ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ អាស៊ានគួរតែនាំមុខសហគមន៍អឺរ៉ុបស្ដីពីការអប់រំអំពីអំពើប្រល័យពូជសាសន៍

◆ សំណុំរឿង០០៣ និង ០០៤ : និយមន័យនៃពាក្យអ្នកទទួលខុសត្រូវខ្ពស់

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧៦ ខែសីហា ឆ្នាំ២០១៤

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៧៦ ខែសីហា ឆ្នាំ២០១៤

## មាតិកា

◆អាស៊ានគួរតែនាំមុខសហគមន៍អឺរ៉ុបស្ដីពី..........................................១

**ផ្នែកឯកសារ**

◆ យុវជន យុវនារីបដិវត្តន៍យើងត្រូវពង្រឹងគោលជំហរ ..........................២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ របាយការណ៍ពីការផ្សាយផ្ទាល់ពីការប្រកាស ......................................៩

◆ គម្រោងឃ្លាំមើលយុត្តិធម៌ ៖ ការកសាងលទ្ធិប្រជា ..........................១៦

◆ ជាប់គុកដោយសារដោះលែងអ្នកទោស ..........................................៤០

◆ ការតស៊ូដើម្បីបដិវត្តន៍ .............................................................៤២

◆ ព្រឹម ជិន ៖ ការលួច និងការបំផ្លាញប្រាសាទ...............................៤៥

**ផ្នែកច្បាប់**

◆ សំណុំរឿង ០០៣ និង ០០៤ ៖ និយមន័យ .............................៥១

**វេទិកាពិភាក្សាសាធារណៈ**

◆ ការចោទប្រកាន់មេដឹកនាំខ្មែរក្រហមលើកឡើងពី..............................៥៥

◆ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ៖ វិទ្យាល័យនៅសហរដ្ឋ........................៥៧

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ ការយល់ដឹងរបស់ខ្ញុំតាមរយៈបទពិសោធ និងរឿង ..........................៥៩



អ្នកភូមិអានសៀវភៅស្ដីពីអំពើប្រល័យពូជសាសន៍ក្នុងរបបខ្មែរក្រហម ក្នុងថ្ងៃប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី១ នៅវត្តព្រៃតាកុយ ខេត្តកែប



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ លី សុខឃាង, ចាន ប្រាថ្នា, រ៉េនឌល ដឹហ្គាលកូ, ស្រីនាថ ដួល និង ម៉ែរាម ម័រហ្គេនស៊្ទើន ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ ទាវ សារៈមុនិន្ទ ***អ្នកបកប្រែ*** ៖ សុភ័ក្ត្រ ភាណា និង ភួង ច័ន្ទប្រណិត ***និពន្ធនាយកទូទៅ*** ៖ ឆាំង យុ និង ញាណ សុជាតិ ***ជំនួយការនិពន្ធនាយក*** ៖ សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ*** ៖ សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ*** ៖ ឆេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# អាស៊ានគួរតែនាំមុខសហភាពអឺរ៉ុបស្តីពីការអប់រំអំពីអំពើប្រល័យពូជសាសន៍

ខ្ញុំយល់ស្របជាមួយនឹងអគ្គរាជទូតសហភាពអឺរ៉ុប លោក ហ្សង់ហ្វ្រង់ស័រ កូតាំង ដែលថា សហភាពអ៊ឺរ៉ុប និង អាស៊ាន គួរតែសហការបន្ថែម ដើម្បីជំរុញលើដំណើរឆ្ពោះទៅមុខ និងសន្តិសុខ ។

តាមទស្សនៈរបស់ខ្ញុំ ដំណើរឆ្ពោះទៅមុខ និងសន្តិសុខនៅអាស៊ានស្ថិតនៅក្នុងការអប់រំអំពី សីលធម៌ ការយល់ដឹងអំពីអំពើយង់ឃ្នងដែលបានកើតឡើងនៅក្នុងតំបន់ និងការអប់រំមនុស្សជំនាន់ក្រោយ នៅក្នុងតំបន់ស្តីពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ដើម្បីបង្កើតជាគំរូសម្រាប់ការទប់ស្កាត់នាពេលអនាគត ។ ដោយសារអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាមានលក្ខណៈខុសពី ហូឡូខសត៍ អាស៊ានគួរតែជាអ្នកនាំមុខក្នុងវិធីសាស្ត្រអប់រំអំពីអំពើប្រល័យពូជសាសន៍ ព្រមទាំងការបង្កើតកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍តាមលក្ខណៈស្តង់ដារនៅក្នុងតំបន់ ។

ទោះបីជាមានបទពិសោធជាច្រើនទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅអឺរ៉ុបនាប៉ុន្មានទសវត្សរ៍កន្លងមកនោះ ដូចជា ការស្លាប់ក្នុងក្បួនដង្ហែរបស់ជនជាតិអាមេនី ការបង្អត់អាហាររបស់ស្តាលីន នៅប្រទេសអ៊ុយក្រែន និង ហូឡូខសត៍ សហភាពអឺរ៉ុបមិនបានបង្កើតវិធីសាស្ត្រអប់រំអំពើប្រល័យពូជសាសន៍ ដែលបម្រើដល់ទស្សនៈដែលថា អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

អាស៊ានមានឱកាសដឹកនាំសហភាពអឺរ៉ុបនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ តាមរយៈការធ្វើខ្លួនជាសហគមន៍ក្នុងតំបន់ដំបូងដែលចែករំលែកមេរៀនអប់រំសីលធម៌នៅតាមប្រទេសសមាជិករបស់ខ្លួន ។ កម្មវិធីអប់រំនេះគួរតែត្រូវបានដាក់បញ្ចូលក្នុងផែនការអាស៊ានថ្មីស្តីពីការអប់រំ ការទទួលស្គាល់គ្រោះកាច ដែលប្រជាជនកម្ពុជាបានប្រឈមមុខចាប់តាំងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ និងការរងទុក្ខរបស់ប្រជាជននៅប្រទេសទីម័រខាងកើតចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៩៩ ។

ចាប់តាំងពីអាស៊ានត្រូវបានបង្កើតនៅក្នុងឆ្នាំ១៩៦៧ អាស៊ានបានជួបប្រទះសង្គ្រាមស៊ីវិល និងអំពើប្រល័យពូជសាសន៍ដែលបណ្តាលឲ្យមានអ្នកស្លាប់រាប់លាននាក់ ។ សង្គ្រាមដែលគួរឲ្យកត់សម្គាល់បំផុតកើតឡើងនៅក្នុងតំបន់ឥណ្ឌូចិន ហើយអំពើប្រល័យពូជសាសន៍ដែលបានកើតឡើង គឺជាអំពើយង់ឃ្នងដែលខ្មែរក្រហមប្រព្រឹត្តប្រឆាំងនឹងប្រជាជនរបស់ខ្លួនផ្ទាល់ ។

ទោះបីជាស្ថិតក្នុងករណីនៃអំពើប្រល័យពូជសាសន៍នេះក៏ដោយ វាមានលក្ខណៈខុសប្លែកពី ហូឡូខសត៍ ដែលបានកើតឡើងក្នុងជម្លោះជុំវិញពិភពលោក ជនរងគ្រោះ និងជនដៃដល់ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់ ។ នៅក្នុងប្រទេសកម្ពុជា អំពើប្រល័យពូជសាសន៍បានកើតឡើងនៅក្នុងជម្លោះក្នុងតំបន់ ក្នុងបរិយាកាសមួយដែលមិនមានការជ្រៀតជ្រែកពីប្រទេសសមាជិកនៅក្នុងអាស៊ាន ។

សន្តិសុខ និងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនៅអាស៊ាននឹងក្លាយជារឿងគ្មានន័យ ប្រសិនបើអំពើយង់ឃ្នងកើតឡើងនៅតាមបណ្តាប្រទេសសមាជិក ទន្ទឹមពេលដែលប្រទេសដទៃត្រឹមតែជាអ្នកឈរមើល ។ **អេង កុកថាយ**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# យុវជន យុវនារីបដិវត្តន៍យើងត្រូវពង្រឹងគោលជំហរ មិត្ត សត្រូវ ឱ្យច្បាស់លាស់ ដើម្បីបន្តវេនបដិវត្តន៍បានខ្លាំងក្លា

*ដកស្រង់ចេញពីទស្សនាវដ្តីទង់បដិវត្តន៍ ឯកសារលេខ D២១៨០២*

ក្រោយថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមធ្វើការជម្លៀសប្រជាជនចេញពីទីក្រុងដោយបង្ខំ ក្រោមលេសថា ធ្វើការបោសសម្អាតខ្មាំង និងជម្លៀសប្រជាជនគេចពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ។ ទន្ទឹមនឹងការជម្លៀសដោយបង្ខំ ខ្មែរក្រហមក៏ធ្វើការបោសសម្អាត សត្រូវទីមួយរបស់ខ្លួនគឺ ទាហាន លន់ នល់ ឬអតីតអ្នករដ្ឋការរបស់ លន់ នល់ ។ ជាក់ស្តែង នៅអំឡុងពេលដែលខ្មែរក្រហមទទួលជ័យជម្នះដំបូង ខ្មែរក្រហមបានប្រកាសតាមវិទ្យុជាតិថា ខ្លួនមិនមែនមកដើម្បីចរចាជាមួយនរណាទាំងអស់



យុទ្ធជនខ្មែរក្រហមកំពុងធ្វើការនៅក្នុងរោងចក្រក្រឡឹង នៅទីក្រុងភ្នំពេញ

និងប្រកាសធ្វើការប្រហារជីវិតមន្ត្រីជាន់ខ្ពស់ និងមេបញ្ជាការទ័ពរបស់រដ្ឋាភិបាលចាស់ទៀតផង ។ ភ្លាមៗ ខ្មែរក្រហមបានប្រហារជីវិតមេដឹកនាំជាន់ខ្ពស់បីរូប មន្ត្រីរាជការ និងទាហានរាប់រយនាក់របស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ។ មេដឹកនាំជាន់ខ្ពស់ទាំងបីរូបនោះមាន នាយករដ្ឋមន្ត្រី ឡុង បូរ៉េត ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ និង លន់ ណុន (ជាប្អូនប្រុសបង្កើតរបស់ លន់ នល់) ។

ការបោសសម្អាតខ្មាំងរបស់ខ្មែរក្រហមមិនទាន់បញ្ចប់ត្រឹមប៉ុណ្ណឹងទេ ខ្មែរក្រហមតែងតែស្រាវជ្រាវរកចាប់ខ្មាំង ដោយជឿជាក់ថា ខ្មាំងមាននៅគ្រប់ទីកន្លែង និងគ្រប់តំបន់ នៅទូទាំងប្រទេស ។ នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មានការប៉ះទង្គិចមួយជាមួយវៀតណាម ហើយការប៉ះទង្គិចនេះ បាននាំទៅដល់ការធ្វើបន្សុទ្ធកម្មដ៏ធំធេងមួយ ។ កម្មាភិបាលខ្មែរក្រហម និងប្រជាជនជាច្រើន ត្រូវបានខ្មែរក្រហមសង្ស័យ និងចោទប្រកាន់ថា ជាភ្នាក់ងារសម្ងាត់របស់អាមេរិក (សេ.អ៊ី.អា) ភ្នាក់ងារសម្ងាត់របស់សូវៀត (កា.ហ្សេ.បេ) និងភ្នាក់ងារសម្ងាត់របស់វៀតណាម ដែលខ្មែរក្រហមចាត់ទុកថា ជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដែលមានគ្រោះថ្នាក់បំផុតសម្រាប់បដិវត្តន៍របស់ខ្លួន ហេតុនេះ ត្រូវតែកម្ទេច ដោយគ្មានការលើកលែងនោះទេ ។ ដូច្នេះ តើខ្មែរក្រហមមានគោលនយោបាយបែបណាក្នុងការអប់រំយុវជនយុវនារីក្នុងការការពារ និងកម្ទេចខ្មាំងរបស់ខ្លួន? ខាងក្រោមនេះ គឺជាអត្ថបទដកស្រង់ចេញពីទស្សនាវដ្តីយុវជន យុវនារីបដិវត្តន៍ ដែលសរសេរអំពីយុវជន យុវនារីបដិវត្តន៍ ត្រូវពង្រឹងគោលជំហរ មិត្ត និងសត្រូវ ឲ្យបានច្បាស់លាស់ ។ តើយុវជនយុវនារី បដិវត្តន៍ ត្រូវធ្វើយ៉ាងដូចម្តេច ក្នុងការបែងចែក មិត្ត និងសត្រូវ ឲ្យបានច្បាស់លាស់?

## ១) ហេតុអ្វីបានជាយើងចាំបាច់ធ្វើបដិវត្តន៍?

យើងលើកសំណួរនេះឡើងវិញ ដើម្បីបញ្ជាក់នូវទិសដៅសំណូមពរ និងឧត្តមគតិរបស់យើងជាជនបដិវត្តន៍ឲ្យច្បាស់លាស់ឡើងវិញ ។

កាលដើមឡើយ សង្គមជាតិ គឺជាសង្គមអាណានិគម ពាក់កណ្តាលសក្តិភូមិ ។ នេះបើគិតតែត្រឹមពេលដែលអាណានិគមបារាំង ចូលរុករានឈ្លានពានទឹកដីកម្ពុជាយើង ។ ក្រោយឆ្នាំ១៩៥៤ សង្គមកម្ពុជាយើង បានវិវត្តមកជាសង្គមពាក់កណ្តាលអាណានិគមពាក់កណ្តាលសក្តិភូមិ ។ លុះក្រោយរដ្ឋប្រហារ ថ្ងៃ១៨ មីនា ១៩៧០ សង្គមកម្ពុជាយើងបានធ្លាក់ទៅជាសង្គមអាណានិគមពាក់កណ្តាលសក្តិភូមិជាថ្មីវិញម្តងទៀត ។ តែបើសរុបឲ្យខ្លីទៅ ក្នុងរយៈកាលទាំង៣នេះ ប្រទេសជាតិ និងប្រជាជនកម្ពុជាយើងត្រូវស្ថិតនៅក្រោមក្រញាំរបស់ចក្រពត្តិអាណានិគមនិយមចាស់ ថ្មី និងស្ថិតក្រោមរបបជិះជាន់ផ្តាច់ការហ្វាស៊ីសនៃពួកវណ្ណៈកាន់អំណាច ជាសក្តិភូមិ និងនាយទុន ជាប់ជាបន្តបន្ទាប់រៀងរហូតមក ។ ដូច្នេះ ប្រជាជនកម្ពុជា ហើយជាពិសេសជាងគេ គឺប្រជាជន កម្មករ កសិករក្រីក្រ ពលករ ដែលមានភាគច្រើនលើសលប់ ក្នុងចំណោមប្រជាជនកម្ពុជាយើងទាំងមូលត្រូវរស់នៅរងទុក្ខវេទនា ឈឺចាប់ខ្លោចផ្សា អាប់ឱនកិត្តិយសក្រោមការជិះជាន់ សង្កត់សង្កិន មើលងាយមើលថោករបស់ចក្រពត្តិ អាណានិគមនិយមចាស់ ថ្មី និងពួកវណ្ណៈកាន់អំណាចក្បត់ជាតិយ៉ាងធ្ងន់ធ្ងរណាស់ គ្មានពេលណាងើបមុខរួចនឹងគេឡើយ ។ ឯប្រទេសជាតិកម្ពុជាយើង ក៏ត្រូវធ្លាក់ខ្លួនទៅជាប្រទេសខ្ញុំគេ អាប់ឱនកិត្តិយស បាត់ឈ្មោះ បោះសំឡេង ស្ទើរតែសូន្យឈឹងទៅហើយ ។ ដូច្នេះ ក្នុងរយៈកាលទាំង៣ខាងលើនេះ ទាំងប្រទេសជាតិ ទាំងប្រជាជនកម្ពុជា ត្រូវស្ថិតនៅក្នុងសភាពខ្មោងងឹតសូន្យសុង គ្មានឃើញពន្លឺរស្មីនៃសេចក្តីរុងរឿង ថ្លៃថ្នូរ ហើយក៏គ្មានឃើញពន្លឺអនាគតរបស់ខ្លួនបន្តិចសោះឡើយ ។ ទិសវិវត្តមានតែមួយគត់ គឺឈានទៅវិនាសសាបសូន្យ បាត់បង់អស់ទាំងឈ្មោះ ទាំងសំឡេង បាត់បង់អស់ទាំងទឹកដី ។ និយាយឲ្យខ្លីទៅ គឺឈានទៅស្លាប់តែម្តង ។

ស្ថិតនៅចំពោះមុខគ្រោះមហន្តរាយដ៏ធំធេង និងទុក្ខសោកឈឺចាប់ ខ្លោចផ្សាឥតត្រើយត្រាណរបស់ប្រទេសជាតិ និងប្រជាជនយើងយ៉ាងនេះ តើយើងទាំងអស់គ្នា ដែលជាកុលបុត្រ កុលធីតា នៃមាតុភូមិកម្ពុជា សុខចិត្តឱបដៃនៅស្ងៀមរង់ចាំថ្ងៃស្លាប់ ឬក៏ក្រោកឡើងតស៊ូរើបម្រះឲ្យរួចចាកផុតពី ច្រវាក់ ខ្នោះឃ្នាង និងនឹមដែកដ៏សែនធ្ងន់របស់ចក្រពត្តិអាណានិគមចាស់ ថ្មី ដើម្បីរំដោះប្រទេសជាតិ រំដោះប្រជាជនរបស់ខ្លួន?

ចំពោះសំណួរនេះ មិត្តយុវជន យុវនារីបដិវត្តន៍យើងទាំងអស់គ្នា ពិតជានឹងឆ្លើយជាឯកច្ឆន្ទ ព្រមគ្នាឡើងថា “ដាច់ខាតតស៊ូ ដើម្បីរំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះខ្លួន ទោះបីជាត្រូវធ្វើពលិកម្មធំធេងយ៉ាងណាក៏ដោយ រហូតដល់ត្រូវពលីអាយុជីវិតខ្លួន

*ទៀតក៏ដោយ» ។*

*នេះហើយ ជាមូលហេតុដែលនាំឲ្យបក្សកុម្មុយនីស្តកម្ពុជាកកើតឡើង ដើម្បីដឹកនាំប្រជាជនក្រីក្រយើងងើបឡើងតស៊ូរើបម្រះខ្លួន ដណ្តើមសិទ្ធិសេរីភាព និងឋានៈខ្លួនជាម្ចាស់ប្រទេស ម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃព្រឹក្សា ម្ចាស់គិរីបព្វតា ម្ចាស់ស្រែចម្ការ និងម្ចាស់លើជោគវាសនាអនាគតរបស់ខ្លួនពេញទី ។ នេះហើយដែលជាហេតុផលនាំឲ្យយើងទាំងអស់គ្នាចាំបាច់ត្រូវតែធ្វើបដិវត្តន៍វាយរំលំនឹមត្រួតត្រាជិះជាន់របស់ចក្រពត្តិ អាណានិគមនិយមចាស់ ថ្មី និងវាយបណ្តេញពួកចក្រពត្តិបរទេស ដែលរុករានទន្ទ្រានឈ្លានពានទឹកដី មាតុភូមិកម្ពុជាជាទីស្នេហានៃយើងឲ្យប្រាសចេញអស់រលីង ព្រមទាំងវាយរំលំនូវរបបជិះជាន់ផ្តាច់ការហ្វាស៊ីសរបស់ពួកវណ្ណៈសក្តិភូមិ និងនាយទុនឲ្យរលាយអស់ពីទឹកដីកម្ពុជាយើងដែរ ។ ដូច្នេះសរុបឲ្យខ្លីមកវិញ យើងធ្វើបដិវត្តន៍ដោយហ៊ានលះបង់អ្វីៗទាំងអស់ រហូតដល់អាយុជីវិតខ្លួនយើងទៀត គឺពុំមែនដើម្បីអ្វីក្រៅអំពីរំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះវណ្ណៈក្រីក្រយើងឡើយ ។ យុវជន យុវនារីបដិវត្តន៍យើង ត្រូវក្តាប់ទិសដៅ និងសំណូមពរនេះឲ្យច្បាស់លាស់ និងឲ្យជាប់ជានិច្ច ។*

*តែមិត្តយើងខ្លះអាចសួរថា ចុះឥឡូវប្រទេសជាតិ និងប្រជាជនកម្ពុជាយើង ត្រូវបានរំដោះ ទាំងស្រុង និងជាស្ថាពរហើយ កាលពីថ្ងៃ១៧ មេសា ១៩៧៥ តើយើងចាំបាច់ធ្វើបដិវត្តន៍សង្គមនិយមបន្តទៀតធ្វើអ្វី?*

*សូមបញ្ជាក់ថា ចក្រពត្តិអាមេរិក ព្រមទាំងមារសត្រូវគ្រប់ប្រភេទរបស់យើងពិតមែនតែវា ត្រូវបរាជ័យ រត់ខ្ចាត់ខ្ចាយអស់ពីទឹកដីកម្ពុជា តាំងពីថ្ងៃ១៧ មេសា ១៩៧៥ ទៅមែន ហើយពួកវណ្ណៈសក្តិភូមិ នាយទុន ព្រមទាំងវណ្ណៈជិះជាន់ផ្សេងទៀត ត្រូវរលំរលាយអស់ជាមូលដ្ឋាន ទាំងរបបនយោបាយ ទាំងមូលដ្ឋានសេដ្ឋកិច្ចក៏ពិតមែន តែពួកអស់នេះ ពុំទាន់រលាយសាបសូន្យអស់នៅឡើយទេ ។ ពួកនេះ គឺទាំងចក្រពត្តិអាមេរិក ទាំងមារសត្រូវគ្រប់ទិសទីនៅក្រៅប្រទេស ទាំងពួកវណ្ណៈជិះជាន់គ្រប់ប្រភេទនៅក្នុងប្រទេស វាខឹងសម្បា និងក្តៅក្រហាយ ចំពោះមហាជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ប្រជាជាតិ និងប្រជាជនកម្ពុជាយើង ក្រោមការដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវ និងភ្លឺស្វាងសម្បើមណាស់ ។ វាឯគោលបំណង និងយុទ្ធសាស្ត្រលេបទឹកដីកម្ពុជា ឈ្លានពានឆក់ប្លន់កម្ពុជា និងជិះជាន់សង្កត់សង្កិនប្រជាជនកម្ពុជាយើងរបស់ពួកវានៅតែដដែល គ្មានពេលណាវាបំភ្លេច ឬបញ្ឈប់សោះឡើយ ។ ឃើញយ៉ាងនេះ ទើបយុវជនយុវនារីបដិវត្តន៍យើងយល់ច្បាស់ថា ក្រោយរំដោះប្រទេសជាតិហើយក៏ដោយ យើងចាំបាច់ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យខ្លាំងក្លា ជ្រាលជ្រៅថែមទៀត តទៅទៀត ដើម្បីការពារប្រទេសជាតិយើង ការពារផលបដិវត្តន៍ដែលយើងដណ្តើមបានមកហើយ និងការពារបក្សកុម្មុយនីស្តដ៏ត្រូវត្រូវនៃយើង ឲ្យបានជារៀងរហូត និងកាន់តែរឹងប៉ឹងខ្លាំងក្លាថែមទៀត ទើបយើងរស់ ។ បើការពារមិនបានទេ នោះយើងប្រាកដជាស្លាប់ហើយ ។ ស្លាប់នេះ មិនមែនស្លាប់ជាបុគ្គល១នាក់ ២នាក់ណាទេ មិនមែនស្លាប់ជាបក្សពួក ឬក្រុមនយោបាយទេ ។ តែស្លាប់នេះ គឺពិតជាស្លាប់ប្រទេសជាតិទាំងមូល ស្លាប់ប្រជាជនកម្ពុជាយើងទាំងមូល ។ ស្លាប់ជាខ្លឹមសារនយោបាយផង ស្លាប់ជាការបង្ហូរឈាមផង ។*

*ហេតុផលមួយទៀតដែលយើងចាំបាច់ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យកាន់តែខ្លាំងក្លា ជ្រាលជ្រៅតទៅទៀត គឺដើម្បីកសាងប្រទេសយើង ដែលជាប្រទេសក្រីក្រទន់ខ្សោយ ហើយទើបចេញផុតពីសង្គ្រាមវិនាសកម្មថែមទៀត ឲ្យទៅជាប្រទេសមួយរឹងប៉ឹងខ្លាំងក្លា មានសមត្ថភាពការពារខ្លួនបាន ដោយឯករាជ្យ ម្ចាស់ការផង និងរីកចម្រើនលូតលាស់លើគ្រប់វិស័យយ៉ាងឆាប់រហ័សបំផុត ដើម្បីឲ្យប្រជាជនយើងដែលធ្លាប់តែរស់នៅរងទុក្ខវេទនា ឈឺចាប់ខ្លោចផ្សា អស់ឃ្លានជាង២០០០ឆ្នាំមកហើយនោះ មានជីវភាពសម្បូរសប្បាយ មានសុភមង្គលពិតប្រាកដ ។ បើរំដោះតែខាងនយោបាយ ហើយជីវភាពខាងសេដ្ឋកិច្ច និងខាងស្មារតីនៅលំបាកតោកយ៉ាកដដែល ក៏យើងមិនទាន់ហៅថា រំដោះទាំងស្រុងបានដែរ ។*

*ហេតុផលទាំងអស់នេះហើយ ដែលយើងទាំងអស់គ្នាចាំបាច់បន្តធ្វើបដិវត្តន៍សង្គមនិយម រហូតឈានទៅធ្វើបដិវត្តន៍កុម្មុយនីស្តនិយមជាបន្តបន្ទាប់ទៅទៀត ឲ្យខ្លាំងក្លា និងជ្រាលជ្រៅដាច់ខាត ដើម្បីការពារប្រទេស និងកសាងកម្ពុជាប្រជាធិបតេយ្យយើងឲ្យរឹងប៉ឹងខ្លាំងក្លា រីកចម្រើនលូតលាស់ សម្បូរសប្បាយ និងថ្កុំថ្កើងរុងរឿងទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិ ។*

### ២) ដើម្បីបន្តធ្វើបដិវត្តន៍បានខ្លាំងក្លា ឈានទៅសម្រេច

## ជ័យជម្នះទាំងស្រុង និងជាស្ថាពរទៀត យុវជន យុវនារីបដិវត្តន៍យើងត្រូវមានជំហរ មិត្ត សត្រូវ ឲ្យច្បាស់លាស់

ឆ្លងកាត់តាមការតស៊ូកម្ទេចខ្សែខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ចាប់តាំងពីក្រោយពេលរំដោះ រហូតមកទល់បច្ចុប្បន្ននេះ ហើយជាពិសេសក្នុងរយៈពេល៦-៧ខែ នាដើមឆ្នាំ១៩៧៧នេះ យើងឃើញច្បាស់ថា បើគ្មានជំហរមិត្ត សត្រូវឲ្យច្បាស់លាស់ទេនោះ យើងពុំអាចកម្ចាត់ខ្សែក្បត់ ខ្សែខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដណ្ដើមបានមហាជោគជ័យដូច្នេះឡើយ ។

ចំពោះខ្មាំង វាឃោរឃៅណាស់ វាដាច់ខាតណាស់ ក្នុងការបំផ្លិចបំផ្លាញបដិវត្តន៍ ប្រទេសជាតិ និងប្រជាជនយើង ក៏ដូចក្នុងការវាយកម្ទេចចលនាបដិវត្តន៍ និងបក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវនៃយើង ។ តាំងពីយើងមិនទាន់ដឹង មិនទាន់រកឃើញថា វាជាខ្មាំងនៅឡើយម៉្លេះ ហើយយើងនៅគោរពស្រឡាញ់រាប់អានពួកវាជាយុទ្ធមិត្តស្លាប់រស់ជាមួយគ្នានៅឡើយម៉្លេះ ខ្មាំងវាបានធ្វើសកម្មភាពបំផ្លិចបំផ្លាញ ទាំងទ្រព្យសម្បត្តិ ទាំងអាយុជីវិតរបស់ប្រជាជន យុទ្ធជន យុទ្ធនារី កម្មាភិបាលយើង បំផ្លិចបំផ្លាញទាំងចលនាបដិវត្តន៍យើង ដោយគ្មានស្ទាក់ស្ទើរ អល់អែក ឬញញើតដៃឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ វារកតែពេល រកតែឱកាស ដើម្បីកម្ទេចយើងដែលជាជនបដិវត្តន៍ និងប្រជាជនស្នេហាជាតិពិតប្រាកដជាប់ជានិច្ច ។ នេះជាធាតុឃោរឃៅហ្វាស៊ីស សាហាវយង់ឃ្នង ដូចសត្វតិរច្ឆាន របស់ពួកអាក្បត់ ជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដែលជាឆ្អែបម្រើដាច់ថ្លៃរបស់ចក្រពត្តិបរទេស និងមារសត្រូវគ្រប់ប្រភេទរបស់ប្រទេសជាតិយើងមកពីខាងក្រៅ ។ ពួកអាអស់នេះ គ្មានសាច់ឈាមជាជនជាតិកម្ពុជា គ្មានចិត្តគំនិត គ្មានមនោសញ្ចេតនា ជាជនជាតិកម្ពុជាបន្តិចសោះឡើយ ។ ពួកវានេះហៅ សែនមហាថោកទាប មហាឃោរឃៅហ្វាស៊ីស រកឈ្មោះអ្វីមកដាក់ឲ្យពួកវាពុំត្រូវឡើយ ។ ពេលដែលប្រទេសជាតិនិងប្រជាជនកម្ពុជាទាំងមូលកំពុងឆ្លងកាត់ការលំបាកអត់ឃ្លាន ខ្វះសព្វ ខ្វះគ្រប់ ប្រយុទ្ធ ធ្វើសង្គ្រាមបដិវត្តន៍វាយកម្ទេចខ្មាំងសត្រូវ ដើម្បីរំដោះប្រទេសជាតិ និងរំដោះប្រជាជនខ្លួន ពួកអាក្បត់អស់ទាំងនេះដែលវាមកបង្កប់ស៊ីរូងផ្ទៃក្នុងបក្ស ផ្ទៃក្នុងកងទ័ព ផ្ទៃក្នុងបដិវត្តន៍ និងផ្ទៃក្នុងប្រជាជនយើង វាបែរជានាំគ្នាធ្វើសកម្មភាពបំផ្លិចបំផ្លាញស្រូវ អង្ករ និង ទ្រព្យសម្បត្តិរបស់ប្រជាជនយើង ព្រមទាំងរាយការណ៍ឲ្យចក្រពត្តិអាមេរិក និងបរិវារយកយន្តហោះគ្រប់ធុន ដែលមានយន្តហោះបេ៥២ជាដើម មកទម្លាក់គ្រាប់បែក និងបាញ់រះបំផ្លិចបំផ្លាញភូមិករ ផ្ទះសម្បែង ច្បារដំណាំ គោក្របី និងអាយុជីវិតរបស់ប្រជាជនយើង យុទ្ធជន-យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍យើងយ៉ាងឃោរឃៅព្រៃផ្សៃផុតលេខ ។ ក្រោយពេលសង្គ្រាមត្រូវចប់ ប្រទេសជាតិ និងប្រជាជនយើងត្រូវបានរំដោះទាំងស្រុង និងស្ដាពរហើយ ក្នុងពេលដែលប្រជាជន និងប្រជាជាតិកម្ពុជាទាំងមូលកំពុងរីករាយអបអរសាទរនឹងមហាជ័យជម្នះនេះ ហើយនាំគ្នាវាយសម្រុក ការពារ និងកសាងប្រទេសយ៉ាងសស្រាកសស្រាំ ទាំងយប់ ទាំងថ្ងៃ ពួកអាប្រែតតិរច្ឆាន ដែលជាភ្នាក់ងារឆ្អែបម្រើមារសត្រូវបរទេសគ្រប់ប្រភេទ វាបែរជាមួរម៉ៅក្ដៅក្រហាយ ខិតខំធ្វើសកម្មភាពបំផ្លិចបំផ្លាញគ្រប់បែបយ៉ាង ដើម្បីរាំងរាបន្ទុចបង្អាក់ចលនាកសាង និងការពារប្រទេសរបស់ប្រជាជនកម្ពុជា ក្រោមការដឹកនាំនៃបក្សកុម្មុនីស្តកម្ពុជា ដ៏ត្រឹមត្រូវទៅវិញ ។ មិនត្រឹមតែប៉ុណ្ណោះ ពួកវានៅបានពាំនាំយកផែនការរដ្ឋប្រហារវាយរំលំបក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ វាយរំលំបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់ប្រជាជនកម្ពុជាយើង អំពីមារសត្រូវបរទេសគ្រប់ទិសទី និងអំពីចក្រពត្តិអាមេរិកមកអនុវត្តយ៉ាងសកម្មទៀត ប៉ុនប៉ងយកកម្ពុជាប្រជាធិបតេយ្យយើង និងប្រជាជនកម្ពុជាយើងដែលទើបត្រូវបានរំដោះថ្មីៗនេះ ទៅធ្វើជាខ្ញុំកញ្ជះចក្រពត្តិអាមេរិក និងខ្មាំងសត្រូវបរទេសផ្សេងទៀតដែលតែងតែប៉ុនប៉ងលេបទឹកដីកម្ពុជាយើងជារៀងរហូតមក ។

ឃើញធាតុឃោរឃៅហ្វាស៊ីស ធាតុទាបថោកជាខ្ញុំកញ្ជះចក្រពត្តិបរទេស និងឃើញសកម្មភាពបំផ្លិចបំផ្លាញ វាយរំលំប្រទេសជាតិយើង ប្រជាជនយើង ចលនាបដិវត្តន៍យើង និងបក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវនៃយើងយ៉ាងនេះ របស់ពួកអាក្បត់ដែលជាខ្មាំងបង្កប់ស៊ីរូង និងជាឆ្អែបម្រើដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក និងមារសត្រូវបរទេសយ៉ាងដូច្នេះ តើយុវជន យុវនារីបដិវត្តន៍យើងអាចឱបដៃនៅស្ងៀមទុកឲ្យខ្មាំងបំផ្លិចបំផ្លាញតាមចិត្ត ឬក៏ប្រយុទ្ធតស៊ូវាយកម្ទេច និងបោសសម្អាតវាឲ្យអស់ពីក្នុងជួរបដិវត្តន៍យើងទាំងមូល និងពីក្នុងសង្គមជាតិយើងទាំងមូល?

ចំពោះសំណួរនេះ យុវជន យុវជននារីកម្ពុជាយើងដែល

មានស្មារតីស្នេហាជាតិ សូម្បីតែបន្តិចបន្តួចក៏ប្រាកដនឹងឆ្លើយព្រមគ្នាថា "ដាច់ខាតវាយកម្ទេច និងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងទាំងនេះ ឲ្យស្អាតអស់រលីងចេញពីក្នុងជួរបដិវត្តន៍ និងពីក្នុងសង្គមជាតិយើងទាំងមូលដាច់ខាត ទោះបីត្រូវឆ្លងកាត់គ្រោះថ្នាក់ ឬការលំបាកស្មុគស្មាញយ៉ាងណា ទោះបីត្រូវធ្វើពលិកម្មធំធេងយ៉ាងណាក៏ដោយ" នេះហើយជាជំហរព្រំដែនមិត្តសត្រូវយ៉ាងរឹងប៉ឹងច្បាស់លាស់ដាច់ខាតរបស់យុជន យុវនារី កម្ពុជាយើង ។ ដោយសារយុវជន យុវនារី បដិវត្តន៍កម្ពុជាយើង ក៏ដូចជាប្រជាជនកម្ពុជាយើងទាំងមូលដែរ មានជំហរព្រំដែនមិត្តសត្រូវច្បាស់លាស់យ៉ាងនេះហើយ បានជាចលនាភាវរកខ្មាំង បោសសម្អាតខ្មាំង និងវាយកម្ទេចខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងនៅគ្រប់ទិសទី គ្រប់អង្គភាព គ្រប់ក្រសួងមន្ទីរ គ្រប់សហជីព សហករណ៍ មានសភាពគគ្រឹកគគ្រេងខ្លាំងក្លាសស្រោកសស្រាំណាស់ ។ ប្រជាជនយុវជនយុវនារីកម្ពុជាយើងសស្រោកសស្រាំតាមដានភាវរកខ្មាំង ដេញកម្ទេចខ្មាំង ហាក់បីដូចជា យើងព័ទ្ធស្ទាក់ដេញកម្ទេចសត្វកណ្តុរដូច្នោះដែរ ធ្វើឲ្យខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងគ្រប់ប្រភេទទាំងអស់ ទោះបីជា បង្កប់ជ្រៅយ៉ាងណាក្តី ទោះបីជាបង្កប់យូររាប់សិបឆ្នាំមកហើយក្តី ភិតភ័យញ័ររន្ធត់ហើយបែកមុខ បែកមាត់ក្បត់នៅកណ្តាលវាល ។ ដូច្នេះ ពួកវាក៏ត្រូវមហាចលនាមហាជន កិនសំពៀត និងបោសសម្អាតជាបន្តបន្ទាប់ ។ នេះជាមហាជ័យជម្នះដ៏ធំធេងសម្បើមមានលក្ខណៈជាប្រវត្តិសាស្ត្រថ្មីមួយទៀត របស់ប្រជាជន យុវជន យុវនារីកម្ពុជាយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ នៃបក្សកុម្មុយនីស្តកម្ពុជា បន្ទាប់ពីមហាជ័យជម្នះជាប្រវត្តិសាស្ត្រថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ កន្លងទៅ ។ ប៉ុន្តែបើសិនណាជាប្រជាជនយុវជនយុវនារីកម្ពុជា ព្រមទាំងបក្សកុម្មុយនីស្តកម្ពុជា គ្មានព្រំដែនវណ្ណៈរឹងប៉ឹង គ្មានជំហរបែងចែកមិត្តសត្រូវឲ្យច្បាស់លាស់ដាច់ខាតទេ នោះយើងប្រាកដជាពុំអាចដណ្តើមមហាជ័យជម្នះដ៏ធំធេងអស្ចារ្យនេះបានឡើយ ហើយមិនត្រឹមតែប៉ុណ្ណោះ យើងប្រាកដជាជួបប្រទះនូវគ្រោះមហន្តរាយយ៉ាងធំធេងថែមទៀតផង ។

### ៣) គ្រោះថ្នាក់នៃការធ្វើបដិវត្តន៍ដោយគ្មានជំហរមិត្ត សត្រូវច្បាស់លាស់

ទន្ទឹមនឹងគុណសម្បត្តិខាងលើនេះក៏នៅមានការខ្វះខាត ដោយដុបដោយដុំ ដោយបុគ្គលខ្លះៗ នៅឡើយ ។ ក្នុងពេលដែលប្រជាជាតិ ប្រជាជន និងយុវជន យុវនារីកម្ពុជាទាំងមូល សស្រោកសស្រាំ ភាវរកខ្មាំង សស្រោកសស្រាំក្នុងការបោសសម្អាតកម្ទេចខ្មាំង និងក្នុងពេលដែលយើងទាំងអស់គ្នាសប្បាយរីករាយ នឹងមហាជ័យជម្នះដ៏ធំធេងខាងលើនេះរបស់យើងក៏នៅមានយុវជន យុវនារី មួយចំនួន



យុទ្ធនារីខ្មែរក្រហមកំពុងធ្វើការនៅរោងចក្រតម្បាញ

(ភាគតិចទេ) មានទស្សនៈគោលជំហរមិនត្រឹមត្រូវមិនបដិវត្តន៍ ដែលទោះចង់ ឬមិនចង់ដឹងខ្លួនក្តី ឬមិនដឹងខ្លួនក្តី វាចំណោញដល់ខ្មាំង ។ បាតុភាពខុសឆ្គងទាំងអស់នេះមានដូចតទៅ៖

◆ ក្នុងពេលដែលបក្សណែនាំឲ្យលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ច ដើម្បីទប់ទល់ និងវាយកម្ចាយនូវរាល់

ខុបាយកល ស៊ីរូងបំផ្លិចបំផ្លាញរបស់ខ្មាំង មានយុវជន យុវនារី បដិវត្តន៍យើងខ្លះ មិនរវេរវល់អើពើ មិនចាប់អារម្មណ៍ពីបញ្ហាខ្មាំង បន្តិចសោះឡើយ ។ គេធ្លាក់ទៅសន្តិភាពនិយម កសាងនិយម ហើយ ធ្វេសប្រហែស ធូររលុងនៅគ្រប់ជំហាន ដោយគេមានទស្សនៈថា ឈ្នះហើយ សន្តិភាពហើយ អស់ខ្មាំងហើយ ចាំបាច់អីទៅប្រុង



ប្រយ័ត្ន ការពារពេក នាំតែខាតកម្លាំង នាំតែខាតពេលវេលា ក្នុងការ កសាងប្រទេស ។ល ។ ដូច្នេះ គេមើលពុំឃើញខ្មាំង គេបើកទ្វារចំហ ទុកឲ្យខ្មាំងកក្កូរកកាយ ធ្វើសកម្មភាពបំផ្លិចបំផ្លាញ ទាំងទ្រព្យសម្បត្តិ ជាតិ ទាំងកម្លាំងបដិវត្តន៍បានតាមចិត្ត ។

◆ មានប្រភេទយុវជន យុវនារីយើងមួយចំនួនទៀតគិតតែ សម្ងំសុខយករួចខ្លួន ចង់អ្នកណាធ្វើអី ក៏ធ្វើទៅខ្លួនគេមិនដឹងមិនឮ អ៊ីទាំងអស់ ទុកខ្លួនគេហាក់ដូចជាស្ថិតនៅក្រៅសង្គមជាតិ និងក្រៅ មហាចលនាមហាជន ដែលកំពុងតែបក់បោកគ្រាំគ្រេងគ្រប់ទិស ទី ។ ដូនកាលគេឃើញ ស្តាប់ឮ និងដឹងរឿងក្បត់ខ្លះៗដែរ តែគេ ធ្វើគ គេធ្វើថ្លង់ គេធ្វើខ្វាក់ មិនឈឺឆ្អាលអ៊ីទាំងអស់ ។ គេទល់ភ្នែកចាំ មើលខាងណាឈ្នះ ។ បើខាងណាឈ្នះ ក៏បម្រើខាងនោះតទៅទៀត ទៅ ជាការស្រេច ។ ម្ល៉ោះហើយ បើមានជំហរបែបនេះ ទោះចង់ ឬ មិនចង់ វាជាការរួមគំនិតក្បត់ជាមួយខ្មាំង វាជាការបើកដៃ និង បើកទ្វារចំហឲ្យខ្មាំងធ្វើសកម្មភាពបំផ្លិចបំផ្លាញប្រទេសជាតិ ប្រជា ជនបដិវត្តន៍ និងបក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវរបស់ខ្លួនបាន ពេញទំហឹង ។

◆ នៅពេលដែលបក្ស មានវិធានការចំពោះពួកអាក្បត់ដែល ជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង និងជាភ្នាក់ងារផ្សែបម្រើចក្រពត្តិអាមេរិក និងមារសត្រូវបរទេសគ្រប់ប្រភេទ មានយុវជន យុវនារី យើងខ្លះ មិនត្រឹមតែមិនឈឺចាប់ ឬមិនបានចូលរួមក្នុងការវាយកម្ទេចបោស សម្អាតខ្មាំងជាមួយបក្ស ជាមួយចលនាមហាជន ក្រោមការដឹកនាំ របស់បក្សប៉ុណ្ណោះទេ តែគេបែរជាមានការព្រួយបារម្ភចំពោះ សន្តិសុខផ្ទាល់ខ្លួនគេ ឬមានមនោសញ្ចេតនាអាណិត អាសូរ ឬរហូត ដល់ទៅសោកស្តាយបុគ្គលខ្មាំង បុគ្គលក្បត់នឹងបក្សបដិវត្តន៍ ប្រទេស ជាតិ និងប្រជាជនខ្លួនថែមទៀតផង ។ តែគេពុំមានស្មារតីអាណិត អាសូរដល់ប្រទេសជាតិ ប្រជាជនបដិវត្តន៍ដែលត្រូវខ្មាំងស៊ីរូង បំផ្លិចបំផ្លាញវិនាសហិនហោចរាប់សិបឆ្នាំមកហើយនោះឡើយ ។ គេពុំឈឺចាប់នឹងខ្លួនគេ ដែលពុំបានចូលរួមក្នុងការពិនិត្យតាមដាន រាវរកខ្មាំងឲ្យឃើញ ហើយបណ្តោយឲ្យខ្មាំង ធ្វើសកម្មភាពស៊ីរូង បំផ្លិច បំផ្លាញបានតាមចិត្តរាប់សិបឆ្នាំមកហើយនោះឡើយ ។ មានអ្នក ខ្លះទៀត ដោយមានមនោសញ្ចេតនាអាណិតមេត្តាចំពោះបុគ្គលនេះ ទោះបីជាឃើញសកម្មភាពរបស់បុគ្គលនោះមិនត្រឹមត្រូវតាម មាគ៌ារបស់បក្ស មិនល្អចំពោះបដិវត្តន៍ខ្លះក៏ដោយ ក៏គេពុំហ៊ាន រាយការណ៍ជូនបក្ស ព្រោះខ្លាចបក្សមានវិធានការ ។ ហើយពេល បក្សសួរណែនាំអី គេថែមទាំងជួយលុបលាង ជួយសម្រាលទោស កំហុស និងអំពើក្បត់ថែមទៀតផង ។ បើមានទស្សនៈ គោលជំហរ ទន់ជ្រាយបែបនេះ មានមនោសញ្ចេតនាគ្មានព្រំដែនវណ្ណៈបែបយ៉ាង

នេះ ទោះចង់ ឬមិនចង់ ដឹងខ្លួនក្តី ឬមិនដឹងខ្លួនក្តី ក៏ជាការស៊ីគ្រលំ ជួយលាក់បំពួនខ្មាំង ហើយបើកទ្វារចំហឲ្យខ្មាំងធ្វើសកម្មភាព បំផ្លិចបំផ្លាញសម្ងាប់បក្ស សម្ងាប់បដិវត្តន៍ សម្ងាប់ប្រទេសជាតិ និងប្រជាជនខ្លួនបានតាមចិត្តដែរ ។

◆ ក្នុងពេលដែលបក្សបំផុសមហាជន ចលនាមហាជន រាវរកខ្មាំង និងបោសសម្អាតខ្មាំង មានយុវជន យុវនារីយើងខ្លះមិនត្រឹមតែមិនបានចូលរួមដោយសកម្មក្នុងមហាចលនាបោសសម្អាតខ្មាំងប៉ុណ្ណោះទេ តែនៅដោយរោយជាទស្សនៈ ជាគោលជំហរជាពាក្យសម្តី និងជាទម្លាប់ផ្សេងៗ តាមខ្មាំង ហើយយកទស្សនៈ គោលជំហរពាក្យសម្តីរបស់ខ្មាំងទាំងនោះមកអនុវត្តមកផ្សព្វផ្សាយ ធ្វើឲ្យប្រឫកប្របល់នៅក្នុងចំណោមមហាជន បន្ធុចបន្ធាក់ដល់មហាចលនាបោសសម្អាតខ្មាំង ឬក៏ធ្វើឲ្យប្រឫកប្របល់ស្រពេចស្រពិលក្នុងការរាវរកខ្មាំង ។ ដូច្នេះ ទោះចង់ ឬមិនចង់ គេបម្រើខបាយកលខ្មាំងពេញទី ។

◆ មានយុវជន យុវនារីយើងខ្លះទៀត ក្នុងពេលដែលខ្មាំងកំពុងធ្វើសកម្មភាពអុកឡុកបំផ្លិចបំផ្លាញនៅគ្រប់ទិសទី គេគ្មានឈឺឆ្អាល ចូលរួមជាមួយមហាជន ក្រោមការដឹកនាំរបស់បក្ស ជួយពិនិត្យតាមដាន ស្រាវជ្រាវរាវរកខ្សែខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឡើយ គេគិតតែភ្លើតភ្លើន ហ៊ឺហា មុខមាត់បុណ្យសក្តិ សេរីមិនគោរពអង្គការវិន័យ ហើយរហូតដល់ពេលខ្លះទោមនស្ស ថ្នាំងថ្នាក់ជាមួយសមូហភាពជាមួយបក្សអំពីរឿងកម្មសិទ្ធសួនតួរបស់គេទៀត ។ ដល់ខ្មាំងក្តាប់ចំណុចខ្សោយទាំងនេះបាន វាក៏ចាក់ចុចញុះញង់ឲ្យកាន់តែភ្លើតភ្លើន ឬកាន់ស្មុគស្មាញខ្មោងនឹកថែមទៀត រួចហើយវាក៏អូសទាញទៅបញ្ចូលខ្សែក្បត់របស់ពួកវា រួមសកម្មភាពក្បត់ប្រទេសជាតិ ក្បត់ប្រជាជន ក្បត់បក្ស ក្បត់បដិវត្តន៍ឯង ជាមួយខ្មាំងយ៉ាងថោកទាបបំផុត ។ យុវជនប្រភេទនេះ ច្រើនតែធ្លាក់ទៅជាចំណីខ្មាំងយ៉ាងងាយ ហើយវិនាសខ្លួនដោយឥតប្រយោជន៍ នឹងដោយទាបថោកបំផុត ។

ទស្សនៈ គោលជំហរខុសឆ្គងទាំងអស់នេះ គឺបណ្តាលមកពីគ្មានកំហឹងវណ្ណៈចំពោះខ្មាំង គ្មានព្រំដែនមិត្តសត្រូវច្បាស់លាស់ ។ ដូច្នេះធ្វើបដិវត្តន៍របៀបនេះដែលចេះតែបណ្តែតៗ ទៅតាមចលនា ហើយគ្មានព្រំដែនមិត្តសត្រូវច្បាស់លាស់ គ្មានកំហឹង ចំពោះខ្មាំងឲ្យក្តៅងំជាប់ជានិច្ចដោយខ្លួនឯងទេ គ្រោះថ្នាក់ធំណាស់ចំពោះប្រទេសជាតិ ប្រជាជន ក៏ដូចចំពោះចលនាបដិវត្តន៍ទាំងមូល ហើយក៏ដូចចំពោះបុគ្គលផ្ទាល់ខ្លួនដែរ ។ ធ្វើបដិវត្តន៍របៀបនេះមិនខ្លាំងក្លាទេ មិនធានាអនាគតយូរអង្វែងទេ ហើយមិនត្រឹមតែមិនអាចដណ្តើមជ័យជម្នះទីអវសានបានប៉ុណ្ណោះទេ តែមុខជានឹងជួបនូវគ្រោះមហន្តរាយវិនាសដល់ខ្លួន អន្តរាយដល់ប្រទេសជាតិ ប្រជាជន និងចលនាបដិវត្តន៍ទាំងមូលទៀតផង ។

ដូច្នេះសរុបមកវិញ ដើម្បីធ្វើបដិវត្តន៍បានខ្លាំងក្លាទាំងចំពោះមុខ ធានាទាំងអនាគតយូរអង្វែង ហើយដណ្តើមបានជ័យជម្នះជាបន្តបន្ទាប់រហូតដល់សម្រេចជ័យជម្នះទាំងស្រុងនៅទីអវសានបាន យុវជន យុវនារីបដិវត្តយើងចាំបាច់ត្រូវពង្រឹងគោលជំហរមិត្តសត្រូវ ឲ្យបានច្បាស់លាស់រឹងប៉ឹងដាច់ខាត កុំស្ទាក់ស្ទើរ កុំស្រពិចស្រពិល កុំមនោសញ្ចេតនាឥតព្រំដែនវណ្ណៈឲ្យសោះ ។ យុវជន យុវនារីបដិវត្តន៍យើង ត្រូវមានទស្សនៈមួយឲ្យច្បាស់លាស់ថា "បើយើងមិនកម្ទេចខ្មាំង គឺខ្មាំងកម្ទេចយើង" ។

មិត្តយុវជន យុវនារីទាំងឡាយ មិត្តជាកម្លាំងស្រួចកម្លាំងឈានមុខដែលត្រូវវាយ សម្រុកធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម នៅពេលបច្ចុប្បន្ន និងបន្តវេនតទៅអនាគតឲ្យខ្លាំងក្លាបំផុត ។ មិត្តជាសេចក្តីសង្ឃឹមរបស់ប្រទេសជាតិ ប្រជាជន និងរបស់បក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវនៃយើង មិត្តត្រូវតែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ ឲ្យខ្ពស់ជាប់ជានិច្ច ចំពោះគ្រប់ខបាយកលរបស់ខ្មាំង ខិតខំពង្រឹងគោលជំហរបដិវត្តន៍គ្រប់ផ្នែកឲ្យដល់ខ្លួន ហើយក្នុងនេះ គឺត្រូវពង្រឹងជំហរមិត្តសត្រូវឲ្យច្បាស់លាស់ដាច់ខាត ទើបមិត្តធ្វើបដិវត្តន៍បានខ្លាំងក្លា ហើយបន្តវេនបដិវត្តន៍ទៅអនាគតទៀត ក៏ធានាថារឹងប៉ឹងខ្លាំងក្លា ហើយការពារប្រទេស និងកសាងប្រទេសក៏បានកាន់តែរឹងប៉ឹង ខ្លាំងក្លា និងកាន់តែល្អប្រសើរជារៀងរហូតទៅ ។ បើយុវជន យុវនារីបដិវត្តន៍យើងនេះ សម្រេចសំណូមពរខាងលើនេះបាន នោះទើបធានាចលនាបដិវត្តន៍យើងឲ្យនៅតែក្រហមឆ្អិនឆ្អៅជារៀងរហូត គ្មានខ្មាំង សត្រូវណាអាចមកប្រែពណ៌សម្បុរបានឡើយ ទើបធានាដល់អនាគតថ្កុំថ្កើងរុងរឿង សប្បុរសប្បាយនៃប្រទេសជាតិ និងប្រជាជនកម្ពុជាយើងជារៀងរហូត ។

**ឆាយ សារៈមុនិន្ទ**

# របាយការណ៍ពីការផ្សព្វផ្សាយផ្ទាល់ពីការប្រកាសសាលក្រមករណី០០២ ជំណាក់កាលទី១ នៅវត្តអូរចោទ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

ក្រុមការងារបានធ្វើដំណើរអស់រយៈពេល៦ម៉ោង កាត់តាមផ្លូវជាតិលេខ៥ និងផ្លូវខេត្តលេខ ៥៧B នៃស្រុកបវេលភ្ជាប់ទៅស្រុកមួយចំនួនទៀតដែលស្ថិតនៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃ នៃភាគពាយ័ព្យប្រទេសកម្ពុជា ។ ផ្លូវកៅស៊ូទាំងនេះ បានសាងសង់ឡើងនៅអំឡុងពេលប្រទេសកម្ពុជាមានជម្លោះជាមួយប្រទេសថៃទាក់ទងនឹងរឿងវិវាទប្រាសាទព្រះវិហារ ។ នៅអមសងខាងផ្លូវ យើងឃើញផ្ទះដែលទើបនឹងសាងសង់ថ្មីៗជាច្រើន និងឃើញវាលធំល្វឹងល្វើយ និងឃើញប្រជាជនកំពុងមមាញឹកភ្ជួររាស់ដីធ្វើចម្ការ ។ ជារឿយៗ យើងឃើញឃ្លាំងធំៗ ដែលឈ្មួញសាងសង់សម្រាប់ផ្ទុកគ្រាប់ធញ្ញជាតិ ដែលប្រមូលទិញពីកសិករ ។ តមកយើងឃើញចម្ការដំឡូងមីរាប់ម៉ឺនហិកតា ចម្ការពោតដែលដាំរួចហើយដុះឡើងពណ៌បៃតងចាស់ ជាមួយដំណាំហូបផ្លែជាច្រើនមុខទៀត ។ ដោយសារតំបន់នេះ ជាតំបន់ខ្ពង់រាប ដូច្នេះ ប្រជាជនមិនសូវដាំស្រូវប៉ុន្មានទេ គឺដាំសម្រាប់តែផ្គត់ផ្គង់ និងហូបក្នុងគ្រួសារប៉ុណ្ណោះ ។ នៅលើផ្លូវនេះ ចរាចរមិនសូវមមាញឹកប៉ុន្មានទេ គឺយូរៗម្ដងយើងឃើញរថយន្តតាក់ស៊ី រថយន្តក្រុង និង ត្រាក់ទ័រដឹកផលិតផលកសិកម្មពីចម្ការបើកឆ្លងកាត់ ។ ក្រឡេកទៅខាងមុខឆ្ងាយយើងឃើញកំពូលភ្នំជាច្រើនដែលអាចឲ្យយើងដឹងជាព្រំប្រទល់រវាងប្រទេសខ្មែរ និងប្រទេសថៃ ។ នៅចុងបញ្ចប់ ក្រុមយើងបានមកដល់ទីរួមស្រុកភ្នំព្រឹក ដែលមានចម្ងាយប្រមាណ៤០០គីឡូ



ភ្នំព្រឹក (មើលពីចម្ងាយ) ស្ថិតនៅក្នុងឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

ម៉ែត្រ ពីទីក្រុងភ្នំពេញ ។

## សង្ខេបស្រុកភ្នំព្រឹក

ស្រុកភ្នំព្រឹក ជាស្រុកមួយក្នុងចំណោមស្រុកទាំង១៤ នៃខេត្តបាត់ដំបង ដែលជាប់ព្រំប្រទល់ជាមួយនឹងខេត្តច័ន្ទបុរី ប្រទេសថៃ ។ ភ្នំព្រឹកជាស្រុកដែលសម្បូរទៅដោយភ្នំ និងព្រៃឈើក្រាស់ៗ កាលពីសម័យមុន និងមិនសូវមានមនុស្សចូលទៅរស់នៅទេ ដោយសារតែតំបន់នោះ ជាតំបន់សម្បូរទៅដោយជំងឺគ្រុនចាញ់ ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០ ស្រុកនេះបានក្លាយទៅជាមូលដ្ឋានតស៊ូរបស់កម្មាភិបាល និងកងទ័ពខ្មែរក្រហម ដែលរត់គេចចេញពីកងទ័ពវៀតណាម និងកងទ័ពរណសិរ្សរំដោះជាតិកម្ពុជាក្នុងឆ្នាំ១៩៧៩ ។ ក្រោយមក ក្រោមផែនការក-៥ របស់រដ្ឋកម្ពុជា (រដ្ឋាភិបាលក្រុងភ្នំពេញ) ដែលគាំទ្រដោយវៀតណាម បានកាប់ព្រៃមួយចំនួននៅក្នុងស្រុកនេះ ក្នុងគោលបំណងដើម្បីបំផ្លាញជម្រកលាក់ខ្លួនរបស់ខ្មែរក្រហម ។ កងទ័ពខ្មែរក្រហមមួយចំនួន បានរត់ចូលទៅរស់នៅនិងបោះទីតាំងក្នុងដីកដីថៃ ដោយមានការគាំទ្រពីរដ្ឋាភិបាលថៃ និងជំនួយហិរញ្ញវត្ថុពីប្រទេសចិន និងប្រទេសមួយចំនួនទៀត ។ ចាប់តាំងពីពេលនោះមក ភ្នំព្រឹកបានក្លាយទៅជាសមរភូមិប្រយុទ្ធគ្នា និងជាតំបន់ប្រទាញប្រទង់រវាងកងទ័ពខ្មែរក្រហម និងរដ្ឋាភិបាលភ្នំពេញ ។ រហូតដល់ឆ្នាំ១៩៩១ ពេលកិច្ចចរចាបញ្ចប់សង្គ្រាមរវាងរដ្ឋាភិបាលត្រីភាគី ភាគីខ្មែរក្រហម, ហ៊ុនស៊ិនប៉ិច និង រដ្ឋាភិបាលភ្នំពេញ នៅក្រុងប៉ារីសរៀបចំឡើង ខ្មែរក្រហមចាប់ផ្ដើមបញ្ជូនកងទ័ពរបស់ខ្លួន និងប្រជាជនកាន់តែច្រើនពីប្រទេសថៃឲ្យមករស់នៅក្នុងស្រុកភ្នំព្រឹកនេះវិញ ។ ទោះបីយ៉ាងណា សង្គ្រាមមិនបានបញ្ចប់ទេ ដោយសារខ្មែរក្រហមបានបដិសេធក្នុងការចូលរួមបោះឆ្នោតសកល នៅឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយកងថែរក្សាសន្តិភាពបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ ហៅកាត់ថា អ៊ុនតាក់ ។ នៅពេលនោះដែរ តំបន់នេះបានគ្រប់គ្រងទាំងស្រុងដោយកងពល៣២០ ក្រោមការដឹកនាំរបស់ នី កន ជាប្អូន



ផ្លូវកាត់តាមស្រុកភ្នំព្រឹក ឆ្ពោះទៅស្រុកសំពៅលូន និង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ប្រុសរបស់ សុន សេន អតីតរដ្ឋមន្ត្រីក្រសួងការពារជាតិរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ ក្រោយមក យោធាខ្មែរក្រហមមួយចំនួនបានអាក់អន់ចិត្តជាមួយនឹងមេបញ្ជាការរបស់ខ្លួន ដោយសារតែមានការរឹតបន្តឹងក្នុងជីវភាពរស់នៅ និងហាមប្រាមចំពោះការជួញដូរជាលក្ខណៈឯកជន ទើបយោធាទាំងនោះរត់ទៅចូលជាមួយកងពល៤៥០ របស់ សុខ ភាព ក្រោមជំនួយហិរញ្ញវត្ថុ ពី អៀង សារី នៅតំបន់ម៉ាឡៃវិញ ព្រោះការគ្រប់គ្រងនៅម៉ាឡៃ មានលក្ខណៈសេរីជាង ។ ដើម្បីទប់ស្កាត់សកម្មភាព រត់ចោលអង្គភាពបែបនេះ មេបញ្ជាការដែលគ្រប់គ្រងនៅភ្នំព្រឹកបានដាក់បញ្ជាឲ្យយោធាដែលស្មោះត្រង់នឹងខ្លួនដាក់មីននៅតាមបណ្តោយព្រំប្រទល់តំបន់ដែលខ្លួនគ្រប់គ្រងតែម្តង ។ រហូតដល់ឆ្នាំ១៩៩៦ យោធារបស់ខ្មែរក្រហមជាច្រើននៅភ្នំព្រឹក បានចាប់ផ្តើមងើបឡើងបះបោរ ហើយបានផ្តាច់ខ្លួនទៅចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ បន្ទាប់ពីផ្តាច់ខ្លួនរួច អតីតកម្មាភិបាលខ្មែរក្រហមបានជ្រើសយកឃុំភ្នំព្រឹកធ្វើជាទីស្នាក់ការស្រុកដើម្បីធ្វើការងារ ។ ប៉ុន្តែក្រោយមក ដោយសារទីនោះ ជាតំបន់ភ្នំ មិនសូវមានប្រជាជនមករស់នៅ និងមិនមានផ្លូវទំនាក់ទំនងទៅខាងថៃ ទើបរដ្ឋាភិបាលសម្រេចផ្លាស់ទីស្នាក់ការស្រុកទៅនៅឃុំពេជ្រចិន្តាវិញ ។

បច្ចុប្បន្នស្រុកភ្នំព្រឹកមានឃុំទាំងអស់ចំនួន៥ គឺ ឃុំភ្នំព្រឹក, ពេជ្រចិន្តា, ចក្រី, បារាំងធ្លាក់ និង ឃុំអូររំដួល ។ ប្រជាជនជាង៩០ ភាគរយនៃស្រុកនេះ ជាអតីតយោធា និងកម្មាភិបាលខ្មែរក្រហមមកពីខេត្តតាកែវ និងកំពត ។ ក្រៅពីនោះជាអ្នកស្រុកចំណូលថ្មី មកពីខេត្តកំពង់ស្ពឺ កំពង់ធំ សៀមរាប បាត់ដំបង កំពង់ចាម និងខេត្តមួយចំនួនទៀតនៅទូទាំងប្រទេសកម្ពុជា ។ ប្រជាជនទាំងនេះមករស់នៅជាមួយបងប្អូន ឬសាច់ញាតិដែលជាអតីតខ្មែរក្រហម និងមកប្រកបរបរធ្វើចម្ការ ដោយសារតំបន់នោះមានផ្ទៃដីធំទូលាយសម្រាប់ដាំដំណាំ និងមកធ្វើអាជីវកម្មរ៉ែមាស ហើយមួយចំនួនទៀត បានមកប្រកបរបរលក់ដូរនៅតាមទីប្រជុំជន ។



ប្រជាជននៅក្នុងឃុំភ្នំព្រឹក មកចូលរួមស្តាប់ការផ្សាយបន្តផ្ទាល់ពីការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី១ នៅវត្តគិរីរម្យសន្តិភាព ហៅ វត្តអូរចោទ

រហូតមកដល់សព្វថ្ងៃ ប្រជាជននៅក្នុងស្រុកនេះស្ទើរតែទាំងអស់ រួមទាំង អតីតខ្មែរក្រហម ដែលមួយចំនួនពិការដោយសារសង្គ្រាម បានប្រកបរបរធ្វើចម្ការដំឡូងមី ពោត សណ្ដែក និងដាំដំណាំហូបផ្លែផ្សេងៗ ហើយផលដែលបានមក ភាគច្រើនបានលក់ទៅឲ្យថៃ និងមានតិចតួចប៉ុណ្ណោះដែលលក់មកទីផ្សារក្នុងស្រុក ។ ប៉ុន្តែជារឿយៗ ផលដែលបានមកត្រូវឈ្មួញទម្លាក់តម្លៃថោកបណ្ដាលឲ្យខាតបង់ ទើបធ្វើឲ្យប្រជាជនមួយចំនួនបានចំណាកស្រុកទៅរកស៊ី និងធ្វើការនៅក្នុងប្រទេសថៃវិញ ។ លើសពីនេះ ប្រជាពលរដ្ឋមួយចំនួន រួមទាំង មន្ត្រីឃុំផ្ទាល់ បានបាត់បង់ដីចម្ការរបស់ខ្លួនដែលធ្លាប់ដាំដុះតាំងពីទសវត្សរ៍៨០ ដោយសារថៃយក ។ ទោះបីយ៉ាងណា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ យើងឃើញមានក្រុមហ៊ុនឯកជន ដូចជា ក្រុមហ៊ុនព្រៃសម្បទានដាំកៅស៊ូ ក្រុមហ៊ុនអភិវឌ្ឍផ្នែកកសិកម្ម និងក្រុមហ៊ុនជីកមាស បានចូលទៅបណ្ដាក់ទុនរកស៊ី ។ ការចូលទៅអភិវឌ្ឍន៍របស់ក្រុមហ៊ុនទាំងនោះ បានធ្វើឲ្យតំបន់ដែលធ្លាប់តែស្ងប់ស្ងាត់ និងវិន័យតឹងរឹង ជាមួយនឹងមនោគមវិជ្ជាកុម្មុយនីស្តជ្រាលជ្រៅ ប្រែទៅជាមានសភាពអ៊ូអរ និងមានមនុស្សកាន់តែច្រើន ។ ប៉ុន្តែការអភិវឌ្ឍខ្លះ បានធ្វើឲ្យប្រាសចាកទៅនឹងវិន័យរបស់ខ្មែរក្រហម ដូចជា ការរត់ពន្ធខុសច្បាប់ ការលេងល្បែងស៊ីសង ការប្រើប្រាស់គ្រឿងញៀន និងការរំលោភបំពានផ្សេងៗ ។

## ការជ្រើសទីតាំង

យើងបានជ្រើសរើសយក វត្តគិរីរម្យសន្តិភាព ហៅ វត្តអូរបោទ ធ្វើជាកន្លែងរៀបចំវេទិកាសាធារណៈ និងធ្វើការផ្សាយបន្តផ្ទាល់ពីការប្រកាសសាលក្រមសំណុំរឿង០០២ ដំណាក់កាលទី១ ។ បច្ចុប្បន្ន វត្តអូរបោទ មានព្រះសង្ឃចំនួន១០អង្គ គង់នៅ ។ វត្តនេះបានសាងសង់ឡើងនៅឆ្នាំ១៩៩៦ ក្រោយពេលខ្មែរក្រហមផ្ដាច់ខ្លួន ចុះចូលជាមួយរដ្ឋាភិបាល ។ វត្តនេះ បានសាងសង់ឡើងនៅលើដីរបស់អតីតមេបញ្ជាការរបស់ខ្មែរក្រហម ដោយបានដាក់ឈ្មោះវត្តនេះ យោងទៅតាមភូមិសាស្ត្រ និងសណ្ឋានដី ដែលមានអូរទឹក និងដីបោទ ស្ថិតក្នុងភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ។



សាលាឆាន់ វត្តគិរីរម្យសន្តិភាព ហៅ វត្តអូរបោទ ជាទីតាំងផ្សាយបន្តផ្ទាល់ពីការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទីមួយ

មូលហេតុយើងជ្រើសយកទីតាំងនេះ ដោយសារ ទី១) ជាអតីតតំបន់យុទ្ធសាស្ត្ររបស់ខ្មែរក្រហមក្នុងពេលធ្វើសង្គ្រាមប្រឆាំងនឹងរដ្ឋាភិបាលភ្នំពេញ កាលពីអំឡុងទសវត្សរ៍៨០ និង ៩០ ទី២) ជាកន្លែងដែលមេដឹកនាំខ្មែរក្រហមក្នុងតំបន់នោះរស់នៅ និង ទី៣) ជាកន្លែងដែលមិនសូវទទួលបានព័ត៌មានពីសាលាក្តីខ្មែរក្រហម ។

## សារសំខាន់ និងដំណើរកម្មវិធីនៃការផ្សាយបន្តផ្ទាល់ពីការប្រកាសសាលក្រម

ការផ្សាយបន្តផ្ទាល់នេះ មានសារសំខាន់ណាស់ ដើម្បីឲ្យប្រជាជន ក៏ដូចជា អតីតយោធា និង កម្មាភិបាលខ្មែរក្រហមបានទស្សនា ស្វែងយល់ពីដំណើរការរបស់សាលាក្តីខ្មែរក្រហម និងបំផុសឲ្យមានការពិភាក្សាក្នុងសហគមន៍របស់គាត់ ។ ជាពិសេសឲ្យក្មេងៗនៅក្នុងសហគមន៍ដែលគាត់រស់នៅបានដឹង ។

មុននឹងរៀបចំកម្មវិធីនេះ ដំបូងយើងបានធ្វើការទំនាក់ទំនងតាមទូរស័ព្ទជាមួយលោកមេឃុំ ម៉ែន សែប ដែលជាអតីតមេឃុំជំនាន់ខ្មែរក្រហម ដោយលោកណែនាំបន្តឲ្យទាក់ទងទៅលោកស្មៀនឃុំ ជិន ចាំ វិញ ។ ដោយមានកិច្ចសហការ និងការផ្តល់ព័ត៌មានបន្ថែមពីស្មៀនឃុំ យើងបានសម្រេចជ្រើសរើសយកវត្តអូរចោទ ធ្វើជាកន្លែងប្រជុំផ្សព្វផ្សាយ ។ ព្រមជាមួយគ្នានោះដែរ ដើម្បីបញ្ជាក់ឲ្យច្បាស់ពីសុវត្ថិភាព និងការធានាឲ្យមានការចូលរួមពីប្រជាជនក្នុងឃុំទាំងមូល នៅរយៈពេលពីរថ្ងៃមុនពេលការផ្សាយផ្ទាល់ពីការ ប្រកាសសាលក្រម នួន ជា និង ខៀវ សំផន យើងបានទូរស័ព្ទជម្រាបទៅប្រធានក្រុមប្រឹក្សាស្រុក និងអភិបាលស្រុកភ្នំព្រឹក ដោយបញ្ជាក់ពីលិខិតដែលក្រុមការងារទទួលបានការអនុញ្ញាតពីក្រសួងមហាផ្ទៃ និងសាលាខេត្តបាត់ដំបង ដើម្បីឲ្យលោកចាត់តាំងសមាជិកក្រុមប្រឹក្សាស្រុក និងឃុំដើម្បីអញ្ជើញប្រជាជន ។

នៅថ្ងៃបន្ទាប់ យើងបានទៅសាលាឃុំភ្នំព្រឹកដើម្បីជួបជាមួយលោកមេឃុំ ប៉ុន្តែគាត់មិនបានមកជួបដោយផ្ទាល់ទេ គឺគាត់ចាត់ឲ្យក្រុមប្រឹក្សាឃុំ ជា ភឿន និង មេភូមិទួលខ្ពស់ សួន ម៉ុត មកជួបជំនួស ។ បន្ទាប់ពីទទួលរបាយការណ៍ពីចំនួនគ្រួសារនៅក្នុងឃុំភ្នំព្រឹក ដែលសរុបទាំងអស់ ១.៣៧៨ គ្រួសារស្មើនឹង ៥៧៥៩ នាក់ ក្នុងនោះមាន ស្រីចំនួន២.៧០៧នាក់ រស់នៅក្នុងភូមិចំនួន៦ គឺ ភូមិគគីរ, ស្រឡៅ, ទួលខ្ពស់, បេងស្អាត, ភ្នំព្រឹក និង ភូមិអូរធំ រួចមកយើងក៏ផ្តើមពិភាក្សាពីដំណើរកម្មវិធីលម្អិតនៃការផ្សាយបន្តផ្ទាល់ដើម្បីជូនព័ត៌មានដល់ប្រជាជន ។ បន្ទាប់មក ក្រុមការងារយើង រួមជាមួយក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាស្រុក បានចុះទៅមើលពិនិត្យមើលទីតាំងវត្ត និងសុំការអនុញ្ញាតពីព្រះចៅអធិការវត្ត ។

នៅវេលាម៉ោង៧ព្រឹក ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ក្រុមការងាររបស់យើង បានទៅដល់វត្តគិរីរម្យសន្តិភាព ហៅ វត្តអូរចោទ ។ ក្រុមការងារយើងបានរៀបចំសៀវភៅទស្សនាវដ្តីស្វែងរកការពិត, សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ (១៩៧៥-៧៩) និងសៀវភៅស្តីពីអំពើប្រល័យពូជសាសន៍ សម្រាប់ចែកទៅអ្នកចូលរួម ។ បន្ទាប់មក យើងធ្វើការសាកល្បងទូរទស្សន៍ ភ្ជាប់ទៅនឹងឌីធីវី (DTV ជាឧបករណ៍សម្រាប់ចាប់យកប៉ុស្តិ៍ទូរទស្សន៍) និងឧគ្ឃោសនសព្ទ ដើម្បីឲ្យដំណើរការ ។ នៅវេលាម៉ោង៨ព្រឹក ទើបយើងសង្កេតឃើញក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ប៉ូលិស ទាហាន និង ប្រជាជនមួយចំនួនអញ្ជើញមកដល់ ។ ក្រុមការងារយើង រង់ចាំរហូតដល់ម៉ោងប្រមាណ ៨:៣០ ព្រឹក ទើបលោកជំទប់ទីពីឃុំភ្នំព្រឹក ជិន ខុម ជួយប្រកាសអញ្ជើញប្រជាជនឲ្យមកជុំគ្នា ។

នៅវេលាម៉ោង ៨ : ៤០ នាទីព្រឹក មានប្រជាជនប្រមាណ ២០០នាក់ ដោយមិនរាប់បញ្ចូល ក្មេងដែលមកជាមួយឪពុកម្តាយ បានមកដល់សាលាឆាន់វត្តគិរីរម្យសន្តិភាព ហៅ វត្តអូរចោទ ដែលជាកន្លែងរៀបចំផ្សាយបន្តផ្ទាល់ ។ បន្ទាប់មក ក្រុមការងារយើង រួមជាមួយ ក្រុមប្រឹក្សាឃុំ និងស្រុក បានចែកសៀវភៅដែលយើងរៀបចំទុកជាស្រេចដល់អ្នកចូលរួមទាំងអស់ និងបានចែកទឹកសុទ្ធនិងនំ ឲ្យគាត់បរិភោគ ។ ឆ្លៀតឱកាសនោះ ខ្ញុំក៏ឡើងនិយាយបញ្ជាក់ពីកម្មវិធីសម្រាប់ព្រឹកនេះ រួមមាន : ១) ការផ្សាយបន្តផ្ទាល់ពីការប្រកាសសាលក្រមក្នុងករណី០០២ដំណាក់កាលទីមួយ របស់ចៅក្រមសាលាដំបូង នៅវេលាម៉ោង៩ព្រឹក រួមទាំងការពន្យល់គ្រួសៗពីប្រវត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដំណើរការរបស់សាលាក្តីខ្មែរក្រហម ២) ការចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង "ក្បូនទឹកទន្លេ" និងការស្នើសុំឲ្យមានការគាំទ្រជាកម្លាំងចិត្តពីអ្នកចូលរួមទាំងអស់ ចំពោះការសង់វិទ្យាស្ថានស្លឹករឹត របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ប្រជាជនចាប់ផ្តើមសម្លឹងទៅទូរទស្សន៍ទាំងអស់គ្នា នៅពេលរូបភាពបង្ហាញពីចៅក្រមដែលកំពុងដើរចូលកន្លែងអង្គុយ ។ បន្ទាប់មក ចៅក្រម និល ណុន ចាប់ផ្តើមអាននូវសាលក្រមរបស់ជនជាប់ចោទ ។ អ្នកភូមិមួយ ចំនួនបានពិភាក្សាគ្នា និងរកនឹកឈ្មោះជនជាប់ចោទ នៅពេលទូរទស្សន៍ចាប់យករូបភាព នួន ជា និង ខៀវ សំផន ។ អ្នកខ្លះទៀត បានបង្ហាញពីអារម្មណ៍អាណិតអាសូរ ដោយសារតែឃើញមេដឹកនាំខ្មែរក្រហមទាំងនោះមានវ័យចំណាស់ ។ ដោយសារការអានមានរយៈពេលវែង និងមានពាក្យបច្ចេកទេសនៅក្នុងនោះ ទើបធ្វើឲ្យប្រជាជនខ្លះមិនសូវយល់ ហើយគាត់បានសួរគ្នា ។ អ្នកចូលរួមខ្លះដែលនាំកូនចៅមកជាមួយ ហើយដោយមិនអាចរង់ចាំរហូតដល់ចប់កម្មវិធីបាន ក៏ចាកចេញពីការប្រជុំ ហើយមួយចំនួនបានចាកចេញ ដោយសារមានការមមាញឹកនៅចម្ការ និងត្រូវទៅចម្អិនអាហារសម្រាប់គ្រួសារ ។ ទោះបីយ៉ាងណា អ្នកភូមិមួយចំនួន នៅអាចស្តាប់ឮនូវការប្រកាសសាលក្រមនោះ ដោយសារយើងបានចាក់ផ្សាយតាមរយៈឧគ្ឃោសនសព្ទនៅក្នុងវត្តទៀត ។ ការប្រកាសសាលក្រមបានបញ្ចប់ នៅវេលាម៉ោងប្រមាណជិត១១ថ្ងៃត្រង់ ដោយចៅក្រមអង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់ពន្ធនាគារជនជាប់ចោទអស់មួយជីវិត ។ ក្នុងឱកាសនោះ មានអ្នកចូលរួមម្នាក់ដែលបង្ហាញការមិនសូវពេញចិត្តនឹងសាលក្រមនេះ បានលើកឡើងនូវចម្ងល់ចំពោះកម្មាភិបាលផ្សេងទៀតដែលប្រព្រឹត្តការកាប់សម្លាប់ដោយផ្ទាល់ ហើយតុលាការមិនបានយកមកកាត់ទោស ។

## ប្រតិកម្មរបស់អ្នកភូមិ

**១) សួន ម៉ុត** ភេទប្រុស អាយុ៦៥ ឆ្នាំ ជាមេភូមិទួលខ្ពស់ មានប្រសាសន៍ថា សាលក្រមសម្រេចឲ្យ នួន ជា និង ខៀវ សំផន ជាប់គុកមួយជីវិត នឹងធ្វើឲ្យប្រជាជនកម្ពុជាបានស្ងប់ចិត្ត ហើយវាក៏មិនហួសហេតុពេកដែរ ។ ការកាត់ទោសនេះ ដើម្បីកុំឲ្យអ្នកដឹកនាំប្រព្រឹត្តកំហុស និងអំពើយង់ឃ្នងទៀត និងដើម្បីឲ្យក្មេងៗយល់ដឹងដែរ ។ ឪពុករបស់ ម៉ុត ត្រូវខ្មែរក្រហមចាប់យកទៅឃុំឃាំង នៅឆ្នាំ១៩៧៧ ដោយចោទថា ក្បត់ព្រោះធ្វើឲ្យដំរីដែលគាត់ថែរក្សា



ប្រជាជនសួរសំណួរទៅក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់ពីចៅក្រមប្រកាសសាលក្រមដាក់ទោស នួន ជា និង ខៀវ សំផន ជាប់គុកអស់មួយជីវិត

រួច ហើយដើរទៅស៊ីស្រូវរបស់អ្នកស្រុក ។ ឪពុករបស់គាត់បានស្លាប់នៅមន្ទីរសន្តិសុខមួយនៅក្នុងស្រុកឈូក ខេត្តកំពត ដោយសារតែអត់អាហារ ។ ម៉ុត ចង់បានយុត្តិធម៌សម្រាប់ឪពុករបស់គាត់ ។ ម៉ុតបន្តថា ការកាត់ទោសនេះមានសារប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាបានស្ងប់ចិត្ត ជាពិសេស ដើម្បីបកអាក្រាតកំហុសដែលខ្មែរក្រហមបានប្រព្រឹត្ត ។

**២) អ៊ឹក អ៊ី** ភេទប្រុស អាយុ៥៩ឆ្នាំ ជាភ្នាក់ងារបណ្តាញកាកបាទក្រហមស្រុកភ្នំព្រឹក រស់នៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានមានប្រសាសន៍ថា គាត់ឯកភាពជាមួយនឹងការសម្រេចរបស់តុលាការ ហើយការកាត់ទោសនេះមិនធ្ងន់ធ្ងរទេ សម្រាប់មេដឹកនាំខ្មែរក្រហម ព្រោះគ្រាន់តែឃុំឃាំងគាត់មិនឲ្យដើរហើរប៉ុណ្ណោះ មិនមែនកាប់សម្លាប់គាត់ទេ ។ ការកាត់ទោសសមនឹងទង្វើដែលខ្មែរក្រហមបានធ្វើ និងធ្វើឲ្យកំហឹងរបស់ប្រជាជនបានរសាយដែរ ។ គាត់ចង់ឲ្យក្មេងជំនាន់ក្រោយ បានចងចាំ រួមទាំងជនរងគ្រោះ និងជនដៃដល់ ហើយក៏អំពាវនាវឲ្យមានការថែរក្សាទុកនូវឯកសារទាំងអស់នេះដែរ ។ បងប្អូនជីដូនមួយរបស់ អ៊ី បានស្លាប់ដោយសារខ្មែរក្រហមចាប់យកទៅដាក់គុក ។

**៣) ធី សេម** ភេទស្រី អាយុ៥៧ឆ្នាំ ជាមេភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក និងជាអតីតប្រធានកងដែលដឹកនាំយុទ្ធនារី ៣០០នាក់នៅតាមបណ្តោយព្រំដែនថៃ បានមានប្រសាសន៍ថា គាត់ពេញចិត្តនឹងការកាត់ទោសនេះ ហើយបានបន្តថា យុត្តិធម៌បានផ្តល់ឲ្យរូបគាត់ ក៏ដូចជាអ្នកផ្សេងទៀតដែរ ។ គាត់ចង់ឲ្យក្មេងជំនាន់ក្រោយបានដឹងពីប្រវត្តិសាស្ត្រដ៏លំបាកនេះ ។ ចុងក្រោយ គាត់សំណូមពរឲ្យមានការជួយដល់សហគមន៍ផ្នែកសេវាសុខភាព និងឲ្យផលិតផលដំណាំដែលគាត់ដាំបាន លក់បានតម្លៃខ្ពស់ ។

**៤) សែម ពៅ** ភេទប្រុស មុខរបរធ្វើចម្ការ នៅភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានមានប្រសាសន៍ថា ការកាត់ទោសនេះត្រឹមត្រូវ មានយុត្តិធម៌ ព្រោះមេដឹកនាំខ្មែរក្រហមបានធ្វើបាបប្រជាជនរាប់ពាន់នាក់ ។ នួន ជា និង ខៀវ សំផន សមតែទទួលទោសនេះ ។ គាត់ពេញចិត្តទាំងស្រុងចំពោះការកាត់ទោសនេះ តែបើតាមចិត្តចង់ឲ្យដាក់ទោសប្រហារជីវិត ។ ចុងបញ្ចប់ គាត់បានលើកឡើងថា វាស៊ើរតែហួសពេលទៅហើយនៅពេលនេះ ។

**៥) នូ ប្រុស** ភេទប្រុស អាយុ៤៨ឆ្នាំ មុខរបរធ្វើចម្ការ រស់នៅភូមិបេងស្អាត ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានមានប្រសាសន៍ថា ការកាត់ទោសនេះត្រឹមត្រូវ ហើយគាត់ពេញចិត្តចំពោះការដាក់ទោសនេះ ។ ប្រុស បានបន្តថា គាត់បានស្ងប់ចិត្ត អស់ចិត្ត និងអស់កំហឹង ហើយគាត់ចង់ឲ្យក្មេងជំនាន់ក្រោយដឹងរឿងនេះ ។

**៦) ទេព វ៉ាត** ភេទស្រី អាយុ៧១ឆ្នាំ ធ្វើចម្ការ រស់នៅភូមិបេងស្អាត ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានមានប្រសាសន៍ថា ការដាក់ទោសនេះត្រឹមត្រូវ ហើយសមតែដាក់ទោសឲ្យធ្ងន់ធ្ងរជាងនេះ ។ គាត់គាំទ្រចំពោះការកាត់ទោសនេះ ។

**៧) អ៊ុច សូផាត** ភេទប្រុស អាយុ៦៦ឆ្នាំ ធ្វើចម្ការ រស់នៅភូមិបេងស្អាត ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានមានប្រសាសន៍ថា គាត់ឯកភាពតាមការប្រកាសរបស់តុលាការ ។ គាត់យល់ថា ការកាត់ទោសនេះត្រឹមត្រូវ ។ គាត់ពេញចិត្ត និងអស់សង្ស័យ ព្រោះបានបញ្ជាក់ពីការពិត និងបានផ្តល់យុត្តិធម៌ ហើយការឈឺចាប់របស់គាត់នឹងរសាយ ហើយនឹងគ្មានអ្វីដែលគាត់ត្រូវរំពឹងទៀតឡើយ ។

**៨) រ័ត្ន ហ៊ួ** ភេទប្រុស អាយុ៦៤ ជាគណៈកម្មាធិការវត្តអូរបោទ បានមានប្រសាសន៍ថា ការកាត់ទោសនេះត្រឹមត្រូវ ។ គាត់ពេញចិត្ត និងគាំទ្រចំពោះការកាត់ទោសនេះ ។ ការកាត់ទោសនេះ មានយុត្តិធម៌ នឹងធ្វើឲ្យគាត់ និងប្រជាជនអស់កំហឹង អស់ចិត្ត និងលែងគុំគួន ។

**សន្និដ្ឋាន**

ប្រជាជននៅឃុំភ្នំព្រឹក ជាង៩០ភាគរយ គឺជាអតីតខ្មែរក្រហម ។ ប្រជាជនភាគច្រើនបានគាំទ្រ ចំពោះកម្មវិធីផ្សាយបន្តផ្ទាល់នេះ ។ ប៉ុន្តែមានប្រជាជនភាគតិចប៉ុណ្ណោះ បានបង្ហាញការមិនសូវពេញចិត្តនឹងសាលក្រមនេះ ។ ប្រជាជនខ្លះទៀត បានបដិសេធមកចូលរួមនឹងកម្មវិធីផ្សាយបន្តផ្ទាល់នេះ ដោយលើកហេតុផលថា គាត់អាចមើលទូរទស្សន៍នៅផ្ទះរបស់គាត់ និងខ្លះទៀតថា វាមិនសមទេដែលយកមេដឹកនាំដែលមានវ័យចំណាស់ទៅហើយមកកាត់ទោស ។ ចំណែកអតីតកម្មាភិបាលខ្មែរក្រហមដែលមានតួនាទីនៅក្នុងអំឡុងពេលខ្លួនគ្រប់គ្រងអំណាច បានព្យាយាមលាក់បាំងនូវប្រវត្តិរបស់ខ្លួន ។ **សោម ប៊ុនថន**

# គម្រោងឃ្លាំមើលយុត្តិធម៌ : ការកសាងប្រជាធិបតេយ្យភាពក្នុងប្រទេសកម្ពុជាតាមរយៈការប្រកាសសាលក្រមសំណុំរឿង០០២ ដំណាក់កាលទី១

## សេចក្តីផ្តើម

នាថ្ងៃទី៧ ខែសីហា ឆ្នាំ ២០១៤ មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាត់តាំងក្រុមចំនួន២០ ទៅធ្វើការផ្សាយបន្តផ្ទាល់ពីការប្រកាសសាលក្រមនៃករណី០០២/០១ ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងគោលបំណងផ្សព្វផ្សាយដល់សហគមន៍ដែលពុំមានប្រព័ន្ធព័ត៌មានស្តីពីសាលក្រមនេះទៅដល់ ។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការផ្សាយបន្តផ្ទាល់នៅទីតាំងចំនួន២០កន្លែង ក្នុងខេត្តចំនួន១២ ក្នុងប្រទេសកម្ពុជា ។ ទីតាំងទាំងអស់នេះត្រូវបានជ្រើសរើស ដោយផ្អែកទៅលើគោលបំណងសំខាន់ៗចំនួនបីគឺ អតីតតំបន់របស់កម្មាភិបាលខ្មែរក្រហម សហគមន៍នៃជនជាតិភាគតិច និងសាសនា និងទីតាំងវប្បធម៌ ។

ប្រជាជនដែលបានអញ្ជើញមកពីទីតាំងទាំងនេះ មានការយល់ស្រប ដោយអតីតមេដឹកនាំខ្មែរក្រហមគឺ នួន ជា និង ខៀវ សំផន ដែលបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានសម្រេចដាក់ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការពន្យល់នូវដំណើរការដែលមានភាពស្មុគស្មាញនេះនូវរាល់ពេលដែលអ្នកចូលរួមមានចម្ងល់ ។ លើសពីនេះ ក្រុមការងារទាំងអស់ក៏បានជំរុញឲ្យមានកិច្ចពិភាក្សាអំពីការយល់ឃើញរបស់អ្នកចូលរួម ចំពោះការពិត និងយុត្តិធម៌ ។ កិច្ចប្រជុំនេះបានផ្តល់ឲ្យ មិនត្រឹមតែវេទិកាសម្រាប់ពិភាក្សាផ្ទាល់ និងការវិភាគវែកញែកប៉ុណ្ណោះទេ តែក៏បានបង្កឱកាសដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការប្រមូល និងកត់ត្រានូវប្រតិកម្ម ការយល់ឃើញ និងមតិរបស់អ្នកចូលរួមដែរ ។

## ដំណើរការរួមនៃការរៀបចំការផ្សាយបន្តផ្ទាល់

នៅក្នុងកិច្ចរៀបចំការផ្សព្វផ្សាយការប្រកាសសាលក្រមនៃករណី០០២/០១ដែលមានលក្ខណៈប្រវត្តិសាស្ត្រ គម្រោង "ឃ្លាំមើលយុត្តិធម៌" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសកម្មភាពជាច្រើន ដើម្បីផ្តល់នូវការផ្សព្វផ្សាយទៅដល់សាធារណជនទូទៅ ។ ទីតាំងចំនួនប្រាំមួយត្រូវបានជ្រើសរើសដើម្បីធ្វើជាតំណាងដល់តំបន់រដ្ឋបាលខ្មែរក្រហម ។ ទន្ទឹមនឹងនេះ ការផ្សាយបន្តផ្ទាល់នេះ គឺធ្វើឡើងនៅទូទាំងប្រទេស ។ យ៉ាងណាមិញ ដោយសារតំបន់ជាច្រើនមានការផ្គត់ផ្គង់នូវអ៊ីនធឺណេត និងទូរទស្សន៍ ការសម្រេចចិត្តចុងក្រោយ គឺផ្តោតលើអតីតតំបន់ដែលខ្មែរក្រហមគ្រប់គ្រង តំបន់នៃក្រុមជនជាតិភាគតិចរស់នៅ និងតំបន់វប្បធម៌ ។ ហេតុនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាត់តាំងក្រុម ចំនួន២០ ដើម្បីធ្វើការផ្សាយបន្តផ្ទាល់ ។ នៅក្នុងក្រុមនីមួយៗ មានបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមជាមួយនឹងនិស្សិតស្ម័គ្រចិត្ត... 

នៅរយៈពេលពីរសប្តាហ៍មុនការផ្សាយផ្ទាល់ មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានការអនុញ្ញាតពីអាជ្ញាធរទាំង១២ខេត្ត ដែលជាទីតាំងនៃការផ្សាយផ្ទាល់ ។ អាជ្ញាធរបានផ្តល់នូវការឆ្លើយតបជាវិជ្ជមាន ព្រមទាំងបន្តសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ក្រុមការងារធ្វើការយ៉ាងជិតស្និតជាមួយអាជ្ញាធរថ្នាក់ស្រុក ឃុំ និង ភូមិ ។ កិច្ចសហប្រតិបត្តិការដែលប្រព្រឹត្តតាមឋានានុក្រមរដ្ឋបាលនេះ បានជួយដល់ក្រុមនីមួយៗក្នុងការរៀបចំទីតាំងការផ្សាយបន្តផ្ទាល់ ការអញ្ជើញប្រជាជនមកចូលរួម ការរៀបចំឧបករណ៍ និងការងាររដ្ឋបាលដទៃទៀតដែលចាំបាច់សម្រាប់ការផ្សព្វផ្សាយ ។ ទោះជាយ៉ាងណាក្តី ឧបសគ្គនៅតែកើតមានក្នុងដំណើរការរៀបចំនេះ ។ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារ

កម្ពុជា ពុំសូវជាទទួលបានការស្វាគមន៍ទេនៅតាមទីតាំងខ្លះ ដែលជាតំបន់រងការប៉ះពាល់ដោយការកាប់បំផ្លាញព្រៃឈើ និងការរឹបអូសដីធ្លី ។ ក្រុមផ្សេងទៀត បានធ្វើការរាយការណ៍អំពីប្រតិកម្ម និងមិនស្វាគមន៍ពីអតីតសមាជិកខ្មែរក្រហម ដែលបង្ហាញការមិនពេញចិត្តចំពោះក្រុមការងារ ។

ក្រុមទាំងអស់បានពិភាក្សាគ្នាចំពោះជម្រើសនៃការប្រើប្រាស់បច្ចេកវិទ្យាដើម្បីធ្វើការផ្សព្វផ្សាយការប្រកាសសាលក្រមនេះ ។ ការផ្សាយបន្តផ្ទាល់ អាចនឹងធ្វើឡើងតាមរយៈស្ថានីយ៍ទូរទស្សន៍ក្នុងស្រុក ឬ ប្រសិនបើជម្រើសទីមួយមិនអាចសម្រេចបាន ការផ្សាយបន្តអាចប្រព្រឹត្តតាមរយៈបណ្តាញអ៊ីនធឺណេត ។ នៅរយៈពេលមួយសប្តាហ៍មុនការផ្សព្វផ្សាយបន្តផ្ទាល់ ទូរទស្សន៍ជាតិកម្ពុជា បានផ្តល់ដំណឹងថា នឹងធ្វើការផ្សាយផ្ទាល់ពីការប្រកាសសាលក្រមនេះ ។ បន្ទាប់មក ស្ថានីយទូរទស្សន៍ដទៃទៀតក៏ធ្វើយ៉ាងដូច្នេះដែរ ក្នុងនោះរួមមាន បណ្តាញទូរទស្សន៍ ស៊ីធីអ៊ិន ជាដើម ។ ហេតុនេះ ជម្រើសនៃការផ្សព្វផ្សាយតាមទូរទស្សន៍ គឺជាជម្រើសមួយដែលប្រសើរបំផុត ព្រោះការប្រើប្រាស់ប្រពន្ធអ៊ីនធឺណេតតាមតំបន់ ភាគច្រើនដែលបានជ្រើសរើសអាចនឹងមានភាពរអាក់រអួល ។

ក្រុមនីមួយៗចេញដំណើរពីរាជធានីភ្នំពេញ ទៅកាន់ទីតាំងគោលដៅរៀងៗខ្លួន នាថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៤ និងបានចំណាយពេលមួយថ្ងៃពេញ គឺថ្ងៃទី៦ ខែសីហា ដើម្បីរៀបចំឧបករណ៍ បញ្ចាំង ផ្ទាំងសំពត់ស និងឧបករណ៍បំពងសំឡេង ដោយមានជំនួយពីអ្នកបច្ចេកទេសក្នុងតំបន់ ។ ក្រុមនីមួយៗបានសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការជម្រាបដល់អ្នកភូមិឲ្យបានដឹងអំពីព្រឹត្តិការណ៍នេះ និងឆ្លៀតឱកាសធ្វើការសម្ភាសមុនពេលផ្សព្វផ្សាយ ។

ក្រុមមួយចំនួនបានជួបប្រទះនូវឧបសគ្គខ្លះ និងបានធ្វើការរាយការណ៍អំពីដំណើរការនៅក្នុងតំបន់របស់ខ្លួន ។ ដំបូងឡើយ ទឹកជំនន់បានធ្វើឲ្យមានការកែប្រែមួយចំនួនដល់គម្រោងដើម ។ នៅរយៈពេលពីរថ្ងៃមុនការផ្សព្វផ្សាយ មានក្រុមចំនួនពីរ ដែលត្រូវចាត់តាំងឲ្យទៅស្រុកវើនសៃ និង ស្រុកអណ្តូងមាស នៃខេត្តរតនគិរី បានទទួលការរាយការណ៍អំពីទឹកជំនន់ធ្ងន់ធ្ងរដែលបង្កឲ្យមានការដាច់ផ្លូវ និងស្ពាន ។ លើសពីនេះទៅទៀត ភ្លៀងធំៗបានបង្ហាញសញ្ញាណដែលពុំមានភាពធូរស្រាលឡើយ ។ ជាលទ្ធផល ក្រុមទាំងពីរក៏សម្រេចចុះទៅបំពេញការងារនៅស្រុកកូនមុំ និងស្រុកអូរជុំវិញ ។ ទន្ទឹមនឹងនេះ ក្រុមដែលបានចាត់តាំងទៅកាន់ខេត្តត្បូងឃ្មុំ ក៏បានទទួលនូវការរាយការណ៍អំពីទឹកជំនន់កើនឡើង ដែលពុំអាចធ្វើការផ្សាយបន្តផ្ទាល់បាន ។ ក្រុមនេះក៏បានធ្វើការទាក់ទងទៅកាន់ស្រុកកងមាស នៃខេត្តកំពង់ចាម ជាទីតាំងដែលជនជាតិចាមភាគច្រើនរស់នៅ ក៏ប៉ុន្តែទីនោះក៏មានទឹកជំនន់ទៅដល់ក្នុងរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ។ ក្រុមនេះក៏សម្រេចទៅបំពេញការងារនៅស្រុករកាពរ៥ នៃខេត្តត្បូងឃ្មុំវិញ ។

## ក្រុមនៅខេត្តត្បូងឃ្មុំបានសរសេរថា៖

ក្រុមនៅខេត្តត្បូងឃ្មុំជួបប្រទះឧបសគ្គជាច្រើន ។ ដំបូង ក្រុមនេះមានគម្រោងធ្វើការផ្សព្វផ្សាយ នៅស្រុកក្រូចឆ្មារដែលនៅតាមបណ្តោយទន្លេមេគង្គ ។ ក៏ប៉ុន្តែធម្មជាតិឆ្នាំនេះ បានរៀបចំគម្រោងផ្សេងឲ្យក្រុមនេះ ។ ភ្លៀងធ្លាក់ជោគជាំខុសប្រក្រតីនៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងភាគខាងជើងប្រទេសឡាវ ។ នាដើមខែសីហា កម្ពស់ទឹកទន្លេមេគង្គបានឡើងដល់២៧ម៉ែត្រ ហើយបានឡើងលិចច្រាំងទន្លេ ។ នៅថ្ងៃទី៤ ខែសីហា ប្រធានភូមិស្វាយឃ្លាំងបានជម្រាបដល់ក្រុមការងារយើងថា ទីតាំងនៃការផ្សាយបន្តផ្ទាល់ មានភាពលិចលង់ដែលបង្កឲ្យមានការលំបាកក្នុងការដំឡើងម៉ាស៊ីនភ្លើង សម្រាប់ឧបករណ៍បញ្ចាំង ក៏ប៉ុន្តែការផ្សាយបន្តផ្ទាល់នៅតែអាចប្រព្រឹត្តទៅបាន ។ ក្រុមការងារយើងបានចេញដំណើរទៅកាន់ភូមិនោះ នៅថ្ងៃទី៥ ខែសីហា ដើម្បីសម្រេចថា យើងអាចធ្វើការផ្សព្វផ្សាយបើទោះជាមានទឹកជំនន់ ឬយ៉ាងណា ។ ប្រសិនកម្រិតទឹកមិនឡើងខ្លាំង ហើយមានជម្រៅត្រឹមកន្លះម៉ែត្រនៅជុំវិញវត្ត នោះការផ្សព្វផ្សាយបន្តនៅតែអាចប្រព្រឹត្តិទៅបាន ។ នៅថ្ងៃទី៥ ខែសីហា ចំណែកផ្លូវខ្លះបានលិច ហើយទឹកហូរកាត់តាមបណ្តោយ

*ដងផ្លូវ ក៏ប៉ុន្តែរថយន្តអាចធ្វើការឆ្លងកាត់បាន ។ អ្នកភូមិចាប់ផ្តើមដេញគោក្របីរបស់ខ្លួនឡើងលើផ្លូវ ដែលជាទីតាំងខ្ពស់ជាងគេក្នុងភូមិ ។ ក្រុមយើងបានមកដល់ភូមិស្វាយឃ្លាំង ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ជាទីតាំងដែលបានកំណត់ទុកសម្រាប់ការផ្សាយបន្តផ្ទាល់ នៅថ្ងៃទី៥ ខែសីហា ។ ក្រុមនេះដឹងថា ទឹកបានឡើងដល់កម្ពស់មួយម៉ែត្រនៅជុំវិញវត្ត ហើយបន្តហូរពីចំណុចប្រសព្វទន្លេមេគង្គ ។ លំហូរទឹកបានបង្កជាសំឡេងរំខាន ហើយមានគ្រោះថ្នាក់ខ្លាំងក្នុងការឆ្លងកាត់ ។ លើសពីនេះ ក្រុមការងារពុំបានទទួលឯកសារឆ្លើយតប ដែលបានផ្ញើទៅកាន់ភូមិកាលពីប៉ុន្មានថ្ងៃមុននេះទេ ព្រោះផ្ទះដែលទុកឯកសារនោះ មានទឹកជ្រៅនៅព័ទ្ធជុំវិញ ។ ក្រុមនេះមាននៅសល់តែទស្សនាវដ្តី និងសៀវភៅអង្គេតការណ៍ចំនួន២០០ក្បាលប៉ុណ្ណោះ ។ ដោយព្រួយបារម្ភថា ទឹកអាចនឹងបន្តឡើង ក្រុមការងារបានធ្វើដំណើរមកកាន់ខេត្តកំពង់ចាមទាំងយប់ នៅថ្ងៃបន្ទាប់ ។ ការធ្វើដំណើរលើដងផ្លូវ ស្ទើរតែមិនអាចប្រព្រឹត្តទៅបាន ។ ក្រុមការងារបានធ្វើការទាក់ទងទៅមេឃុំរកាពរ៤ភ្លាមៗ ដើម្បីឲ្យគាត់មានពេលគ្រប់គ្រាន់ក្នុងការជម្រាបប្រជាជនរកទីតាំងសមស្របសម្រាប់ការផ្សាយបន្តផ្ទាល់ និងអាចឲ្យយើងរៀបចំដំឡើងឧបករណ៍ ។ ជំនួសឲ្យឧបសគ្គ និងរយៈពេលរៀបចំខ្លី យើងអាចរកបានទីតាំងសមស្របនៅក្នុងឃុំ ដើម្បីបំពេញការងារ ។*

ចំណែកឯទីតាំងដទៃទៀត ចំនួនអ្នកចូលរួមបានកាត់បន្ថយដោយសារភ្លៀងធំ ។ ក្រុមនៅខេត្តប៉ៃលិនបានកត់សម្គាល់ថា វត្តមាននៃអ្នកចូលរួមមានតិចជាង៧០នាក់ ដោយសារភ្លៀងជោគជាំ ។ អ្នកចូលដែលជាជនជាតិភាគតិចរស់នៅតំបន់ភ្នំភាគច្រើនរួមមាន ព្នង គ្រឹង ទំពួន មានភាពលំបាកក្នុងការយល់អំពីការប្រកាសសាលក្រមនេះ ។ ទោះបីជាយ៉ាងណាក្តី ក្រុមការងារបានជួយពន្យល់ដល់គាត់ អំពីសាលក្រមនេះ ព្រមទាំងប្រមូលបាននូវប្រតិកម្មរបស់អ្នកចូលរួមមួយចំនួនទៀតផង ។

**សាលក្រមករណី០០២/០១**

អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជាបានរកឃើញថា នួន ជា និង ខៀវ សំផន មានទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តិឡើងនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ខែធ្នូឆ្នាំ១៩៧៨ និងត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារមួយជីវិត ។ អង្គជំនុំជម្រះក៏បានរកឃើញថា ជនជាប់ចោទទាំងពីររូបបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ដោយបានអនុវត្តនូវបដិវត្តន៍សង្គមនិយមក្នុងទ្រង់ទ្រាយធំ ។ សាលក្រមនេះ រួមបញ្ចូលនូវបទចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបីដំណាក់កាលរួមមាន ដំណាក់កាលទី១) ការជម្លៀសដោយបង្ខំដំណាក់កាលទី២) ការជម្លៀសដោយបង្ខំ និងប្រតិបត្តិការនៅទួលពោធិ៍ជ្រៃ ។ ចំពោះការជម្លៀសដោយបង្ខំក្នុងដំណាក់កាលទី១ ជនជាប់ចោទត្រូវបានរកឃើញថា មានទោសពីបទឃាតកម្ម ធ្វើទុក្ខបុកម្នេញផ្នែកនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត ដូចជា ការជម្លៀសដោយបង្ខំ និងការរំលោភដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស ។ ចំពោះការជម្លៀសដោយបង្ខំដំណាក់កាលទី២ ជនជាប់ចោទត្រូវបានរកឃើញថា មានទោសពីបទធ្វើទុក្ខបុកម្នេញផ្នែកនយោបាយការជម្លៀសដោយបង្ខំ និងរំលោភបំពានដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ។ តុលាការក៏បានរកឃើញថា នួន ជា និង ខៀវ សំផន មានគម្រោងញុះញង់ ផ្តល់ជំនួយ និងផ្សំគំនិតចំពោះ ១) ការកាប់សម្លាប់ដែលកើតឡើងក្នុងអំឡុងពេលជម្លៀសដោយបង្ខំទាំងពីរលើក និង ២) ការបង្ខំឲ្យមានការបាត់ខ្លួនក្នុងអំឡុងពេលជម្លៀសប្រជាជនក្នុងដំណាក់កាលទីពី ។ ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ ជនជាប់ចោទ ត្រូវបានរកឃើញថា មានទោសពីបទ ឃាតកម្ម ការកាប់សម្លាប់ និងធ្វើទុក្ខបុកម្នេញផ្នែកនយោបាយចំពោះមន្ត្រីរាជការសម័យសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ ។ ជាពិសេស អង្គជំនុំជម្រះបានរកឃើញថា នួន ជា ជាអ្នកទទួលខុសត្រូវលើការបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ព្រោះគាត់ជាសមាជិកពេញសិទ្ធិនៃបក្សកម្មុយនីស្តកម្ពុជាក្នុងការ សម្រេច ហើយពេលខ្លះ គាត់មានតួនាទីជានាយករដ្ឋមន្ត្រីស្តីទី នៅពេល ប៉ុល ពត អវត្តមាន ។ ហេតុនេះ នួន ជា ត្រូវបានចាត់ទុកថា ជាអ្នកទទួលខុសត្រូវខ្ពស់លើឧក្រិដ្ឋ

កម្មទាំងអស់ដែលបានប្រព្រឹត្ត រួមមាន ការជម្លៀសដោយបង្ខំ និង ខុក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅទួលពោធិ៍ជ្រៃ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានពិចារណាលើកត្តាជាច្រើនក្នុងការកាត់ទោសជនជាប់ចោទទាំងពីរ ។ តុលាការបានពិចារណាពីទម្ងន់នៃឧក្រិដ្ឋកម្ម ទីតាំងភូមិសាស្ត្រនៃឧក្រិដ្ឋកម្ម កាលៈទេសៈនៃឧក្រិដ្ឋកម្ម និងផលប៉ះពាល់ដែលបង្កឡើងដោយឧក្រិដ្ឋកម្មចំពោះជនរងគ្រោះ គ្រួសាររបស់ជនរងគ្រោះ និងប្រជាជនកម្ពុជាទូទៅ ។ តុលាការបានរកឃើញនូវកត្តាដែលមានភាពធ្ងន់ធ្ងរជាច្រើន ដែលជំរុញឲ្យកម្រិតនៃការកាត់ទោសកាន់តែមានប្រសិទ្ធភាព ហើយមានស្ថានភាពធូរស្រាលតិចតួចប៉ុណ្ណោះដែលបន្ធូរបន្ថយកម្រិតនៃការដាក់ទោស ។ កត្តាធ្ងន់ធ្ងរមួយចំនួនរួមមាន កម្រិតខ្ពស់នៃការអប់រំដែលជនជាប់ចោទបានទទួល ការប្រើប្រាស់អំណាចរំលោភច្បាប់របស់ជនជាប់ចោទ និងផលប៉ះពាល់ដែលជនរងគ្រោះទទួលរង ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលស្គាល់នូវលទ្ធផលឧក្រិដ្ឋកម្មរបស់ជនជាប់ចោទក្នុងករណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាការឈឺចាប់ដ៏ធំធេងរបស់អ្នករស់រាន និងការដាក់ចេញនូវសំណង ។ តុលាការបានយល់ស្របចំពោះសំណង ចំនួន១១គម្រោង (ក្នុងចំណោម១៣ គម្រោង) រួមមាន៖ គម្រោងថៃរំឭកថ្នាក់ជាតិ ការសាងសង់ស្តូបនៅភ្នំពេញ ដើម្បីគោរពដល់ជនរងគ្រោះពីការជម្លៀសដោយបង្ខំ គម្រោងព្យាបាលក្រុមជួយខ្លួនឯង ការតាំងពិពណ៌អចិន្ត្រៃយ៍ គម្រោងតាំងពិពណ៌ចល័ត និងការអប់រំ ការដាក់បញ្ចូលជំពូកមួយស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងកាប់សម្លាប់នៅទួលពោធិ៍ជ្រៃទៅក្នុងកម្មវិធីសិក្សាក្នុងសាលារៀនកម្ពុជា ការកសាងមជ្ឈមណ្ឌល សិក្សាសន្តិភាព សៀវភៅស្តីពីការវិនិច្ឆ័យការពិត និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ការបោះពុម្ពផ្សាយសាលក្រមក្នុងករណី ០០២/០១ និងការដាក់បញ្ចូលឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួម ចូលទៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅពេលដែលការកាត់ទោសបញ្ជាក់ថា ជនជាប់ចោទបានចូលរួមក្នុងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដែលបានបង្កឡើងនាចុងសតវត្សរ៍ទី២០ ដោយសារតែការបញ្ចប់នូវការកាត់ក្តីសាលក្រមមានលក្ខណៈចង្អៀត ។ សាលក្រមធ្វើការរួមបញ្ចូលនូវទារុណកម្មរបស់ខ្មែរក្រហមច្រើនទម្រង់ ដូចជា ការងារសហករណ៍ ការបង្អត់អាហារ និងការរៀបការដោយបង្ខំ ។ សវនាការដំណាក់កាលទីពីរនឹងត្រូវស៊ើបអង្កេតទៅលើទោសដទៃទៀតដែលរួមមានបទឧក្រិដ្ឋប្រល័យពូជសាសន៍ជាដើម ។

អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ភាគីពាក់ព័ន្ធទាំងអស់មានសិទ្ធិក្នុងការតវ៉ាពីការសម្រេច ។ ជនជាប់ចោទអាចនឹងធ្វើការតវ៉ាពីទោស ការដាក់ពន្ធនាគារមួយជីវិត ដែលគាត់ទទួល ក៏ប៉ុន្តែការកាត់ទោសនោះ ព្រះរាជអាជ្ញាក៏អាចធ្វើការតវ៉ាចំពោះផ្នែកច្បាប់មួយចំនួននៃការសម្រេចនេះ ។ ទោះជាយ៉ាងណា ដោយសារតែភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានលើកឡើង ជនជាប់ចោទនឹងត្រូវឃុំឃាំងដដែល នៅក្នុងអំឡុងពេលសវនាការនៃការតវ៉ា ។

ជារួម ការសម្រេចកាត់ទោសនេះ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់កម្ពុជា ។ ការសម្រេចកាត់ទោសនេះមិនត្រឹមតែនាំមកនូវការធូរស្បើយដល់អ្នករស់រានជាច្រើននោះទេ តែក៏បានបង្ហាញនូវសមត្ថភាពរបស់តុលាការកូនកាត់នេះ ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងការផ្តល់នូវសវនាការមួយដែលមានយុត្តិធម៌ដោយដំណើរការប្រកបតាមបទដ្ឋាន ។

## ការយល់ឃើញចំពោះពាក្យយុត្តិធម៌របស់ប្រជាជន

ពាក្យថា «យុត្តិធម៌» មានទំហំធំធេង ដែលរួមមានអត្ថន័យផ្សេងគ្នាចំពោះអ្នករស់រាន ។ បើទោះជាសាលក្រមនឹងមិនសុទ្ធតែមានភាពយុត្តិធម៌ ក៏ប៉ុន្តែ អ្នកដែលបានចូលរួមក្នុងការផ្សាយបន្តផ្ទាល់ភាគច្រើនជឿជាក់ថា សាលក្រម និងការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជាជំហានមួយឆ្ពោះទៅកាន់យុត្តិធម៌ និងការផ្សះផ្សា ។ អ្នកចូលរួមមួយរូបគឺ រិក ញូយ អាយុ៤៨ឆ្នាំ មកពីខេត្តរតនគិរី បានលើកឡើងថា «សាលក្រមអាចបង្ហាញឲ្យឃើញថា ប្រទេសយើងមានច្បាប់ ដែលអាចនាំមកនូវភាពយុត្តិធម៌ដល់ប្រជាពលរដ្ឋ» ។ ក៏ប៉ុន្តែ យុត្តិធម៌ដែលមនុស្សភាគច្រើនយល់ឃើញ គឺលើសពីសាលក្រមនេះ ។ អ្នកឆ្លើយតបមួយចំនួនយល់ថា តុលាការមិនអាចផ្តល់នូវយុត្តិធម៌បានទេ ព្រោះការឈឺចាប់ដែលគាត់ទទួលរងមានទំហំធំធេងដែលនឹងមិនអាចទូទាត់តាមរយៈដំណើរការស្វែង

រកយុត្តិធម៌ ឬ ប្រព័ន្ធដោះស្រាយបាននោះទេ ។ អ្នកផ្សេងទៀតយល់ថា ការផ្តល់នូវយុត្តិធម៌អាចនឹងត្រូវពន្យា ដោយដំណើរការនៃតុលាការ ហើយយល់ថា អ្វីដែលសាលក្រមផ្តល់ឲ្យ អាចនឹងតិចតួច ឬអាចនឹងហួសពេល ។

## យុត្តិធម៌ ៖ សាលក្រម និងការកាត់ទោស

សរុបមក សាលក្រមដែលបង្ហាញពីទោសនេះ ត្រូវបានគាំទ្រ និងទទួលយកជាទូទៅ ដោយអ្នកចូលរួមក្នុងការផ្សាយបន្តផ្ទាល់ ។ ចំពោះអ្នកចូលរួមភាគច្រើន សាលក្រមបានបញ្ជាក់ដោយភាពយុត្តិធម៌ ឬ "កម្មពៀរ" ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ។ នៅពេលដែលអ្នកខ្លះជឿជាក់ថា សាលក្រម និងការកាត់ទោសមានភាពគ្រប់គ្រាន់ មានអ្នកដទៃជាច្រើនទៀតយល់ថា បើទោះជាសាលក្រម មានភាពចាំបាច់ក្នុងការដាក់ចេញនូវយុត្តិធម៌ ក៏ប៉ុន្តែវាមិនគ្រប់គ្រាន់នោះទេចំពោះភាពយុត្តិធម៌ ។ ក្រៅពីការពេញចិត្តជារួមចំពោះសាលក្រម អ្នកឆ្លើយតបមួយភាគធំយល់ថា ការឈឺចាប់របស់គាត់ ទាំងអតីតកាល និងបច្ចុប្បន្ន គឺមានភាពធ្ងន់ធ្ងរ ទោះជាសាលក្រម ឬការកាត់ទោសអាចទូទាត់ចំពោះការបាត់បង់ដែលគាត់ទទួលរង ។

បើទោះជា ពុំមានអ្នកចូលរួមបង្ហាញនូវការមិនពេញចិត្តទាំងស្រុងចំពោះសាលក្រម ក៏ប៉ុន្តែមានអ្នកភូមិមួយចំនួនមានភាពមន្ទិលចំពោះការសម្រេចរបស់តុលាការ ។ អ្នកចូលរួមភាគច្រើនបង្ហាញពីការពេញចិត្ត ដែលជនដៃដល់ត្រូវបានកាត់ទោសដាក់ពន្ធនាគារមួយជីវិត ដែលជាទោសធំបំផុតរបស់តុលាការ ។ អ្នកឆ្លើយតបមួយចំនួនយល់ថា ការដាក់ពន្ធនាគារមួយជីវិតគឺមិនធ្ងន់ធ្ងរគ្រប់គ្រាន់នោះទេ ហើយចង់ឃើញមេដឹកនាំខ្មែរក្រហមត្រូវដាក់ទោសប្រហារជីវិតដោយភ្ជួរក ឬចាក់សម្លាប់ ។ អ្នកចូលរួមមួយចំនួនមានមន្ទិលចំពោះយុត្តិធម៌លើការគាំពារដែលជនដៃដល់ទទួលបានដែលខុសពីគាត់ជាប់គុក ឬត្រូវឃុំឃាំង ហើយយល់ថា សិទ្ធិមនុស្ស និងលក្ខខណ្ឌរស់នៅដែលផ្តល់ដល់មេដឹកនាំខ្មែរក្រហមគឺមិនស្មើភាពចំពោះការវាយដំ បង្អត់អាហារ និងការរំលោភបំពានសិទ្ធិមនុស្សដែលគាត់បានធ្វើទៅកាន់ជនរងគ្រោះនោះទេ ។ ក៏ប៉ុន្តែការយល់ឃើញបែបនេះ មិនសុទ្ធសឹងត្រូវបានលើកឡើងដោយអ្នកចូលរួមទាំងអស់ឡើយ ។ ឡាយ សាន អាយុ៥១ឆ្នាំ មកពីកោះកែរ បានលើកឡើងថា "ការកាត់ទោសឲ្យស្លាប់មិនអាចនាំមកនូវអ្វីដែលយើងបាត់បង់ទេ" ។ គាត់យល់ឃើញទៀតថា ការសងសឹក គឺពុំមែនជាដំណោះស្រាយនោះទេ ព្រោះ "ការសងសឹកនឹងមិនបញ្ចប់ឡើយ" ។

អ្នកចូលរួមមួយចំនួនដែលមកពីអន្លង់វែង និងធ្លាប់ជាអតីតកម្មាភិបាលខ្មែរក្រហមយល់ថា មេដឹកនាំខ្មែរក្រហមគួរតែត្រូវលើកលែងទោសដោយសារគាត់មានមានវ័យចំណាស់ ។ ដោយសារការផ្តល់ឲ្យនូវយុត្តិធម៌ហាក់ដូចជាមានភាពយឺតយ៉ាវចំពោះអ្នករស់រាន និងដោយសារវ័យ និងស្ថានភាពសុខភាពទ្រុឌទ្រោមរបស់ជនដៃដល់ វាពុំមានភ្ញាក់ផ្អើលទេដែលការដាក់ទោសមួយជីវិតរបស់ ខៀវ សំផន និង នួន ជា ពុំបាននាំមកនូវការពេញចិត្តដល់អ្នករស់រានទាំងអស់ ។ អ្នករស់រានមួយរូប គឺ កញ្ញា ច័ន្ទ ធីតា ដែលបានចូលរួមក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រំពឹងថា នឹងមានការដាក់ពន្ធនាគាររយៈពេល១០០ឆ្នាំ ។ គាត់បានពន្យល់ថា ការដាក់ទោសមួយជីវិត ដល់ជនដៃដល់គឺនៅសល់តែរយៈពេលខ្លីប៉ុណ្ណោះ ក្រោយមកគាត់នឹងរួចផុតពីទោស ។ ផ្ទុយទៅវិញ ការដាក់ពន្ធនាគារ១០០ឆ្នាំនឹងបន្តចំពោះជនដៃដល់ដល់ជាតិក្រោយ ។

## ការស្វែងរកការពិត

ការយល់ឃើញរបស់អ្នកចូលរួមចំពោះការពិតដែលអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា ផ្តល់ឲ្យនោះគឺសាលក្រមមានភាពខុសប្លែកពីគ្នា ។ អ្នកចូលរួមភាគច្រើនយល់ថា ដំណើរការនេះអាច ឲ្យគេយល់ដឹងអំពីឧក្រិដ្ឋកម្មដែល ខៀវ សំផន និង នួន ជា បានប្រព្រឹត្ត ។ ដោយសារអ្នកឆ្លើយតបភាគច្រើនបាននិយាយថា គាត់មិនបានដឹងនូវអ្វីដែលកើតឡើងនៅក្រៅសហគមន៍របស់គាត់ទេ កាលពីជំនាន់នោះ និងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ ។ គាត់មានចំណាប់អារម្មណ៍ក្នុងការយល់ដឹងបន្ថែមឲ្យបានស៊ីជម្រៅទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម និងការចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនោះ ដោយជនរងគ្រោះ តាមរយៈដំណើរការកាត់ទោសនេះ ក៏ដូចជា តាមរយៈគម្រោងចុះផ្ទាល់ទៅមូលដ្ឋាននេះដែលផ្តល់នូវការយល់ដឹង និងពន្យល់ឲ្យបានកាន់តែច្បាស់ចំពោះដំណើរការនេះ ។ យ៉ាងណាមិញ អ្នកចូលរួមភាគច្រើនរំពឹងថា ខៀវ សំផន និង នួន ជា

ប្រឈមនឹងភាពយុត្តិធម៌ និងរំពឹងនូវការសារភាពពីទោសកំហុស និងការពន្យល់ដោយផ្ទាល់ពីសំណាក់ជនរងគ្រោះ ។ អ្នកចូលមួយភាគធំមិនរំពឹងថា នឹងមានសវនាការទៀតទេ ហើយមានអ្នកខ្លះទៀតយល់ថា ដំណើរការនៃសវនការមានរយៈពេលវែងពេក អ្នកដទៃទៀតដែលជាអតីតកម្មាភិបាលខ្មែរក្រហមភ័យខ្លាចថា គេក៏នឹងត្រូវកាត់ទោស ។ ក៏ប៉ុន្តែមានអ្នកចូលរួមមួយភាគតូចស្នើឲ្យមានការស៊ើបអង្កេតបន្ត ដោយយល់ថា មិនត្រឹមតែកម្មាភិបាលថ្នាក់ក្រោមទេ ក៏ប៉ុន្តែក៏មានបុគ្គល ឬប្រទេសដ៏ទៃទៀតដែលចូលរួមឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

លើសពីនេះ អ្នកចូលរួមមួយចំនួនលើកឡើងថា ការតម្កល់ឯកសារមានសារសំខាន់ណាស់ ក្នុងការធ្វើជាភ័ស្តុតាងសម្រាប់ដំណើរការ និងកត់ត្រានូវដំណើរការ ។ គាត់ជឿជាក់ថា វាមានសំខាន់ណាស់ក្នុងការបង្ហាញការពិត និងបញ្ជាក់ពីបទពិសោធឈឺចាប់របស់គាត់ដែលបានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអប់រំកូនចៅជំនាន់ក្រោយដែលពុំជឿថាមានរឿងរ៉ាវនោះបានកើតឡើងពិតមែន ។

## សំណងលើភាពយុត្តិធម៌

អ្នកចូលរួមមួយចំនួនពុំបានយល់ដឹងថា សំណងជាអ្វីនោះទេ នេះគឺដោយសារតែតុលាការមិនបានធ្វើការពន្យល់ឲ្យបានពិស្តារអំពីគម្រោងសំណង ក្នុងអំឡុងពេលផ្សព្វផ្សាយសាលក្រមរបស់ខ្លួន ។ ក៏ប៉ុន្តែ អ្នកចូលរួមភាគច្រើនបានយល់ដឹងអំពីអត្ថន័យនៃពាក្យនេះ គាត់ក៏បានលើកឡើងពីប្រភេទសំណងមួយចំនួនដែលគាត់ចង់បាន ក្នុងនោះរួមមាន ផ្លូវថ្នល់ មជ្ឈមណ្ឌលសាសនា ស្តូបបូជនីយស្ថាន មន្ទីរពេទ្យ ទឹកស្អាត ការបោះពុម្ពផ្សាយនូវដំណើរការនៃការកាត់ទោស ការសុំទោសជាសាធារណៈ និងការសាងសង់សាលារៀន ។

អ្នកចូលរួមភាគច្រើនបានបង្ហាញឲ្យឃើញពីការរំពឹងយ៉ាងមុតមាំក្នុងការអប់រំក្មេងជំនាន់ក្រោយឲ្យបានដឹងអំពីរបបខ្មែរក្រហមជាពិសេស រារាំងការកើតមានម្តងទៀតនូវរបបនេះ ។ អ្នកចូលរួមខ្លះ ស្នើឲ្យមានសាលារៀនមានភាពប្រសើរឡើង តាមរយៈការដាក់បញ្ចូលនូវការអប់រំពីរបបប្រល័យពូជសាសន៍ ចំណែកឯអ្នកចូលរួមខ្លះទៀត ស្នើឲ្យមានកំណែទម្រង់ប្រព័ន្ធច្បាប់ និងការគ្រប់គ្រងដើម្បីរារាំងអំពើឃោរឃៅរបស់ខ្មែរក្រហមកើតឡើងទៀត ។ ការយល់ឃើញរបស់អ្នកចូលរួមភាគច្រើនទាក់ទងនឹងសំណង គឺការរារាំងវត្តមាននៃរបបនេះម្តងទៀត ។

បើទោះជាពុំមានការលើកឡើងក្នុងទម្រង់របស់សំណង អ្នកចូលរួមភាគច្រើនលើកឡើងពីការសុំទោសជាសាធារណៈ នៅរាល់ពេលគាត់ត្រូវបានសួរពីដំណើរការនេះ ។ អ្នកចូលរួមជាច្រើនរំពឹងថា សវនាការនេះអាចឲ្យ ខៀវ សំផន និង នួន ជា ធ្វើការសារភាពកំហុសរបស់ខ្លួនជាសាធារណៈ និងសុំការអធ្យាស្រ័យ ក៏ប៉ុន្តែអ្វីទាំងនេះពុំបានកើតឡើងឡើយ ។ អ្នកចូលរួមម្នាក់គឺ លោក ឡាច យឿន អាយុ៦៩ឆ្នាំ មកពីកោះកែរ ចង់ឲ្យមានការដឹងជាសាធារណៈនៃបទពិសោធរបស់អ្នករស់រានពីរបបខ្មែរក្រហម ដោយជឿជាក់ថា សវនាការនេះអាចឲ្យមានការយកចិត្តទុកដាក់ជាសកលទៅលើមេដឹកនាំខ្មែរក្រហម នៅពេលដែលប្រជាជនកម្ពុជាដែលរងទុក្ខ និងស្លាប់យ៉ាងព្រៃផ្សៃក្នុងរបបខ្មែរក្រហមពុំទទួលបានការយកចិត្តទុកដាក់ ឬផ្តល់កិត្តិយសឲ្យឡើយ ។

មានតែអ្នកឆ្លើយតបមួយចំនួនតូចប៉ុណ្ណោះ ដែលស្នើឲ្យជនដែលជាអ្នកទទួលខុសត្រូវលើគម្រោងសំណងដល់អ្នករស់រាន ។ ក៏ប៉ុន្តែដោយសារតែជនដែលក្នុងករណីនេះ ដូចទៅនឹង ឌុច ក្នុងករណី០០១ដែរ គឺ ត្រូវបានដឹងថា មានភាពក្រខ្សត់ ហេតុនេះ គាត់ពុំមានលទ្ធភាពផ្តល់នូវសំណងបាន ។ អ្នកឆ្លើយតបមួយចំនួនជឿជាក់ថា រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិដទៃទៀតគួរតែជាអ្នកទទួលខុសត្រូវក្នុងការផ្តល់នូវគម្រោងសំណងទាំងនេះ ។

## តួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងដំណើរការយុត្តិធម៌

អ្នកចូលរួមភាគច្រើនមិនត្រឹមតែពេញចិត្តចំពោះការផ្សាយបន្តផ្ទាល់របស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ចំណេះដឹងពីដំណើរការកាត់ទោសប៉ុណ្ណោះទេ គាត់ក៏មានការពេញចិត្តនូវកិច្ចពិភាក្សាជុំវិញសាលក្រមដែលគាត់ទទួលបានផងដែរ ។ មានអ្នកចូលរួមមួយភាគតូចប៉ុណ្ណោះដែលបានលើកឡើងថា គាត់ពុំមានទូរទស្សន៍ទេ គាត់មានត្រឹមតែវិទ្យុមួយប៉ុណ្ណោះ ដូច្នេះការផ្សាយបន្តផ្ទាល់នេះ អាចឲ្យគាត់មើលឃើញពីដំណើរការនៃការកាត់ទោសជាលើកដំបូង ។ អ្នកចូលរួមយល់ថា វត្តមានរបស់

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាមានសារសំខាន់ណាស់ក្នុងការពន្យល់នូវចំណុចស្មុគស្មាញដែលគាត់ពុំអាចយល់បានក្នុងដំណើរការនេះ ។ អ្នកចូលរួមភាគច្រើនជឿជាក់ថា ការផ្សាយបន្តផ្ទាល់មានសារប្រយោជន៍ណាស់ក្នុងការអប់រំដល់ក្មេងជំនាន់ក្រោយ ។

ការផ្សាយបន្តផ្ទាល់នេះបានផ្តល់ឲ្យលើសពីឱកាសសម្រាប់អ្នកចូលរួមក្នុងការអង្កេត និងយល់ដឹងអំពីសាលក្រម ហើយក៏បាននាំមកនូវការពិភាក្សាយ៉ាងទូលាយដល់អង្គប្រជុំទាំងមូលដែរ ។ លោក ថុន ធឿន អាយុ៣៦ឆ្នាំ មកពីកោះកែរ ជឿជាក់ថា ការពិភាក្សាបានជំរុញឲ្យមានភាពប្រជាធិបតេយ្យ ។ អ្នកចូលរួមភាគច្រើនយល់ថា ការផ្សាយបន្តផ្ទាល់នេះបានបង្កឱកាសដល់គាត់ក្នុងនាមជាសហគមន៍ ។ អ្នកចូលរួមមួយរូបគឺ លោក ប្រុក នឿន អាយុ៦៨ឆ្នាំ មកពីខេត្តក្រចេះ បាននិយាយថា ព្រឹត្តិការណ៍នេះបានធ្វើឲ្យដំណើរការនៃការកាត់ទោសមាន “ភាពជាក់ស្តែង” ថែមទៀតដល់រូបគាត់ ។

**ខាងក្រោមនេះជាការដកស្រង់ការអង្កេតពីក្រុមជាច្រើនផ្សេងគ្នាក្នុងអំឡុងពេលផ្សាយបន្តផ្ទាល់៖**

ក្រុមស្វាយឃ្លាំងនៅខេត្តត្បូងឃ្មុំ៖ អ្នកភូមិ ជារួមមានការស្វាគមន៍ចំពោះការផ្សាយបន្តផ្ទាល់ក្នុងវត្តនេះ ដែលស្ថិតនៅក្បែរផ្ទះគាត់ ។ គាត់អាចមើលទូរទស្សន៍នៅផ្ទះបាន ប៉ុន្តែមកជួបជុំគ្នានៅក្នុងថ្ងៃពិសេសនេះអាចឲ្យគាត់ទទួលបាននូវគំនិតចម្រើននឹងប្រមូលផ្តុំ ចំពោះឧក្រិដ្ឋកម្ម ការចងចាំ និង បទពិសោធដែលគាត់បានឆ្លងកាត់ក្នុងសម័យខ្មែរក្រហមជាមួយសហគមន៍របស់ខ្លួន ។ សាលាឆាន់នៃវត្តនេះគឺជាទីតាំងដ៏សមស្របមួយ ។ វាបានផ្តល់នូវម្លប់អគ្គិសនី និងការការពារប្រឆាំងនឹងកម្តៅថ្ងៃ និងភ្លៀង ។ កន្លែងនោះក៏ជាទីតាំងសុវត្ថិភាព និងស្ងប់ស្ងាត់សម្រាប់អ្នកទាំងអស់ដែរ ។ ទាំងរូបភាព និងសំឡេងមានភាពសមស្របសម្រាប់ការស្តាប់ និងទស្សនា ។ អ្នកចូលរួមរំពឹងថា គាត់អាចទទួលបាននូវឯកសារពីក្រុមការងាររបស់យើង ក៏ប៉ុន្តែយើងពុំអាចផ្តល់ឲ្យបាន ដោយសម្ភារៈរបស់យើងត្រូវបានបំផ្លិចបំផ្លាញដោយទឹកលិចនៅឯទីតាំងដើមដែលយើងត្រៀមនឹងធ្វើការផ្សាយបន្តផ្ទាល់ ។

**ក្រុមការងារនៅភ្នំវល្លិ៍ ខេត្តកែប ៖** កិច្ចប្រជុំនេះប្រព្រឹត្តទៅដោយសមិទ្ធិផល ។ វាបានជួយឲ្យមានការយល់ដឹងជាសាធារណៈទាក់ទងជាមួយនឹងរបបខ្មែរក្រហម និងផ្តល់ដល់ប្រជាពលរដ្ឋនូវឱកាសក្នុងការបញ្ចេញមតិ ។

**ក្រុមការងារនៅស្រុកសម្បូរ ខេត្តក្រចេះ ៖** ការផ្សាយបន្តផ្ទាល់នេះមានសារប្រយោជន៍ ដល់ឃុំក្បាលដំរី ព្រោះអ្នកភូមិភាគច្រើនពុំមានទូរទស្សន៍ ហើយអ្នកភូមិពុំដែលតាមដានដំណើរការកាត់ទោសនេះពីមុនទេ ។ ជនជាតិភាគតិចពីរក្រុម គឺ ព្នង និង មិល រស់នៅទីនេះ ។

**ក្រុមការងារនៅស្រុកកូនមុំ ខេត្តរតនគិរី ៖** ការផ្សាយបន្តផ្ទាល់នេះមានសារសំខាន់ណាស់ដោយជ្រើសយកវត្តជាទីតាំងសម្រាប់ការផ្សាយបន្តផ្ទាល់ និងប្រមុំផ្តុំ ព្រោះនេះជាទីតាំងមួយដែលអ្នករាល់គ្នាគោរព និងអាចចូលរួមបានដោយគ្មានភាពរើសអើង ។ បើទោះជាគាត់ពុំអាចយល់បានទាំងស្រុងអំពីសាលក្រមក៏ដោយ ក៏គាត់ចូលរួមយ៉ាងសកម្មដោយគ្មានការផ្តល់នូវថវិកាសម្រាប់ការចូលរួម ដែលខុសពីសកម្មភាពដទៃដែលគេចូលរួមលុះត្រាតែមានការជូនជាថវិកា ។ យើងសង្កេតឃើញថា មិនមែនអ្នកចូលរួមទាំងអស់អាចយល់អំពីសាលក្រមនេះទេ ក៏ប៉ុន្តែការផ្សាយបន្តផ្ទាល់នេះ គឺជា ឱកាសតែមួយគត់ដែលអាចឲ្យគាត់មើលឃើញពីមុខមាត់មេដឹកនាំខ្មែរក្រហម ក៏ដូចជាសវនាការ ទាំងនេះបានជំរុញឲ្យការចងចាំរបស់គាត់ចំពោះរបបខ្មែរក្រហមត្រឡប់មកវិញនិងរស់រវើក ។

**ក្រុមការងារនៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ៖** ការផ្សាយបន្តផ្ទាល់នៃការប្រកាសសាលក្រមករណី០០២/០១ របស់ នួន ជា និង ខៀវ សំផន បានផ្តល់នូវពន្លឺដល់ប្រជាជនកម្ពុជាក្នុងដំណើរស្វែងរកការពិត ។ ការផ្សាយបន្តផ្ទាល់នេះ គឺជាជំហានមួយទៀតសម្រាប់កម្ពុជាក្នុងការដោះស្រាយនូវបញ្ហាអតីតកាល ។ យុត្តិធម៌ពុំបានផ្តល់ឲ្យទាំងស្រុងនោះទេនៅពេលដែលការឲ្យនិយមន័យមានភាពខុសប្លែកគ្នា ។ មានតែបុគ្គលផ្ទាល់ទេ ដែលអាចវិនិច្ឆ័យថា យុត្តិធម៌បែបនេះអាចទទួលយកបានប៉ុណ្ណា ។

**ក្រុមការងារនៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ៖** ការផ្សាយបន្តផ្ទាល់សាលក្រមករណី០០២ ដំណាក់កាលទី១ របស់តុលាការខ្មែរក្រហម មានសារសំខាន់ណាស់ ដើម្បីឲ្យប្រជាជន ក៏ដូចជាអតីតយោធា និងកម្មាភិបាលខ្មែរក្រហមបានទស្សនា ស្វែងយល់ពី

ដំណើរការរបស់សាលាក្តីខ្មែរក្រហម និងបំផុសឲ្យមានការពិភាក្សាក្នុងសហគមន៍ ។ ជាពិសេស ឲ្យក្មេងៗនៅក្នុងសហគមន៍ដែលគាត់រស់នៅបានដឹង ។

### សេចក្តីសន្និដ្ឋាន

ការផ្សាយបន្តផ្ទាល់នេះអាចឲ្យអ្នកភូមិរាប់រយនាក់ ដែលមកពី២០ទីតាំង ដែលបានកំណត់ បានទស្សនានូវការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំពោះករណី ០០២/០១ របស់អតីតមេដឹកនាំខ្មែរក្រហម គឺ ខៀវ សំផន និង នួន ជា ។ ក្នុងឱកាសនេះដែរ គាត់មិនត្រឹមតែបានមើលឃើញនូវដំណើរការនេះប៉ុណ្ណោះទេ គាត់ក៏អាចវិភាគ និងពិភាក្សាបានយ៉ាងទូលំទូលាយក្នុងតំបន់របស់គាត់ ។ សរុបមក ទីតាំងដែលបានកំណត់បានប្រមូលផ្តុំនូវវត្តមានរបស់អតីតកម្មាភិបាលខ្មែរក្រហម ជនជាតិភាគតិច និង អ្នកកាន់សាសនា ព្រមទាំងទីតាំងដែលជា តំបន់វប្បធម៌ ។ នៅពេលដែលអ្នកចូលរួមបញ្ចេញមតិផ្សេងគ្នាទាក់ទងជាមួយនឹងសាលក្រម ការពិត និងយុត្តិធម៌ មានអ្នកខ្លះទៀតក៏មានចំណាប់ក្នុងការចែករំលែកនូវគំនិតរបស់ខ្លួន ផ្តល់ឲ្យនូវការសន្ទនាមួយដែលប្រកបដោយភាពក្បោះក្បាយ និង មានប្រយោជន៍នៅរាល់ទីតាំងនីមួយៗ ។ ការពិភាក្សាទាំងនេះមានភាពចាំបាច់ចំពោះការបង្កើតឲ្យមាននូវប្រជាជនកម្ពុជាដែលមានការយល់ដឹងដែលអាចឲ្យគាត់ចូលរួមក្នុងសកម្មភាពប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្ស ។

**លី សុខឃាង**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងឧិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញែកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស បែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល ៖ *truthfatily.s@dccam.org* គេហទំព័រ ៖ *www.ariverchangescourse.com*







# ពិធីផ្សាយផ្ទាល់ពីការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី











# ១ នៅស្រុកសាលាក្រៅ ខេត្តប៉ៃលិន ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤









# ពិធីផ្សាយផ្ទាល់ពីការប្រកាសសាលក្រមករណី00២ ដំណាក់កាល










# ទី១ នៅស្រុកកំរៀង ខេត្តបាត់ដំបង ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤











# ពិធីផ្សព្វាយផ្ទាល់ពីការប្រកាសសាលក្រមករណី00២ ដំណាក់កាលទី១











# នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤









# ពិធីផ្សាយផ្ទាល់ពីការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី









# ី១ នៅស្រុកគូលែន ខេត្តព្រះវិហារ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤











# ពិធីផ្សព្វផ្សាយផ្ទាល់ពីការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី១












# នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤









# ពិធីផ្សាយផ្ទាល់ពីការប្រកាសសាលក្រមករណី០០២ ដំណាក់កា









# បទី១ នៅស្រុកកូនមុំ ខេត្តរតនគិរី ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤











# ពិធីផ្សព្វាយផ្ទាល់ពីការប្រកាសសាលក្រមករណី00២ ដំណាក់កាលទី











១ នៅស្រុកជំណាក់ចង្អើរ ខេត្តកែប ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤









# ពិធីផ្សព្វផ្សាយពីការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី១









# នៅស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤











# ជាប់គុកដោយសារដោះលែងអ្នកទោស

ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ គឺជាកាលបរិច្ឆេទមួយដែលការឈឺចាប់របស់អ្នករស់រានពីរបបខ្មែរក្រហមភាគច្រើនត្រូវបានតបស្នងដោយយុត្តិធម៌ ។ នេះគឺជាថ្ងៃដែលមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ដែលរួមមាន ខៀវ សំផន និង នួន ជា ត្រូវបានដាក់ទោសឲ្យជាប់គុកមួយជីវិត ។ ថ្ងៃនេះគឺពិតជាមានអត្ថន័យធំធេងណាស់ចំពោះអ្នកដែលរស់រានទាំងនោះ ។ អ៊ឹ យិក ដែលជាអ្នករស់រានពីក្នុងគុកល្បាង មានការពេញចិត្តជាខ្លាំងចំពោះលទ្ធផលដែលមេដឹកនាំទាំងនេះទទួលរង ។

អ៊ឹ យិក អាយុ៦៦ ឆ្នាំ គឺជាកសិករមួយរូប ក្នុងភូមិចម្ការបី នៃឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ គាត់មានស្រុកកំណើតក្នុងភូមិដំណាក់ត្រយឹង ។ ចាប់តាំងពីកុមារភាព គាត់អាចអាន និងសរសេរបាន ។ នាឆ្នាំ១៩៧០ គាត់បានរៀបការនិងមានកូនចំនួន ៤នាក់ ។ ក្រៅពីមុខរបរជាកសិករ គាត់ប្រកបរបរជីកថ្មសលក់នៅឯផ្សារទូកមាស ។ គាត់រស់នៅក្នុងជីវភាពសមរម្យ ។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ប្រជាជន ១៧មេសា ចំនួន ៨នាក់ ត្រូវបានខ្មែរក្រហមជម្លៀសឲ្យមកនៅជាមួយគាត់ ។ ដោយសារគាត់ត្រូវបានចាត់តាំងជាកម្មាភិបាលខ្មែរក្រហម ខ្មែរក្រហមបញ្ជាឲ្យគាត់យកប្រជាជន ១៧ មេសា ពីរនាក់ ទៅដាក់នៅក្រោលគោមួយ នៅឯភ្នំក្បាលរិញ ។ បើទោះជាយ៉ាងនេះក្តី គាត់ពុំបានធ្វើតាមការបញ្ជានោះទេ ព្រោះគាត់ដឹងថា ប្រសិនបើគាត់យកអ្នកទាំងពីរនោះទៅ អ្នកទាំងនោះនឹងស្លាប់មិនខាន ។ ការបដិសេធនេះធ្វើឲ្យគាត់ជាប់ឈ្មោះនៅក្នុងបញ្ជីតាមដានរបស់ខ្មែរក្រហម ។

នាពាក់កណ្តាលឆ្នាំ១៩៧៧ គាត់ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាប្រធានកងមើលខុសត្រូវគោ ក្របី ដែលមានឈ្មោះ អន ជាអ្នកគ្រប់គ្រង ។ ការងាររបស់គាត់គឺមើលថែគោក្របីពី ៥០ ទៅ ៦០ ក្បាល ។ នៅក្នុងកងរបស់គាត់រួមមានសមាជិកចាស់ៗ ៣នាក់ និងក្មេង២នាក់ ។ ថ្ងៃមួយ មានកូនគោមួយពុំព្រមចូលក្រោល ។ ដោយអស់មធ្យោបាយ គាត់ក៏បណ្តោយឲ្យកូនគោនោះនៅក្រៅហ៊ុង ។ ឃើញដូច្នេះ ប្រធានភូមិបានចាប់កូនគោនោះទៅកាប់ចែកគ្នាបរិភោគ ។ ស្រាប់តែពី-បីថ្ងៃក្រោយមក អង្គការបានបញ្ជូន យិក ឡើងទៅប្រយុទ្ធនៅសមរភូមិព្រែកជីក ដែលស្ថិតនៅក្បែរព្រំប្រទល់ប្រទេសវៀតណាម ។ ថ្ងៃមួយ មានមនុស្សម្នាក់មករកគាត់ ហើយប្រាប់គាត់ថា កូនរបស់គាត់ឈឺ ហើយត្រូវបានអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញចំនួន១ខែ ។ គាត់មានភាពរីករាយជាពន់ពេក ព្រោះបានមកជួបជុំជាមួយគ្រួសារវិញ ។ ផ្ទុយទៅវិញ គាត់បែរជាត្រូវចាប់ខ្លួន ។ គាត់ត្រូវបានអង្គការចោទប្រកាន់ពីបទដោះលែងប្រជាជន ១៧មេសា ពីរនាក់ និងសម្លាប់កូនគោមួយក្បាល ។ អង្គការសម្រេចបញ្ជូនគាត់ទៅកាន់កំពត ។ យោធាខ្មែរក្រហម បានចាប់គាត់ចង និងដាក់ខ្នោះគាត់រួចបោះដាក់នៅលើឡាន ។ បន្ទាប់មក ទើបបញ្ជូនទៅគុកនៅខេត្តកំពត ។ គាត់បានចំណាយពេល


អ៊ឹ យិ ថតនៅផ្ទះរបស់គាត់ នៅឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប

មួយយប់ ទើបទៅដល់គុកនោះ ។

នៅពេលដែលទៅដល់កំពត គាត់នៅជាប់ចំណង និងខ្នោះនៅឡើយ ។ ក្នុងរយៈពេលបីថ្ងៃដំបូង គាត់ត្រូវនាំទៅសួរចម្លើយ និងវាយធ្វើទារុណកម្មបីដងក្នុងមួយថ្ងៃ ។ អំឡុងពេលសួរចម្លើយ ខ្មែរក្រហមសួរគាត់ថា គាត់ធ្វើខុសអ្វី ។ គាត់ឆ្លើយថា គាត់ពុំបានធ្វើអ្វីខុសទេ ។ គាត់នៅតែបន្តឆ្លើយដូច្នេះ ។ តែអ្នកសួរចម្លើយពុំស្តាប់គាត់ទេ ។ ឆ្មាំគុកបានលើកឡើងថា "ប្រសិនបើមិត្តមិនធ្វើខុស អង្គការមិនឃាត់ខ្លួនមិត្តទេ ។ អង្គការមិនដែលឃាត់ខ្លួននរណាម្នាក់ដោយគ្មានហេតុផលទេ" ។ ឆ្មាំគុកក៏បានសួរគាត់ពីជីវប្រវត្តិរបស់គាត់ ដោយគាត់បានឆ្លើយប្រាប់ថា គាត់ជាកសិករ ។ ទោះបីយ៉ាងណា ឆ្មាំគុកនៅតែបន្តសួរគាត់ពីមូលហេតុដែលគាត់ត្រូវអង្គការបញ្ជូនមកកាន់ទីនោះ ។ ដោយពុំផ្តល់ចម្លើយឲ្យអ្នកសួរពេញចិត្ត ទើបគាត់ត្រូវទទួលរងការវាយនឹងចម្រឹងដែកបង្គួច ។ ដោយពុំអាចទ្រាំទ្រនឹងការឈឺចាប់ គាត់បានសន្លប់បាត់ស្មារតី ។ ចុងក្រោយ គាត់ត្រូវឆ្មាំគុកដាក់ប្រវាក់ ។ គាត់ទទួលបានអាហារពីរពេល គឺបាយ និង បបរ ។ នៅក្នុងបន្ទប់មួយ ឆ្មាំដាក់អ្នកទោសចំនួន១០នាក់ អ្នកទោសទាំងនោះ ត្រូវបានឆ្មាំគុកចងភ្ជាប់នឹងរបាដែកវែងមួយ ។ ឆ្មាំគុកបានដាក់កេសគ្រាប់សម្រាប់ឲ្យអ្នកទាំងនោះបន្ទោរបង់ដែរ ។ មានអ្នកខ្លះបានស្លាប់ ។ បរិយាកាសទីនោះពោរពេញដោយក្លិនស្អុយ ឆ្អេះឆ្អាប ដោយសារតែសាកសពអ្នកទោស រួមជាមួយលាមក និង ទឹកនោម ។ គាត់ត្រូវដេកជាមួយសាកសពនៅជុំវិញខ្លួន ។ គាត់ពុំដែលមានឱកាសងូតទឹកទេ ។ គាត់ជាប់គុកនៅទីនោះអស់រយៈពេល៣ខែ និង២០ថ្ងៃ ។ បន្ទាប់មក គាត់ត្រូវបាននាំទៅទីតាំងថ្មីគឺ ល្អាង រួមជាមួយ អ្នកទោស១០អ្នកទៀត តាមឡាន ។

នៅល្អាង គាត់ត្រូវអង្គការចាត់តាំងឲ្យធ្វើស្រែ លើកដី និងរុករានព្រៃយកដីដាំដំណាំ ។ នៅទីនោះ មានអ្នកទោស សរុបទាំងប្រុស និង ស្រីចំនួន ៦០០នាក់ ។ ចំណែកអាហារដែលគាត់ទទួលបាន គឺបាយលាយជាមួយដំឡូងមី ។ មានមនុស្សស្រីមួយចំនួនបានរត់គេច តែត្រូវឆ្មាំគុកចាប់ខ្លួនបាន ។ បន្ទាប់ពីឃាត់ខ្លួន អ្នកទាំងនោះត្រូវបានចងរយៈពេល២ថ្ងៃ២យប់ ។ ក្រោយមក ឆ្មាំគុកបានឲ្យអ្នកទោសទាំងអស់ឈរជាជួរ ដើម្បីឲ្យអ្នកដែលរត់គេចខ្លួនទាំងនោះស្នើសុំធ្វើជាអ្នកធានារបស់ខ្លួន ដោយធានាថា អ្នកទាំងនោះនឹងពុំរត់ទៀតទេ ។ ប៉ុន្តែពុំមាននរណាម្នាក់ហ៊ានទទួលធ្វើជាអ្នកធានាទេ ។ ជាលទ្ធផលស្ត្រីទាំងនោះត្រូវបានឆ្មាំគុកសម្លាប់ ។ យិក មើលឃើញដោយផ្ទាល់នូវហេតុការណ៍សម្លាប់ចំនួនបីដងដែរ ។ ស្ត្រីពីរនាក់ ត្រូវបានសម្លាប់ដោយត្បូងចប និង បុរសម្នាក់ត្រូវបានសម្លាប់នៅចំពោះមុខគាត់ និងអ្នកទោសដទៃ ។

នៅក្នុងឆ្នាំ១៩៧៨ មានតែអ្នកទោស៣០០នាក់ប៉ុណ្ណោះដែលនៅសល់ ។ ចំនួនអ្នកទោស ត្រូវបានកាត់បន្ថយអស់ពាក់កណ្តាល ។ ក្នុងឆ្នាំនេះ ខ្មែរក្រហមត្រូវវាយទប់ទល់នឹងកងទ័ពវៀតណាមនៅកោះស្លា ហេតុនេះហើយអ្នកទោសទាំងអស់ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅជួយ ។ អ្នកទាំងនោះមានតួនាទីដឹកជញ្ជូនស្បៀងឲ្យយោធាខ្មែរក្រហម ។ មានពេលមួយ យិក បានឃើញអ្នកទោសត្រូវបានខ្មែរក្រហមសម្លាប់ ។ បន្ទាប់មក ឆ្មាំគុកបានមកត្រួតពិនិត្យអ្នកទោស រួចហើយសម្លាប់ជាបន្តបន្ទាប់ ។ យិក គិតថា មិនយូរប៉ុន្មានគាត់នឹងត្រូវខ្មែរក្រហមសម្លាប់ដូច្នេះដែរ ។ ពេលនោះ គាត់ក៏សម្រេចចិត្តលួចរត់ ។ គាត់ត្រូវចំណាយពេល១២យប់ ១២ថ្ងៃធ្វើ ដំណើរទៅក្បាលរមាស ដោយគាត់រត់នៅពេលយប់ ព្រោះខ្លាចខ្មែរក្រហមឃើញ ។ នៅទីនោះ គាត់បានចំណាយពេល១៥ថ្ងៃទៀត ដើម្បីសង់ខ្ទមស្នាក់នៅ ។ ក្រោយមក ឪពុករបស់គាត់បានបររទេះសេះទៅទទួលគាត់ត្រឡប់មកភូមិវិញ ។

ក្រោយពីដឹងថា ខៀវ សំផន និង នួន ជា ត្រូវបានដាក់ទោសឲ្យជាប់គុកមួយជីវិត យិក មានក្តីត្រេកអរ និងពេញចិត្តជាខ្លាំង ។ សាលក្រមនេះបានជួយសម្រាលការឈឺចាប់របស់គាត់បានមួយកម្រិត ។ ប៉ុន្តែ គាត់នៅតែមិនអស់ចិត្ត ព្រោះ ខៀវ សំផន និង នួន ជា ទទួលបានអាហារ និងស្នាក់នៅក្នុងទីតាំងសមរម្យ ដែលផ្ទុយពីគាត់ដែលជាប់គុកនៅក្នុងព្រៃ ។ គាត់បញ្ជាក់ថា "វាពុំស្មើភាពគ្នាទេ" ។ គាត់ចង់ឲ្យអ្នកទាំងពីរទទួលរងការធ្វើបាបដូចគាត់ដែរ ។ បើទោះជា ខៀវ សំផន និង នួន ជា អាចរស់នៅ ឬឃុំឃាំងក្នុងទីតាំងសមស្រប ដែលផ្ទុយស្រឡះពីគាត់ដែលត្រូវរងទារុណកម្ម ។ ទោះបីយ៉ាងណា យិក គិតថា ការចំណាយពេលសេសសល់របស់មេដឹកនាំខ្មែរក្រហមទាំងពីរនៅក្នុង គុកអស់មួយជីវិត គឺសមស្រប ព្រោះជាវេនរបស់គាត់ម្តង ។

**សុភ័ក្រ្ត ភាណា**

# ការតស៊ូដើម្បីបដិវត្តន៍

ក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ តំបន់មួយចំនួននៅប្រទេសកម្ពុជា ជាពិសេស នៅតាមជនបទចុងកាត់មាត់ញក ភាគច្រើនគ្រប់គ្រងដោយកម្លាំងខ្មែរក្រហម ។ ខ្មែរក្រហមបានធ្វើការឃោសនា អប់រំប្រជាជនឲ្យចូលរួមតស៊ូវណ្ណៈ និងដណ្តើមអំណាចថ្វាយសម្តេចឪវិញ ទន្ទឹមនឹងមានការប្រកាសរបស់សម្តេច សីហនុ ឲ្យប្រជាជនទាំងអស់នាំគ្នាចូលព្រៃម៉ាគី ដើម្បីធ្វើការតស៊ូប្រឆាំងនឹង លន់ នល់ ។ ប្រជាជនដែលរស់នៅជនបទភាគច្រើនបានចូលរួមជាមួយចលនាតស៊ូរបស់ខ្មែរក្រហម ដោយម្នាក់ៗមានហេតុផលរៀងៗខ្លួន ។ អ្នកខ្លះចូលរួមក្នុងចលនានេះគឺដើម្បីដណ្តើមអំណាចថ្វាយសម្តេច សីហនុ វិញ និងអ្នកខ្លះទៀត ចូលរួមដើម្បីតស៊ូវណ្ណៈ ព្រោះអ្នកជនបទទាំងនោះតែងតែទទួលការមាក់ងាយ កេងប្រវ័ញ្ច ជិះជាន់ សង្កត់សង្កិន ពីសំណាក់ នាយទុន និងអ្នកមានអំណាច ។

ជាក់ស្តែង ស៊ីវ គេង សព្វថ្ងៃអាយុ ៦០ឆ្នាំ រស់នៅស្រុកឈូក ខេត្តកំពត ។ គាត់គឺជាកូនប្រុសពៅ ក្នុងគ្រួសារកសិករ ដែលមានបងប្អូនប្រាំពីរនាក់ រស់នៅឃុំជម្ពូវ័ន្ត ស្រុកឈូក ក្នុងខេត្តកំពត ។ គាត់ បានចូលរួមចលនាតស៊ូ ជាមួយខ្មែរក្រហម ក៏ព្រោះគ្រួសារគាត់ក្រីក្រពេក ហើយត្រូវក្រុមឈ្មួញធ្វើបាបរឹបអូសយកដីស្រែ ដោយសារមិនមានលុយបង់ការប្រាក់ ។ នៅឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារទម្លាក់ សម្តេច សីហនុ ខ្មែរក្រហមបានចូលមកឃោសនានៅភូមិរបស់គាត់ ដោយប្រាប់ពីការតស៊ូវណ្ណៈប្រឆាំង សក្តិភូមិ នាយទុន ប្រតិកិរិយា និងចក្រពត្តិនិយម ។ គេង និងអ្នកភូមិឯទៀត បានចូលរួមក្នុងចលនានេះ ។ ដូចគ្នានឹងអ្នករួចរស់ជីវិតពីរបបខ្មែរក្រហមម្នាក់ទៀតដែរ អ៊ុន ភឿន គឺជាអតីតមេក្រុមកងពិសេស ផ្នែកជើងទឹក បានចូលរួមចលនាតស៊ូជាមួយខ្មែរក្រហមនៅពេលនោះ បំណងតែមួយគត់របស់គាត់ គឺចូលរួមតស៊ូដើម្បីប្រឆាំងនឹងចក្រពត្តិអាមេរិក និងដណ្តើមអំណាចថ្វាយសម្តេចឪ ។ ស្ថានភាពនៅអំឡុងឆ្នាំ១៩៧០ នៅតាមបណ្តាភូមិស្រុកដែលខ្មែរក្រហមចូលទៅកាន់កាប់ និងចុះអប់រំឃោសនាមិនមានអ្វីខុសគ្នានោះទេ ខ្មែរក្រហមមិនបានធ្វើបាប សម្លុតគំរាមកំហែងប្រជាជនទេ ។ ខ្មែរក្រហមបានចូលគ្រប់គ្រងភូមិរបស់ គេង តាំងពីឆ្នាំ១៩៧០ មកម្ល៉េះ ហើយក៏មិនបានរឹតត្បិតធ្វើបាបប្រជាជនដែរ ។ គេង បានសម្រេចចិត្តចូលធ្វើយោធាស្រុកនៅវត្តចក ។ គាត់មិនដែលបានទៅច្បាំងនៅលើសមរភូមិនោះទេ គ្រាន់តែនៅការពារតាមខ្សែក្រវ៉ាត់ស្រុកប៉ុណ្ណោះ ។ ដំបូង ខ្មែរក្រហមឲ្យ គេង កាន់កាំភ្លើង សេ.កា.សេ ទាំងគាត់មិនចេះប្រើសោះ ។ មួយរយៈក្រោយមក ទើបមានការបង្រៀនឲ្យចេះប្រើប្រាស់កាំភ្លើង ។ ស្ថានភាពជាយោធានាពេលនោះ គឺពិតជាមានការលំបាកខ្លាំងណាស់សម្រាប់ គេង ជាពិសេស គឺការហូបចុក មានការខ្វះខាតច្រើន ទោះបីជាមានការឧបត្ថម្ភខ្លះៗពីអ្នកភូមិក៏ដោយ ។


ស៊ីវ គេង

ក្រោយជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ គេង បានស្នើសុំទៅថ្នាក់លើឈប់ធ្វើជាទាហាន ដើម្បីត្រឡប់មករស់នៅជាមួយឪពុក និងបងប្អូននៅក្នុងភូមិវិញ ។ ថ្នាក់លើបានអនុញ្ញាតឲ្យគាត់ត្រឡប់មកវិញ និងឲ្យធ្វើការនៅក្នុងសហករណ៍ភូមិថ្មី ។ ប្រជាជនជាច្រើនមកពីតំបន់ផ្សេងៗ ដែល គេង បានឃើញ ត្រូវបានជម្លៀសមកកាន់ភូមិថ្មីនេះ អ្នកទាំងនោះភាគច្រើនជាអ្នកជម្លៀសមកពីភ្នំពេញ ។ នៅភូមិថ្មីនេះ មិនថា ប្រជាជនចាស់ ប្រជាជនថ្មីទេ គឺត្រូវធ្វើការដូចគ្នា ខុសគ្នាត្រង់ថា អ្នកថ្មីតែងតែត្រូវទទួលការរើសអើងពីអ្នកមូលដ្ឋាន និងរបបហូបចុកមិនសូវគ្រប់គ្រាន់ដូចអ្នកមូលដ្ឋានទេ ។ មួយរយៈក្រោយមក អង្គការចាប់ផ្តើមធ្វើការបែង

ចែកប្រជាជនទៅតាមនិន្នាការ ប្រជាជនជម្លៀសមកពីភ្នំពេញ ត្រូវចាត់ថ្នាក់ចូលទៅក្នុងសហករណ៍កម្រិតទាប ហើយអ្នកទាំងនោះ តែងតែត្រូវអង្គការដាក់ពិន័យយ៉ាងតឹងរឹង ទោះបីជាកំហុសនោះ តិចតួចក៏ដោយ ។ មនុស្សមួយចំនួនត្រូវចាប់ធ្វើទារុណកម្ម ឬយក ទៅសម្លាប់ចំពោះកំហុស ដូចជា ខ្ជិលធ្វើការ លួចហូប ឬលួចដោះដូរ របស់របរ ឬម្ហូបអាហារជាដើម ។ ការធ្វើការនៅក្នុងសហករណ៍ មិនថាជាប្រជាជនថ្មី ឬប្រជាជនមូលដ្ឋានទេ គឺធ្វើការដូចៗគ្នា ។ ប្រជាជនដែលជម្លៀសមកពីទីក្រុង គឺមានការលំបាកដោយសារ តែអ្នកទាំងនោះមិនធ្លាប់លំបាក មិនចេះធ្វើស្រែ ហេតុនេះហើយ អ្នកទាំងនោះពិបាកទ្រាំនឹងស្ថានភាពបែបនេះណាស់ មិនដូចអ្នកភូមិ ដែលធ្លាប់លំបាកនោះទេ ។ អ្នកខ្លះ ដោយសារតែឃ្លានខ្លាំងពេក បានប្រថុយជីវិតលួចដំឡូង លួចបាយ និងអង្ករហូប ។ អ្នកដែល អង្គការចាប់បានខ្លះ គឺពិន័យនៅនឹងកន្លែងដោយវាយទាត់ធាក់នៅ មុខអ្នកឯទៀត ដើម្បីកុំឲ្យយកគំរូតាម ហើយអ្នកខ្លះត្រូវចាប់ យកទៅឃុំ ឬផ្លាស់នៅកន្លែងផ្សេងដោយគ្មានដំណឹង ។ មិនខុសពី រឿងពិតរបស់កុមារម្នាក់ដែលរួចជីវិតពីរបបខ្មែរក្រហម សឿ គោន ត្រូវបាត់បង់ម្តាយជាទីស្រឡាញ់ ។ ដោយនឹកសង្វេគដល់កូន (គោន) ឈឺ ហើយអត់ឃ្លាន រាងកាយនៅសល់តែស្បែកដណ្តប់ ឆ្អឹងនោះ ម្តាយរបស់ គោន បានសម្រេចចិត្តប្រថុយជីវិតដើម្បីកូន ដោយយកខោអាវ ដែលនៅសល់បន្តិចបន្តួចទៅដូរបាយក្រៀម នឹងអ្នកភូមិក្បែរខាង តែជាអកុសល អ្នកដែលរួមដំណើរជាមួយ ម្តាយគាត់ ត្រូវកងឈ្លបចាប់បាន និងសួរចម្លើយរកអ្នកឯទៀត ។ ស្ត្រីម្នាក់នោះបានរៀបរាប់ឈ្មោះអ្នកទៅជាមួយទាំងប៉ុន្មានប្រាប់ ដល់អង្គការទាំងអស់ ក្នុងនោះ ក៏មានឈ្មោះរបស់ម្តាយ គោន ដែរ ។ ម្តាយរបស់គាត់ និងអ្នកឯទៀត ត្រូវអង្គការចាប់យកទៅ ដាក់គុក និងសួរចម្លើយជាបន្តបន្ទាប់ ។ ប្រហែលជប់ថ្ងៃក្រោយមក ម្តាយរបស់ គោន ត្រូវអង្គការយកទៅសម្លាប់នៅក្នុងរណ្តៅរួម មួយ ។ អ្នកជិតខាងម្នាក់បានប្រាប់រឿងរ៉ាវទាំងនេះដល់គាត់ ។



ស៊ីវ តេង (រូបអង្គុយផ្អែកសសរ) ចូលរួមទស្សនាការផ្សាយបន្តផ្ទាល់ពីការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី១ នៅឃុំកោះស្វា ស្រុកឈូក ខេត្តកំពត

ទាំងនេះ គ្រាន់តែជាកំហុសតូចមួយប៉ុណ្ណោះ តែចំពោះខ្មែរក្រហម នេះជាអំពើប្រឆាំងនឹងបដិវត្តន៍ មិនស្មោះត្រង់នឹងសមូហភាព ត្រូវតែកម្ចាត់ចោល ទុកជាគំរូសម្រាប់អ្នកក្រោយៗកុំឲ្យយកតម្រាប់តាម ។

នៅអំឡុងឆ្នាំ១៩៧៦ នៅសហករណ៍ភូមិថ្មីរបស់ គេង ដែលគ្រប់គ្រងដោយមេភូមិឈ្មោះ ឆេង ការចាប់ខ្លួន និងបាត់ខ្លួន មានការកើនឡើងជារៀងរាល់ថ្ងៃ ។ មនុស្សមួយចំនួនបាត់ខ្លួនដោយគ្មានដំណឹង ហើយអ្នកខ្លះត្រូវអង្គការហៅទៅរៀនសូត្រ តែមិនដែលឃើញត្រឡប់មកវិញទេ ។

រហូតដល់ឆ្នាំ១៩៧៩ ក្រោយបរាជ័យរបស់ខ្មែរក្រហម គេង បានរត់ចូលព្រៃជាមួយមេៗខ្មែរក្រហម ដែលបានហៅគាត់និងគ្រួសារទៅជាមួយនៅព្រៃជ័យសេនា ខាងតាកែន ។ ការដែលគេងសម្រេចចិត្តរត់ចូលព្រៃនេះ គឺធ្វើឡើងដោយបង្ខំចិត្តទេ ព្រោះអ្នកមួយចំនួនបានស្គាល់ និងបានដឹងថា គេង ធ្លាប់ធ្វើជាយោធាខ្មែរក្រហម ដូច្នេះហើយ អ្នកទាំងនោះបានរាយការណ៍ទៅទាហានរដ្ឋាភិបាល ។ ដើម្បីគេចពីការចាប់ខ្លួននេះ គេង មានតែរត់ចូលព្រៃជាមួយមេៗខ្មែរក្រហមទាំងអស់នោះ ។ ជីវិតរស់នៅក្នុងព្រៃគឺមានការលំបាកខ្លាំងណាស់ ព្រោះទៅដល់ដំបូងមិនទាន់មានខ្សែរយៈទាក់ទងទេ ។ ចំពោះអាហារ គឺមានត្រឹមតែក្តួច ដំឡូងប៉ុណ្ណោះ ហើយក៏មិនមានកន្លែងសម្រាប់ដេកដែរ គឺត្រូវដេកផ្ទាល់ដី និងគ្មានមុងភួយសម្រាប់សណ្តប់ទេ ។ ក្នុងព្រៃ គេង ត្រូវខ្មែរក្រហមចាត់ឲ្យចូលធ្វើយោធា និងវាយតាមសមរភូមិផ្សេងៗ ស្ថិតក្រោមបញ្ជារបស់ សំ ប៊ិត ។ នៅឆ្នាំ១៩៩៦ ក្រោយការធ្វើសមាហរណកម្មរវាងរដ្ឋាភិបាលកម្ពុជា និងខ្មែរក្រហម គេង បានត្រឡប់មករស់នៅភូមិកំណើតរបស់គាត់វិញ ដោយប្រកបរបរធ្វើស្រែចម្ការ និងជាជំទប់ទី១ ឃុំតាកែន ។

ទោះបីជារបបខ្មែរក្រហមកន្លងផុតទៅជាងសាមសិបឆ្នាំមកហើយ តែរឿងរ៉ាវដែលបានកើតឡើងទាំងប៉ុន្មាន គេង មិនដែលបំភ្លេចនោះទេ ។ គេង តែងតែនិយាយប្រាប់ដល់កូនៗជានិច្ច ។ គាត់ចង់ឲ្យក្មេងៗជំនាន់ក្រោយសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានច្បាស់លាស់ ដើម្បីចៀសវាងរបបនេះកើតមានសាជាថ្មីទៀត ។ ទន្ទឹមនឹងនេះ យុត្តិធម៌មួយបានផ្តល់មកឲ្យគាត់ តាមរយៈតុលាការខ្មែរក្រហម ។ ថ្ងៃនេះ គេងចាត់ទុកថា ជាថ្ងៃប្រវត្តិសាស្ត្រមួយសម្រាប់ប្រជាជនកម្ពុជា ។ គេង ក៏ដូចជាអ្នកភូមិជ័យសេនា ស្ថិតក្នុងឃុំតាកែន ស្រុកឈូក ខេត្តកំពត បានចូលរួមវេទិកាសាធារណៈដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីពីការផ្សាយបន្តផ្ទាល់ពីការប្រកាសសាលក្រមរបស់តុលាការខ្មែរក្រហមលើសំណុំរឿង០០២ ដំណាក់កាលទី១ ទៅលើអតីតមេដឹកនាំខ្មែរក្រហម នួន ជា និងខៀវ សំផន ។ ការប្រកាសសាលក្រមរបស់តុលាការខ្មែរក្រហម លើអតីតមេដឹកនាំខ្មែរក្រហមទាំងពីររូប នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤នេះ ដោយផ្តន្ទាទោសអតីតមេដឹកនាំទាំងពីរដាក់ពន្ធនាគារអស់មួយជីវិត គឺជាយុត្តិធម៌មួយសម្រាប់ គេង ។ គាត់ពេញចិត្តចំពោះ ការដាក់ទោសនេះ ហើយក៏សមស្របទៅនឹងទង្វើដែលមេដឹកនាំទាំងនេះបានធ្វើមកលើប្រជាជនកម្ពុជា ក៏ដូចជាប្រទេសកម្ពុជា ។ **ធាច សារៈមុនិន្ទ**


# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# ព្រឹម ជិន : ការលួច និង ការបំផ្លាញប្រាសាទកោះកែរ ដោយបារាំង

ក្នុងនាមជាប្រជាជនខ្មែរម្នាក់ ព្រឹម ជិន ទទូចសុំឲ្យបារាំងប្រគល់សងកម្ពុជាវិញនូវវត្ថុបុរាណ ដែលបារាំងបានយកយ៉ាងច្រើនសន្ធឹកសន្ធាប់ចេញពីប្រាសាទកោះកែរ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០ ។ ព្រឹម ជិន មានស្រុកកំណើតនៅភូមិកោះកែរ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ (ពីដើមខេត្តសៀមរាប) ។ បច្ចុប្បន្ន ព្រឹម ជិន ស៊ីឈ្នួលយាមប្រាសាទកោះកែរ និងកត់ត្រាចំនួនភ្ញៀវបរទេសដែលមកមើលប្រាសាទឲ្យអាជ្ញាធរអប្សរា ។ ជិន ជាអ្នកបានឃើញជនជាតិបារាំងដឹករូបចម្លាក់យ៉ាងច្រើនសន្ធឹកសន្ធាប់យកចេញពីប្រាសាទកោះកែរ និងជាសាក្សីប្រវត្តិសាស្ត្រសម្រាប់កូនខ្មែរជំនាន់ក្រោយ ។

ក្នុងវ័យ៧០ឆ្នាំ ព្រឹម ជិន ទំនងជាមានភាពហត់នឿយក្នុងការរត់ចុះរត់ឡើងៗ ដោយគ្មានស្បែកជើង និងទៅមុខទៅក្រោយប្រាសាទ ដើម្បីតាមមើលភ្ញៀវទេសចរ ។ ទោះបីជាយ៉ាងនេះក្តី ព្រឹម ជិន នៅតែមានទឹកមុខញញឹមក្នុងការឆ្លើយប្រាប់គ្រប់យ៉ាង “ចុះយើងលាក់ធ្វើអីជាតិខ្មែរយើង” នៅពេលសួរគាត់អំពីការលួច និងការបំផ្លិចបំផ្លាញរូបចម្លាក់នៅប្រាសាទកោះកែរ ។ ព្រឹម ជិន និយាយរៀបរាប់អំពីការលួចរូបចម្លាក់ ដែលដាក់នៅតាមកំពែងជុំវិញប្រាសាទក្រហមក្នុងបរិវេណប្រាសាទកោះកែរ និងការដឹក



ព្រឹម ជិន ចង្អុលបង្ហាញទីតាំងរូបចម្លាក់នៅក្នុងបរិវេណប្រាសាទក្រហម ដែលជនជាតិបារាំងលួចយកចេញទៅ

កកាយប្រាសាទកោះកែរ (ប្រាសាទធំ) ដោយជនជាតិបារាំង ។

**១) បារាំងដឹកយករូបចម្លាក់យ៉ាងតិច ១០០រូប ចេញពីប្រាសាទកោះកែរ**

ព្រឹម ជិន បញ្ជាក់ថា បារាំងបានប្រមូលយករូបចម្លាក់ខ្មែរយ៉ាងតិចចំនួន១០០ ចេញពីប្រាសាទកោះកែរ ។ ក្នុងនោះមានរូប៖ ខ្លួនមនុស្សក្បាលគោ ខ្លួនមនុស្សក្បាលសេក ខ្លួនមនុស្សក្បាលសេះ ខ្លួនមនុស្សក្បាលឆ្កែ ខ្លួនមនុស្សក្បាលយក្ស ខ្លួនមនុស្សក្បាលស្វា ខ្លួនមនុស្សក្បាលអណ្តើក ខ្លួនមនុស្សក្បាលដំរី ។ រូបទាំងនោះមានទំហំធំៗ និងមានកម្ពស់ពី០.៨ម៉ែត្រ ទៅ ១ម៉ែត្រ ។ រូបខ្លះមានកម្ពស់ជិត២ម៉ែត្រ បើគិតទាំងជើងទម្រ (បល្ល័ង្ក) ។ រហូតមកដល់ពេលនេះ រូបចម្លាក់ទាំងនោះពុំទាន់ត្រូវបានបញ្ជូនមកប្រាសាទកោះកែរវិញទេ ។

កាលពីក្មេង ព្រឹម ជិន ធ្លាប់ស៊ីឈ្នួលជុសលាងសម្អាតរូបចម្លាក់នៅប្រាសាទកោះកែរ ឲ្យជនជាតិបារាំង ដោយទទួលបានប្រាក់កម្រៃ ១រៀល (លុយខ្មែរ) សម្រាប់ការជុសលាងរូបចម្លាក់មួយ ។ ពេលនោះ ព្រឹម ជិន មានអាយុប្រហែល ១១ឆ្នាំ ហើយឪពុករបស់គាត់ជាជំនួយការរបស់ជនជាតិបារាំងទាំងនោះ ។ ឪពុករបស់ ព្រឹម ជិន ឈ្មោះ ព្រឹម ចេះនិយាយភាសាបារាំងយ៉ាងស្ទាត់ជំនាញ ។ ព្រឹម ជិន រៀបរាប់ថា ពេលបារាំងមកដល់ភូមិកោះកែរភ្លាម បារាំងបានបង្គាប់ឲ្យប្រធានភូមិឈ្មោះ ភូម មែន ហៅប្រជាជននៅក្នុងភូមិឲ្យមកជួបជុំគ្នា ដើម្បីជួលឲ្យជុសលាងសម្អាតរូបចម្លាក់នៅប្រាសាទកោះកែរ ។ ពេលប្រជុំ ភូម មែន ប្រាប់ប្រជាជនថា បារាំងជួលឲ្យជុសលាងសម្អាតរូបចម្លាក់នៅប្រាសាទកោះកែរ ដោយផ្តល់ប្រាក់កម្រៃ "លាងសម្អាតរូបចម្លាក់មួយ ទទួលបានមួយរៀល លាងបានរូប១០ ទទួលបាន១០រៀល" ពោលគឺអាស្រ័យទៅតាមចំនួនរូបដែលជុះសម្អាតបាន ។ បន្ទាប់ពីឮដូច្នេះ ប្រជាជនមួយចំនួននៅក្នុងភូមិកោះកែរ មានទាំងក្មេងៗ និងមនុស្សចាស់ នាំគ្នាស៊ីឈ្នួលជុសសម្អាតរូបចម្លាក់ឲ្យជនជាតិបារាំងទាំង


ក្រុមប្រាសាទកោះកែរ និងផ្លូវចូលទៅក្នុងបរិវេណប្រាសាទធំ

នោះ ។

ព្រឹម ជិន បញ្ជាក់ថា គាត់ទទួលបានច្រាសមួយ ធុងទឹកមួយ និងក្រណាត់ សម្រាប់ដុសលាងសម្អាតរូបចម្លាក់ ។ អ្នកផ្សេងៗទៀត ក៏ទទួលបានដូចគ្នា ។ ក្នុងមួយថ្ងៃ គាត់អាចលាងសម្អាតរូបចម្លាក់បានពី ១០ ទៅ ២០រូប ពោល គឺអាស្រ័យលើកម្រាស់ស្លែដែលនៅជាប់រូបទាំងនោះ ។ ព្រឹម ជិន ដុសលាងរូបចម្លាក់ សរុបទាំងអស់បានចំនួន ២៥រូប ដោយទទួលបានប្រាក់កម្រៃ២៥ រៀល ។ គាត់ប៉ាន់ប្រមាណថា រូបចម្លាក់ដែលបារាំងជួលប្រជាជនឲ្យដុសសម្អាត ទាំងអស់មានចំនួនច្រើនជាង ១០០ ហើយសុទ្ធសឹងតែជារូបចម្លាក់ល្អៗ ។ ឪពុករបស់គាត់ ជាអ្នកដើរត្រួតពិនិត្យមើលការដុសសម្អាតនេះដោយផ្ទាល់ ។ រូបទាំងនោះ មានទីតាំងនៅតាមកំពែងព័ទ្ធជុំវិញប្រាសាទក្រហម និងនៅក្នុងប្រាសាទផ្សេងៗ ទៀត ក្នុងបរិវេណប្រាសាទកោះកែរ ។

បារាំងយករូបទាំងអស់នោះចេញពីប្រាសាទកោះកែរ ។ ព្រឹម ជិន បញ្ជាក់ថា បន្ទាប់ពីដុសលាងរួច បារាំងបាននាំគ្នាដឹកជញ្ជូនរូបចម្លាក់ទាំងនោះទាំងថ្ងៃទាំងយប់ ចេញពីប្រាសាទកោះកែរ ។ នៅពេលសួរថា តើគេ (បារាំង) មានបានប្រាប់ថា គេយករូបនឹងទៅទីណាទេ? ព្រឹម ជិន ឆ្លើយថា «អត់ទេ! អត់មានប្រាប់ទេ ។ អត់មានប្រាប់មានអីទេ ។ មកដកយកទៅខ្លួនវា ។ ស្រេចតែចិត្តវា ។ អត់មានប្រាប់ពីណាទេ» ។ នៅពេលសួរទៀតថា ចុះពេលឃើញបារាំងយកនៅនឹងភ្នែកអីចឹង ប្រជាជនអត់មានថាយ៉ាងម៉េចទេ? ព្រឹម ជិន បញ្ជាក់ថា «ចុះថាអី! មានអំណាចអីនឹងថា ។ សូម្បីប្រធានភូមិមិនហ៊ានថាផង ។ អត់ហ៊ានថាទេ ព្រោះគេកាន់នៅប្រទេសខ្មែរយើង ហើយដែលហ៊ានថាគេ ។ អត់ហ៊ានទេ! មេភូមិក៏មិនហ៊ាន មេឃុំក៏មិនហ៊ាន» ។

បារាំងបានប្រើកៅឡាក់ និងឡានស្ទូច ដើម្បីលើក និងដឹកជញ្ជូនរូបចម្លាក់យកចេញពីប្រាសាទកោះកែរ ។ ព្រឹម ជិន រៀបរាប់ថា បារាំងបានជួលប្រជាជនឲ្យជីកលក់ដីនៅក្រោមរូបចម្លាក់ទាំងនោះ ដើម្បីស៊កខ្សែបង ។ បន្ទាប់មក បារាំងប្រើកៅឡាក់ដើម្បីរំកិលរូបទាំងនោះចេញពីទីតាំងដើម ហើយប្រើឡានស្ទូចរូបទាំងនោះដាក់ក្នុងឡានដឹកយកចេញទៅ ។ ព្រឹម ជិនបញ្ជាក់ថា ឡាននោះដាក់រូបចម្លាក់បានចំនួន ១៥រូប ដោយតម្រៀបជាបីជួរ ដែលក្នុងមួយជួរៗ មានរូបចម្លាក់ចំនួន៥ ។


កន្លែងចម្កល់រូបចម្លាក់ដែលបារាំងលួចចេញទៅ

**២) បារាំងគាស់យករូបសំណាកលិង្គព្រះឥសូរ និងយោនីនាងខមា ពីប្រាសាទកោះកែរ**

បច្ចុប្បន្ន នៅលើកំពូលប្រាសាទកោះកែរ (ប្រាសាទធំ) នៅសល់តែបំណែកថ្មបាក់បែក និងប្រហោងធំមួយ (បួនជ្រុង និងជ្រៅចុះទៅក្រោម) នៅចំពាក់កណ្តាលប្រាសាទតែប៉ុណ្ណោះ ។ បារាំងជាអ្នកគាស់បំផ្លាញប្រាសាទនេះ ។ ព្រឹម ជិន បញ្ជាក់ថា កាលពីមុន កំពូលប្រាសាទនេះពុំសូវមានការបែកបាក់ខ្លាំងនោះទេ ហើយប្រហោងធំនេះ ភ្ជិតដោយរូបសំណាកយោនីនាងខមា និងលិង្គព្រះឥសូរ ។ លិង្គនេះមានកម្ពស់ប្រហែល៤ម៉ែត្រ និងទំហំជាង១ម៉ែត្រ ។ ព្រឹម ជិន អះអាងថា គាត់ និង ឪពុកគាត់បានឃើញដោយផ្ទាល់ នៅពេលបារាំងគាស់យករូបសំណាកទាំងពីរនេះ ។ បារាំងប្រើយន្តហោះ (អេឡេកុបទ័រ) ស្ទូចរូបសំណាកនេះដាក់ក្នុងឡានរួចដឹកយកចេញពីប្រាសាទកោះកែរ ។

**ចាន ប្រាថ្នា**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ ទីកន្លែង ៖ អាគារ "ក" ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ភាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍន៍ថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបញ្ចប់សវនាការដេញដោលកាលពីខែតុលា ឆ្នាំ២០១៣ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "Join Criminal Enterprise" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋរួម" ដែលភាសាអង់គ្លេសហៅថា "Common Criminal Plan" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយ នៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# សំណុំរឿង០០៣ និង ០០៤ : និយមន័យនៃពាក្យអ្នកទទួលខុសត្រូវខ្ពស់បំផុតផ្នែកលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

**(តចប់)**

**សំណុំរឿង០០៤ : តាអាន, អ៊ឹម ចែម និង តាទិត្យ**



អ៊ឹម ចែម ថតនៅផ្ទះរបស់គាត់ នៅឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

តាអាន, អ៊ឹម ចែម និង តាទិត្យ ត្រូវបានចាត់ទុកថា ជាជនសង្ស័យនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបែកធ្លាយតាមបណ្តាញសារព័ត៌មានស្កូប ។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ មេធាវីការពារក្តីរបស់ នួន ជា បានបង្ហាញថា តាអាន និង អ៊ឹម ចែម ជាជនសង្ស័យនៅក្នុងសំណុំរឿង០០៤ អំឡុងពេលសួរសាក្សី ប្រាក់ យុទ្ធ នៅក្នុងសំណុំរឿង០០២ ។ ឈ្មោះបុគ្គលទាំងនេះ ត្រូវបានបោះពុម្ពផ្សាយម្តងហើយម្តងទៀត នៅក្នុងអត្ថបទសារព័ត៌មាន ជាមួយនឹងឈ្មោះជនសង្ស័យទី៣ ឈ្មោះ តាទិត្យ នៅក្នុងសំណុំរឿង០០៤ ។

តាអាន ត្រូវបានចោទប្រកាន់ថា បានកាន់ដំណែងអនុលេខាភូមិភាគកណ្តាលនៅក្នុងឆ្នាំ១៩៧៧ ជាទីដែលមានមនុស្សប្រហែល ១៥ម៉ឺននាក់ រួមជាមួយនឹងជនម៉ូស្លីមមួយភាគធំ ត្រូវបានសម្លាប់រង្គាលនៅក្នុងយុទ្ធនាការសម្លាប់ជាបន្តបន្ទាប់ ។ អ៊ឹម ចែម ត្រូវបានចោទប្រកាន់ថា បានក្លាយជាលេខាស្រុកព្រះនេត្រព្រះ នៅក្នុងខេត្តបន្ទាយមានជ័យ អំឡុងពេលនៃការសម្លាប់នៅភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៧ ជាទីដែលគាត់ត្រូវបានរាយការណ៍ថា បានឃើញជំរំលត់ដំ និងគុកចំនួន៥កន្លែង ដែលមនុស្សជិត៥ម៉ឺននាក់បានស្លាប់ ។ ចុងក្រោយយោងតាមអ្នកសិក្សាស្រាវជ្រាវពីខ្មែរក្រហម លោក ប៉ែន ឃៀរនិន តាទិត្យ គឺជាប្អូនថ្លៃរបស់សមាជិកគណៈមជ្ឈិម និងជាលេខាភូមិភាគនិរតី ឈ្មោះ តាម៉ុក ហើយក្រោយមក គាត់បានកាន់តំណែងជាលេខាស្រុកគិរីវង្ស (ស្រុក១០៩) នៅក្នុងភូមិភាគនិរតី ។ តាទិត្យ ត្រូវបានរាយការណ៍ថា បានក្លាយជាអនុលេខាភូមិភាគពាយ័ព្យ ជាទីដែលគាត់បានយល់ដឹង បានបញ្ជា និងរួមចំណែកដោយផ្ទាល់នៅក្នុងការធ្វើ ទារុណកម្ម និងកាត់អវយវៈអ្នកទោស ។

**ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០៣ និង ០០៤**

នៅពេលដែលឈ្មោះរបស់ជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ មូលដ្ឋាននៃអង្គហេតុនៅក្នុងសំណុំរឿង បានក្លាយជាចំណោទបញ្ហានៃការយល់ដឹងជាសាធារណៈ ។ ទាក់ទងនឹងសំណុំរឿង០០៣ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីកាលគ្រានោះ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក វីល្មៀម ស្មីត បានចេញសេចក្តីប្រកាស

ព័ត៌មាននៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៩ ដោយថ្លែងថា ព្រះរាជអាជ្ញា បានស្នើឲ្យមានការស៊ើបអង្កេតរបស់តុលាការ នៅទីតាំងពិតប្រាកដ៨កន្លែងទាក់ទងនឹងការសម្លាប់ ការធ្វើទារុណកម្ម ការឃុំឃាំង ការធ្វើពលកម្មដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញ ដែលបង្កឲ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ និងការប្រព្រឹត្តល្មើសទៅនឹងក្រមព្រហ្មទណ្ឌប្រទេសកម្ពុជាឆ្នាំ១៩៥៦ ។ អតីតសហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានចេញសេចក្តីប្រកាសព័ត៌មានជាបន្តបន្ទាប់ ដែលផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងសំណុំរឿង០០៣ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ។ សហចៅក្រមស៊ើបអង្កេតកាលគ្រានោះ យូ ប៊ុនឡេង និង ប្លង់ បានដាស់តឿន ខេលី អំពីការផ្សព្វផ្សាយព័ត៌មាននេះ ប៉ុន្តែបានបញ្ជាក់ថា ការស៊ើបអង្កេតសំណុំរឿង០០៣ រួមមាន ៖ មន្ទីរសន្តិសុខ ស-២១ ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការសម្លាប់នៅភូមិភាគបូព៌ា កណ្តាល និង ឧត្តរ និងការលុកលុយចូលប្រទេសវៀតណាម ដែលជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿង០០១ និង០០២ ព្រមទាំងការស្វែងរកតំបន់ឧក្រិដ្ឋកម្មថ្មី និងហេតុការណ៍បន្ទាប់បន្សំនៃការកាប់សម្លាប់ ៖ ១) មន្ទីរសន្តិសុខស-២២ នៅក្នុងទីក្រុងភ្នំពេញ ២) មន្ទីរសន្តិសុខនៅវត្តឥន្ទញាន នៅក្រុងព្រះសីហនុ ៣) ការដ្ឋានវាយថ្មស្ទឹងហាវ នៅក្រុងព្រះសីហនុ ៤) ការចាប់ខ្លួនជនបរទេសនៅឆ្នេរសមុទ្រប្រទេសកម្ពុជា និងការផ្ទេរអ្នកជាប់ពន្ធនាគារទៅកាន់មន្ទីរស-២១ ឬសម្លាប់ចោល ៥) មន្ទីរសន្តិសុខប្រតិបត្តិនៅក្នុងខេត្តរតនគិរី ។

សេចក្តីប្រកាសព័ត៌មានរបស់ លោក ខេលី បានពិភាក្សាលើសំណុំរឿង០០៤ ដោយថ្លែងថា ព្រះរាជអាជ្ញាបានស្នើសុំឲ្យមានការស៊ើបអង្កេតលើទីតាំងជាក់ស្តែងនៃការសម្លាប់ ធ្វើទារុណកម្ម ការឃុំឃាំង ការធ្វើពលកម្មដោយបង្ខំ និងការធ្វើទុកបុកម្នេញ នៅទីតាំង៣២កន្លែងផ្សេងគ្នា ដែលបង្កឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភក្រមព្រហ្មទណ្ឌប្រទេសកម្ពុជាឆ្នាំ១៩៥៦ និងអំពើប្រល័យពូជសាសន៍ ។ ចៅក្រមពីររូបបានបង្ហាញនូវបញ្ជីរាយនាមទីតាំងសម្លាប់ និងដើមរឿងនៃការស៊ើបអង្កេតនៃសំណុំរឿង០០៤ ដែលរួមមាន មន្ទីរសន្តិសុខ១៨កន្លែង គុក២កន្លែង ទីតាំងសម្លាប់៦កន្លែង និងទីតាំងធ្វើពលកម្មធ្ងន់ធ្ងរ និងការដ្ឋានសាងសង់ទំនប់ទឹក៤កន្លែង ។ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា ការស៊ើបអង្កេតសំណុំរឿង០០៤ ជាប់ពាក់ព័ន្ធការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាមម៉ូស្លីម នៅក្នុងខេត្តកំពង់ចាម និងឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការសម្លាប់របស់ខ្មែរក្រហមនៅភូមិភាគកណ្តាល និងពាយ័ព្យ ។

## មន្ទីរសន្តិសុខ គុក និងទីតាំងសម្លាប់

មន្ទីរសន្តិសុខត្រូវបានបង្កើតឡើងនៅពាសពេញប្រទេសកម្ពុជាដោយខ្មែរក្រហម ហើយគុក និង ជំរំលត់ដំ ត្រូវបានប្រើប្រាស់សម្រាប់ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ខ្មាំង ។ គួរឲ្យកត់សម្គាល់ ទីតាំងសម្លាប់ស្ថិតនៅជិតមន្ទីរឃុំឃាំង ហើយមានរណ្តៅសាកសពជាច្រើនដែលមានជនរងគ្រោះចាប់ពីរាប់សិបទៅដល់រាប់ពាន់នៅក្នុងរណ្តៅនីមួយៗ ។ ឧទាហរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជា បានប៉ាន់ស្មានថា គុកទួលតាផុង និងទីតាំងសម្លាប់ ដែលស្ថិតនៅក្នុងចំណោមទីតាំងស៊ើបអង្កេតសំណុំរឿង០០៤ មានរណ្តៅសាកសពចាប់ពី២៥០ ទៅ៥០០កន្លែង ដែលមានជនរងគ្រោះចាប់ពី៥ម៉ឺននាក់ទៅ១៥ម៉ឺននាក់ ដែលបានសម្លាប់ដោយខ្មែរក្រហម ។ ទីតាំងគុកផ្សេងៗក្រោមការស៊ើបអង្កេត ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០៣ និង ០០៤ គឺជាទីតាំងដែលមានការសម្លាប់ទ្រង់ទ្រាយធំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ការបោសសម្អាត

ការបោសសម្អាតផ្ទៃក្នុងបក្ស គឺជាប្រភពដ៏សំខាន់នៃការសម្លាប់ និង ការរងទុក្ខទោសក្នុងរបបខ្មែរក្រហម ។ ការបោសសម្អាតភូមិភាគពាយ័ព្យ និង កណ្តាល នៅក្នុងសំណុំរឿង០០៣ និង ០០៤ គឺជាការបោសសម្អាតពីរ ក្នុងចំណោមការបោសសម្អាតដ៏ធំបំផុតទាំងបី ជាមួយនឹងការបោសសម្អាតនៅតំបន់បូព៌ា ក្នុងឆ្នាំ១៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងការសម្លាប់ និងទារុណកម្ម ។ យោងតាមលោក ប៉ែន យៀរនិន ដំណើរការនៃការបោសសម្អាតរបស់ខ្មែរក្រហម គឺដើម្បីបញ្ជូនកម្មាភិបាលក្រោមបញ្ជារបស់តាម៉ុក ឬលេខាភូមិភាគឧត្តរ កែ ពក ចូលក្នុងតំបន់នោះ ហើយចាប់ខ្លួន និងសម្លាប់កម្មាភិបាលនៅក្នុងតំបន់នោះ ។ ក្នុងឆ្នាំ១៩៧៦ កែ ពក បានដឹកនាំឲ្យមានការសម្លាប់ដោយអំពើហិង្សានៅភូមិភាគ

កណ្តាល ហើយនៅក្នុងឆ្នាំ១៩៧៧ កងកម្លាំងរបស់ តាម៉ុក បានបោសសម្អាត ភូមិភាគពាយ័ព្យ ។ យៀវនិន ប៉ាន់ស្មានថា ចំនួនអ្នកស្លាប់បានកើនហួសពីចំនួន១០ម៉ឺននាក់ នៅក្នុងឆ្នាំ១៩៧៧ អំឡុងពេលបោសសម្អាតនៅភូមិភាគពាយ័ព្យ ។

**ការដ្ឋាន**

ការដ្ឋាន និងជីវលត់ដី គឺជាវិធីសាស្ត្ររបស់ខ្មែរក្រហមក្នុងការសម្លាប់ ទាំងការសម្លាប់ នៅការដ្ឋាន និងរួមទាំងការធ្វើការហួសកម្លាំង ការបង្អត់អាហារ ជំងឺ និងកង្វះការថែទាំសុខភាព ។ វិសាលភាពសំណុំរឿង០០៤ រួមមាន ការដ្ឋានអន្លង់ជ្រៃ ត្រពាំងថ្ម ស្ពានស្រែង និងការដ្ឋានសាងសង់ទំនប់ព្រៃរនាម ។ ទីតាំងទាំងនេះគឺជាការដ្ឋានដ៏ធំ ដែលមានអ្នកធ្វើការមួយចំនួនធំ ។ ឧទាហរណ៍ យោងតាមអង្គការឃ្លាំមើលសិទ្ធិមនុស្ស ជនសង្ស័យនៅក្នុងសំណុំរឿង០០៤ ឈ្មោះ អ៊ឹម ចែម ទទួលខុសត្រូវចំពោះការសាងសង់ទំនប់ត្រពាំងថ្ម នៅពាក់កណ្តាលឆ្នាំ១៩៧៧ ហើយស្ថានភាពការងារ ដុនដាបដែលប្រជាជនរងទុក្ខក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម បណ្តាលឲ្យមានអ្នកស្លាប់ជាច្រើន ។ ប្រជាជនមួយចំនួនត្រូវបានសម្លាប់នៅការដ្ឋានទំនប់ ដោយសារប្រជាជនទាំងនោះតវ៉ាអំពីលក្ខខណ្ឌការងារ ឬមិនអាចឆ្លើយតបនឹងតាមតម្រូវការការងារ ។

**ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើជនជាតិចាមម៉ូស្លីម**

ក្រៅពីឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗ ដែលប្រព្រឹត្តនៅមន្ទីរសន្តិសុខ គុក ការដ្ឋាន និងអំឡុងពេលនៃការបោសសម្អាត សំណុំរឿង ០០៣និង០០៤ជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់នៃការសម្លាប់ជនជាតិចាមម៉ូស្លីម ក្រុមជនជាតិភាគតិចនៅក្នុងប្រទេសកម្ពុជា ដែលបានស្លាប់ច្រើនជាងជនជាតិខ្មែរ នៅក្នុងរបបខ្មែរក្រហម ។ ពិតប្រាកដណាស់ ខ្មែរក្រហមបានប្រមាថមើលងាយជនជាតិចាម ហើយមានភ័ស្តុតាងជាច្រើនដែលបង្ហាញថា របបខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ។ ឧក្រិដ្ឋកម្មទាក់ទងនឹងអំពើប្រល័យពូជសាសន៍មកលើជនជាតិចាម ជាប់ពាក់ព័ន្ធក្នុងសំណុំរឿង០០៣ និង ០០៤ ហើយ តាអាន ជាប់ពាក់ព័ន្ធនឹងការត្រួតពិនិត្យមើលការសម្លាប់ក្នុងទ្រង់ទ្រាយធំ រួមមានជនជាតិចាមរាប់ពាន់នាក់ ។

**សេចក្តីសន្និដ្ឋាន**

យោងតាមសេចក្តីសង្ខេបនៃព័ត៌មានទាក់ទងនឹងសំណុំរឿង០០៣ និង ០០៤ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វាទំនងជាថា ជនសង្ស័យដែលរស់រានមានជីវិតទាំងបួននាក់ នៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថា ជាបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត ។ ទី១) វាមិនខុសពីការដែលថា ជនសង្ស័យទាំង៤ គឺជាកម្មាភិបាលខ្មែរក្រហម ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ទី២) ឧក្រិដ្ឋកម្មតាមការចោទប្រកាន់ រួមមាន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ស្ថិតក្នុងចំណោមឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដែលកើតមាន និងគ្របដណ្តប់លើទីតាំងភូមិសាស្ត្រធំ ត្រូវបានប្រព្រឹត្តអស់រយៈពេលជាច្រើនឆ្នាំ ហើយជាប់ពាក់ព័ន្ធនឹងជនរងគ្រោះរាប់លាននាក់ រួមមាន ការសម្លាប់ជនរងគ្រោះរាប់រយពាន់នាក់ យោងទៅតាមអតីតសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ឺត ប៉ីទីត ។ ពិតប្រាកដណាស់ អ្នកសារព័ត៌មាន ឌូក្លាស ហ្គាលីសិន បានប៉ាន់ស្មានតាមរយៈការស្រាវជ្រាវរបស់គាត់ថា មានការស្លាប់ចន្លោះពី ២៤៨.៩៩០នាក់ ទៅ ២៩៥.១៩០នាក់ ដោយសារឧក្រិដ្ឋកម្ម ដែលមានចោទប្រកាន់ក្នុងសំណុំរឿង ០០៤តែឯង ។

ចំនួននេះធ្វើឲ្យសំណុំរឿង០០៣ និង ០០៤ ស្ថិតនៅក្នុងចំណោមការកាត់សេចក្តីថ្មីស្តីពីឧក្រិដ្ឋកម្មអន្តរជាតិថា ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ឧទាហរណ៍ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានរកឃើញថា មីលានលូគិក ដ្រាហ្គោម៉ីរ មីឡូសូវិក និង រាស៊ីម ឌីលិក ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវជាន់ខ្ពស់សម្រាប់ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងអតីតប្រទេសយូហ្គោស្លាវី ហើយបានបដិសេធបញ្ជូនសំណុំរឿងទាំងនេះទៅកាន់តុលាការជាតិដើម្បីឲ្យចោទប្រកាន់ ។ ថ្វីបើការពិតដែលថា សេចក្តីសន្និដ្ឋានទាំងនេះគឺថាសំណុំរឿងទាំងបីនេះជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលមានស្ថានទម្ងន់ស្រាលជាងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ទាក់ទងនឹងរយៈពេល ចំនួនជនរងគ្រោះ និងចំនួនអ្នកស្លាប់ ។ សេចក្តីសម្រេចផ្ទេរសំណុំរឿង បានបង្វែរការជំនុំជម្រះមកតុលាការជាតិ ហើយសម្រេចមិនបញ្ឈប់បទចោទប្រកាន់ទាំងអស់ ។ ជាងនេះទៅទៀត ដោយអនុលោមតាមគោលនយោ

បាយយុត្តាធិការតូចចង្អៀត ព្រះរាជអាជ្ញារបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បានធ្វើការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ១២នាក់ ដែលមានចំនួនពីរនាក់លើសពីចំនួនជនសង្ស័យសរុប១០នាក់ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសិទ្ធិតាមផ្លូវច្បាប់ក្នុងការចោទប្រកាន់មានភាពប្រាកដប្រជា ។ ជាពិសេស ព្រះរាជអាជ្ញាមិនល្មើសទៅលើឆន្ទានុសិទ្ធិយុត្តាធិការនៅក្នុងការនាំសំណុំរឿងប្រឆាំងនឹង អូហ្គោស៊ីន ជៅ និង អាល់លូ ខុនដូវ៉ា ដែលអ្នកទាំងនោះស្ថិតក្រោមបញ្ជាថ្នាក់លើ នៅក្នុងប្រទេសសេរ៉ាឡេអូន ដែលដូចគ្នានឹងជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ខ្មែរក្រហម ។

ជាពិសេស ទន្ទឹមពេលដែលចំនួនអ្នកស្លាប់ក្រោមសម័យខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានប៉ាន់ស្មានថាប្រហែល១.៧លាននាក់ ទៅ ២.២លាននាក់ មានច្រើនលើសលប់លើចំនួនអ្នកស្លាប់សរុបទាំងក្នុងប្រទេសយូហ្គោស្លាវី និងប្រទេសសេរ៉ាឡេអូន ហើយប្រៀបធៀបទៅនឹងការទទួលខុសត្រូវជាប់ពាក់ព័ន្ធនឹងភាគរយនៃអ្នកស្លាប់ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន សំណុំរឿង០០៣ និង ០០៤នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាប់ពាក់ព័ន្ធចំនួនអ្នកស្លាប់ច្រើនជាងសំណុំរឿង ០០១ ។ ពិតប្រាកដណាស់ ជនសង្ស័យដែលត្រូវបានសន្មតនៅក្នុងសំណុំរឿង០០៣ មាស មុត មានទំនាក់ទំនងដោយផ្ទាល់នឹងឧក្រិដ្ឋកម្មមួយចំនួន ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០១ ដោយសារគាត់បានបញ្ជូនជនរងគ្រោះទៅកាន់មន្ទីរសន្តិសុខស-២១ ដើម្បីធ្វើទារុណកម្ម និងសម្លាប់ចោល ។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញ ថា ជនរងគ្រោះយ៉ាងហោចណាស់១២.២៧៣នាក់ ត្រូវបានសម្លាប់ក្រោមអំណាចរបស់ ឌុច ។ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលអំណះអំណាងរបស់ ឌុច ដែលលើកឡើងនៅក្នុងបណ្តឹងសារទុក្ខថា សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត បានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការចាត់ទុក ឌុច ជាបុគ្គលទទួលខុសត្រូវខ្ពស់បំផុត ហើយធ្វើការជំនុំជម្រះលើរូបគាត់ ។ ដូច្នេះវាទំនងជាមិនអាចទៅរួចទេដែលថា ឌុច អាចគេចផុតពីការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ក្នុងនាមជាបុគ្គលម្នាក់ដែលត្រូវបានចាត់ទុកថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះអំពើឃោរឃៅរបស់ខ្មែរក្រហម ប៉ុន្តែប្រសិនបើមើលឲ្យវែងឆ្ងាយជាងនេះបន្តិច បុគ្គលដែលទំនងជាថ្នាក់លើរបស់ ឌុច ហើយអ្នកទាំងអស់ទំនងជាជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬក៏មានស្ថានទម្ងន់ទោសធ្ងន់ធ្ងរជាង ឌុច រួមមាន ការទទួលខុសត្រូវចំពោះការស្លាប់មនុស្សរាប់ពាន់នាក់ ពុំឃើញត្រូវបានចោទប្រកាន់ឡើយ ។

ជាសរុប វាទំនងជាថា អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រូបឺត បឺទីត យល់ឃើញត្រឹមត្រូវក្នុងការពោលអះអាងថា ជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង ០០៤ "ស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ។ ជាងនេះទៅទៀត សេចក្តីសម្រេចរបស់ចៅក្រម ឡូរ៉ង់ កាស្ព័រ អានសឺម៉េត ដែលលើកឡើងថា ជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ ត្រូវបានចាត់ទុកថាជា "អ្នកទទួលខុសត្រូវជាន់ខ្ពស់" គឺលោកបានប្រើប្រាស់ច្បាប់ និងអង្គហេតុធ្វើជាសម្អាង ។ វាអាចជាការលំបាកដែលត្រូវប្រមើលមើលផែនការណាមួយដែលសេចក្តីសម្រេចតាមវិជ្ជាជីវៈត្រឹមត្រូវ បាននាំទៅរកសេចក្តីសន្និដ្ឋានផ្សេង ។ ដូច្នេះហើយ ទន្ទឹមពេលដែលការជំនុំជម្រះនៅក្នុងសំណុំរឿង០០៣ និង ០០៤ អាចមិនមានផលល្អចំពោះភាគីមួយចំនួនតាមផ្លូវនយោបាយ ការជំនុំជម្រះនៅក្នុងសំណុំរឿងទាំងពីរ អាចត្រូវបានយកធ្វើការការពារក្តីនៅក្នុងដំណាក់កាលនេះ ហើយបច្ច័យណាមួយផ្សេងពីនេះ គួរតែត្រូវបានមើលឃើញថា ជាការវិនិច្ឆ័យដោយមិនមានលក្ខណៈវិជ្ជាជីវៈត្រឹមត្រូវ និងមិនមានសុចរិតភាព ។ ដូច្នេះហើយទន្ទឹមពេលដែលសំណុំរឿង០០២ នៅតែជាសំណុំរឿងដ៏សំខាន់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំណុំរឿង០០៣ និង ០០៤អាចកំណត់អំពីភាពជឿជាក់របស់តុលាការថា ជាស្ថាប័នច្បាប់មួយ ហើយអាចនឹងបន្សល់ទុកនូវកេរដំណែលរបស់ខ្លួន ។

**រ៉ែនឌល ដឺហ្សាលក**

# ការចោទប្រកាន់មេដឹកនាំខ្មែរក្រហមលើកឡើងអំពីនិយមន័យនៃពាក្យយុត្តិធម៌

នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ព្រឹត្តិការណ៍ដ៏សំខាន់បានកើតឡើងក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។ ចុងក្រោយ សកលលោកបានយល់ដឹងអំពីលទ្ធផលនៃសំណុំរឿង ០០២ ដែលជាសាលក្រមត្រូវទន្ទឹមរង់ចាំយ៉ាងយូរ សម្រាប់អតីតមេដឹកនាំខ្មែរក្រហម នួន ជា និង ខៀវ សំផន ស្តីពីបទល្មើស និងការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានទាញយកឱកាសដោយបង្ហាញជាទស្សនៈដែលថា "មិនមានអ្នកឈ្នះ និងមិនមានបុព្វហេតុសម្រាប់ការអបអរនោះទេ" ។ ទន្ទឹមពេលដែលឱកាសនោះបង្ហាញអំពីស្នាដៃជាច្រើននៅក្នុងប្រទេសកម្ពុជា និងការតស៊ូយ៉ាងយូររបស់សហគមន៍អន្តរជាតិ ដើម្បីសិទ្ធិមនុស្ស សន្តិភាព និង នីតិរដ្ឋ ហើយជាជ័យជម្នះដែលអាចត្រូវបានចាត់ទុកថា ជាការសញ្ជឹងគិតដែលមិននឹកស្មានដល់ ។

ប្រការនេះបានធ្វើឲ្យខ្ញុំសញ្ជឹងគិតអំពីគោលការណ៍ស្នូលថា តើហេតុអ្វីសាលាក្តីខ្មែរក្រហមត្រូវបានបង្កើតឡើងនៅកន្លែងទីមួយ ។ ការស្វែងរកយុត្តិធម៌ គឺជាគោលបំណងរបស់សាលាក្តី ប៉ុន្តែតើយុត្តិធម៌អាចត្រូវបានស្វែងរកដែរឬទេ? នេះគឺជាសំណួរមួយដែលមនុស្សគ្រប់គ្នានឹងបន្តសួរ ។ ប្រការនេះទាក់ទងជាមួយនឹងនិយមន័យច្បាប់ដែលបង្កើតឡើងដោយអ្នកសិក្សារៀនសូត្រលោកខាងលិច និងពាក្យថា ជនរងគ្រោះ ។ តាមវចនានុក្រម



ជុំ មុី ចូលរួមស្តាប់ការប្រកាសសាលក្រមករណី០០២ ដំណាក់កាលទី១ នៅសាលាក្តីខ្មែរក្រហម នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤

អកហ្វុត បានឲ្យនិយមន័យ "យុត្តិធម៌" ថាជា "តវិយាបថ ឬការប្រព្រឹត្ត ៖ ១) លក្ខណៈនៃយុត្តិធម៌ និងសមហេតុផល ២) ការគ្រប់គ្រងច្បាប់ ដើម្បីឲ្យមានយុត្តិធម៌ ។

និយមន័យនេះបម្រើមុខងារជាមូលដ្ឋានដ៏ល្អ សម្រាប់ការយល់ដឹងរបស់យើងអំពីទស្សនៈនេះ ។ ទោះបីជាយ៉ាងនេះក៏ដោយ អង្គការសហប្រជាជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវតែធ្វើការក្នុងរបៀបមួយដែលអាចស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ និងប្រទេសកម្ពុជាទាំងមូល ។ ដោយយោងលើរបាយការណ៍ ខែមីនា ឆ្នាំ២០១០ របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលថា "យុត្តិធម៌ក្នុងសម័យអន្តរកាលមានដំណើរការ និងយន្តការទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ រួមមានគម្រោងផែនការផ្តួចផ្តើមការចោទប្រកាន់ ការសម្របសម្រួលផែនការផ្តួចផ្តើមទាក់ទងនឹងសិទ្ធិស្វែងរកការពិត ការសងសំណង កំណែទម្រង់ស្ថាប័ន និងការប្រឹក្សាយោបល់ថ្នាក់ជាតិ ។ ទោះបីជាដំណើការមួយណាក៏ដោយដែលត្រូវបានជ្រើសរើស ត្រូវតែស្របជាមួយនឹងស្តង់ដារ និងកាតព្វកិច្ចច្បាប់អន្តរជាតិ ។ កត្តាដ៏សំខាន់បង្ហាញអំពីការពិតដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានដំណើរការដើម្បីស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ។

ទោះបីជាយ៉ាងណាក៏ដោយ វាហាក់បីដូចជាថា ក្នុងនាមជាប្រជាជនកម្ពុជា យើងមានទស្សនៈ មិនច្បាស់លាស់ និងខ្វែងគ្នាអំពីអត្ថន័យនៃពាក្យយុត្តិធម៌ ។ វានៅតែជាទស្សនៈបរទេស ដែលយើងកំពុងតែព្យាយាមរៀនសូត្រ និងទទួលយកតាមការយល់ដឹងរបស់យើងផ្ទាល់ ។ ខ្ញុំជឿថា មិនទាន់មានការពិភាក្សាកម្រិតថ្នាក់ជាតិអំពីប្រធានបទនេះឲ្យបានគ្រប់គ្រាន់ ដោយរួមទាំងនៅក្នុងចំណោមសមាជិកសភាដែលជាប់ឆ្នោត ស្តីពីតើអ្វីជាយុត្តិធម៌ ។ តើវាមានន័យយ៉ាងដូចម្តេច? តើវាគួរតែមានន័យដូចម្តេច? តើវាមើលទៅដូចអ្វី?

ខ្ញុំបានធ្វើដំណើរជុំវិញប្រទេសកម្ពុជា និងបានធ្វើសម្ភាសប្រជាជនអំពីខ្មែរក្រហម ហើយប្រជាជនទាំងអស់នោះប្រាប់ខ្ញុំថា គាត់ចង់បានយុត្តិធម៌ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលសួរថា តើយុត្តិធម៌មានន័យយ៉ាងដូចម្តេច ប្រជាជនទាំងនោះពិបាកនិយាយអំពីពាក្យថា យុត្តិធម៌នេះ ។ នៅពេលដែលខ្ញុំជំរុញប្រជាជនទាំងនោះឲ្យឆ្លើយ ប្រជាជនទាំងនោះបាននិយាយអំពីអត្ថន័យនៃពាក្យយុត្តិធម៌ តាមការយល់ដឹងរបស់ខ្លួន ។ ស្ត្រីម្នាក់ដែលខ្ញុំបានសម្ភាសថ្មីៗ នេះទាក់ទងនឹងសាលក្រមសំណុំរឿង០០២ បានប្រាប់ខ្ញុំថា យុត្តិធម៌សម្រាប់គាត់ គឺមិនចង់ឃើញប្រទេសជាតិត្រឡប់ទៅសម័យកាលដូចសម័យខ្មែរក្រហម ប៉ុន្តែវានឹងមិនអាចនាំសាច់ញាតិរបស់គាត់ត្រឡប់មកវិញពីការស្លាប់បាននោះឡើយ គាត់បានរៀបរាប់ទាំងទឹកភ្នែក និងបានប្រាប់សាច់រឿងរបស់គាត់មកខ្ញុំ ។

ប្រការនេះបានបង្ហាញអំពីការប្រឈម ។ ច្បាស់ណាស់ អត្ថន័យនៃពាក្យយុត្តិធម៌ មិនស្របតាមយុត្តិធម៌ ដូចដែលត្រូវបានកំណត់ដោយបទដ្ឋានអន្តរជាតិ និងការអនុវត្តរបស់តុលាការនោះទេ ។ វាអាចចោទជាសំណួរថា តើយុត្តិធម៌ត្រូវបានបម្រើដល់អ្នករស់រានមានជីវិតឬទេ? អត្ថន័យនៃពាក្យយុត្តិធម៌ទាំងពីរនេះគួរតែត្រូវបានផ្សារភ្ជាប់ ។ ពិតប្រាកដណាស់ ត្រូវតែមានចាំបាច់នូវមធ្យោបាយមួយដែលធានាថា ការចង់បាន និងសេចក្តីសង្ឃឹមរបស់អ្នករស់រានមានជីវិតទាំងនោះ ត្រូវបានឆ្លើយតបជំនួសឲ្យដំណើរការដែលជាការអនុវត្តរបស់អង្គការសហប្រជាជាតិ នៅគ្រប់តុលាការទាំងអស់ ។

នេះគឺជាឱកាសសម្រាប់អង្គការសហប្រជាជាតិដើម្បីដាក់បញ្ចូលការរំពឹងទុករបស់អ្នករស់រានមានជីវិត ដើម្បីធានាថា វាគឺជាយុត្តិធម៌ ដែលប្រជាជនពិតជាចង់បាន ហើយមិនគ្រាន់តែជាអ្វីដែលអង្គការសហប្រជាជាតិគិតថា ខ្លួនចង់បាននោះទេ ។

**ស្រីនាដ ផូល**

# អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាម៖ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ▪ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ប្រវត្តិសាស្ត្រកម្ពុជា ៖ វិទ្យាល័យនៅសហរដ្ឋអាមេរិក

ថ្ងៃមួយនា រដូវរំខ្យល់ធ្លាក់ក្នុងខែមករា ខេលី អាយុ១៨ឆ្នាំ បានដើរចូលក្នុងថ្នាក់រៀន និងអង្គុយនៅខាងក្រោយគេនៅក្នុងថ្នាក់ ។ នេះជាថ្ងៃចាប់ផ្តើមឆមាសដំបូងរបស់ខ្ញុំ ដែលបានដាក់ឈ្មោះថា "កម្ពុជា ៖ វប្បធម៌ និង ជម្លោះ" ។ ជាសិស្សបញ្ចប់ឆ្នាំនៃវិទ្យាល័យ ខេលី ដែលនៅសល់តែ៥ខែទៀត ដើម្បីទទួលសញ្ញាបត្រ ហើយ ខេលី ក៏បានត្រៀមខ្លួនជាស្រេច ដើម្បីប្រឡងចូលរៀនផ្នែកជីវវិទ្យា ។ ដូច្នេះ មូលហេតុដែលនាំ ខេលី ចូលរៀនមុខវិជ្ជារបស់ខ្ញុំ គឺជាការចង់ស្វែងយល់ឲ្យបានស៊ីជម្រៅអំពីប្រវត្តិសាស្ត្រកម្ពុជា និងរបបខ្មែរក្រហម ។

ខេលី ក៏ដូចជាមិត្តរួមថ្នាក់ពាក់កណ្តាលទៀតដែរ ជាជនជាតិខ្មែរដែលមានសញ្ជាតិអាមេរិកាំង ។ ឪពុកម្តាយរបស់ ខេលី មានស្រុកកំណើតនៅប្រទេសកម្ពុជា ហើយបានមករស់នៅសហរដ្ឋអាមេរិក នៅដើមឆ្នាំ១៩៨០ តាមរយៈជំរំ ។ ឪពុកម្តាយរបស់ ខេលី បានរស់នៅឡូវែល ហើយក៏បានក្លាយខ្លួនជាអនិកជនខ្មែរនៅទីនោះ ។ ក្នុងថ្ងៃជួបគ្នាដំបូងជាមួយសិស្ស ខ្ញុំបានឲ្យសិស្សទាំងអស់សរសេរអំពីចំណាប់អារម្មណ៍របស់ខ្លួន ដែលជ្រើសរើសយកមុខវិជ្ជានេះ ។ ខេលី បានសរសេរថា នាងជ្រើសរើសយកមុខវិជ្ជានេះ ព្រោះនាងចង់ដឹងឲ្យបានច្រើនពីប្រវត្តិកម្ពុជា និងពិសេសគឺរបបខ្មែរក្រហម ដែលជាផ្នែកមួយនៃប្រវត្តិរបស់គ្រួសារនាង ប៉ុន្តែឪពុកម្តាយរបស់នាង កម្រនិយាយពីរឿងនេះប្រាប់នាងណាស់ ។ ក្នុងពេលដែលសិស្សជាច្រើននៅក្នុងថ្នាក់ចង់ដឹងពីប្រវត្តិរបស់ខ្លួន និងគ្រួសារ និងព្យាយាមប្រមូលព័ត៌មានបន្តិចបន្តួចដែលបានឮជាច្រើនឆ្នាំមកហើយ អំពីរបបខ្មែរក្រហម ក៏ដូចជា សិស្សផ្សេងទៀតដែលចាប់អារម្មណ៍អំពីវប្បធម៌ និងភាពសម្បូរណ៍បែបរបស់ប្រទេសខ្លួន ដែលជាប្រវត្តិមិនពិត ។

ខ្ញុំបង្រៀនមុខវិជ្ជា "កម្ពុជា ៖ វប្បធម៌ និង ជម្លោះ" ដែលបានចាប់ផ្តើមឡើងដំបូង នៅឆ្នាំ២០០៩ ក្នុងវិទ្យាល័យឡូវែល ផ្នែកប្រវត្តិសាស្ត្រ ។ នេះជាថ្នាក់សិក្សាដំបូងបង្អស់នៃប្រវត្តិសាស្ត្រកម្ពុជា និងវប្បធម៌ ដែលបង្រៀននៅក្នុងវិទ្យាល័យឡូវែល និងជាកម្រិតមុខវិជ្ជាដំបូងបង្អស់ដែលបង្រៀនប្រវត្តិសាស្ត្រកម្ពុជា នៅសហរដ្ឋអាមេរិកនេះ ។ ផ្នែកដ៏ធំដែលផ្តួចផ្តើមគំនិតបង្កើតថ្នាក់នេះឡើង គឺអាស្រ័យដោយទីក្រុងឡូវែល មានប្រជាជនខ្មែរដែលមករស់នៅច្រើនជាងគេ ប្រៀបធៀបនឹងទីក្រុងដទៃទៀតនៅសហរដ្ឋអាមេរិក ។ ក្នុងវិទ្យាល័យឡូវែល សិស្សទាំងអស់អាចជ្រើសរើសរៀនមុខវិជ្ជាភាសាខ្មែរ សម្រាប់មុខវិជ្ជាភាសាបរទេសដែលជាការតម្រូវរបស់សាលា និងសិស្សច្រើនជាង៣០ភាគរយដែលជាជនជាតិខ្មែរ ។ ក្នុងបរិវេសនកាលថ្មី ឆ្នាំ២០១៤-២០១៥ នេះ មានសិស្សដល់ទៅ៦០នាក់ ដែលបានចុះឈ្មោះចូលរៀនជាពីរផ្នែកនៃមុខវិជ្ជាប្រវត្តិសាស្ត្រកម្ពុជា និងជាការជ្រើសរើសដែលមានការប្រឡងប្រជែងជាមួយនឹងមុខវិជ្ជាដទៃទៀត ដូចជា វិស្វកម្មចិត្តវិទ្យា និងគណនេយ្យ ។

ចំពោះចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ចំពោះប្រវត្តិសាស្ត្រកម្ពុជា គឺកើតឡើងដោយសារបទពិសោធផ្ទាល់ខ្លួននៃការសិក្សាអំពីហូឡូខស្ត៍ និងអំពើប្រល័យពូជសាសន៍ ដែលសម្របនឹងសិស្សរបស់ខ្ញុំភាគច្រើន ជាជនជាតិខ្មែរសញ្ជាតិអាមេរិក ។ នៅក្នុងឆ្នាំ២០០៨ ខ្ញុំមានឱកាសធ្វើដំណើរទៅប្រទេសកម្ពុជា និងវៀតណាម ជាមួយនឹងអ្នកបណ្តុះបណ្តាលពី ម៉ាសាឈូសេត ដែលរួមបញ្ចូលទាំងថ្នាក់អប់រំរបស់រដ្ឋថែមទៀត ។ ក្នុងដំណើរទស្សនកិច្ចរបស់យើង យើងបានទៅទស្សនាមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយទទួលបានការណែនាំពីនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ និងបានស្វែងយល់ពីការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្រៀនពីភាពឃោរឃៅនៃរបបខ្មែរក្រហមដល់សិស្សអនុវិទ្យាល័យ ។ នៅពេលត្រឡប់មក ម៉ាសាឈូសេត វិញ ខ្ញុំបានពិភាក្សាជាមួយប្រធានផ្នែកប្រវត្តិសាស្ត្រពីលទ្ធភាពដែលអាចបង្កើតឡើងនូវថ្នាក់ប្រវត្តិសាស្ត្រកម្ពុជានៅវិទ្យាល័យឡូវែល ។ កម្មវិធីដែលយើងបង្កើតឡើង គឺបានមក

ពីការសិក្សាស្វែងយល់ក្នុងដំណើរទស្សនកិច្ចទៅប្រទេសកម្ពុជាលើកទីមួយក្នុងឆ្នាំ២០០៨ និងពីដំណើរលើកទីពីក្នុងរដូវរំហើយ ដែលជាពេលខ្ញុំបានចូលរួមជាអ្នកបណ្តុះបណ្តាលក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅទីក្រុងភ្នំពេញជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ថែមលើនេះទៀត វិទ្យាល័យឡូវែល និងមជ្ឈមណ្ឌលឯកសារកម្ពុជា មានកិច្ចព្រមព្រៀងជាដៃគូ ដែលជារៀងរាល់ឆ្នាំ មជ្ឈមណ្ឌលឯកសារកម្ពុជាអាចបញ្ជូនបុគ្គលិកម្នាក់ឬពីរនាក់ មកហាត់រៀននៅក្នុងថ្នាក់ និងរៀនពីវិធីសាស្ត្របង្រៀននៃអំពើប្រល័យពូជសាសន៍ ។ ក្នុងនោះដែរ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានចែករំលែកបទពិសោធដែលខ្លួនមាន ជាមួយសិស្សអំពីរបបខ្មែរក្រហម និងសហគមន៍ ។ ចាប់តាំងពីការសហការជាមួយគ្នាមក មានបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន៩រូបហើយ ដែលបានចូលរួមក្នុងកម្មវិធីផ្លាស់ប្តូរវប្បធម៌នេះ ។

ទោះបីជា “កម្ពុជា ៖ វប្បធម៌ និង ជម្លោះ” ផ្តោតសំខាន់លើប្រវត្តិសាស្ត្រខ្មែរក្រហមក៏ដោយ ក៏កម្មវិធីសិក្សា មានការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាជាទូទៅដែរ ។ ដើម្បីងាយស្រួលយល់ពីភាពចលាចលនៃនយោបាយក្នុងរបប ប៉ុល ពត សិស្សទាំងអស់ចាំបាច់ត្រូវតែស្វែងយល់ពីការសិក្សាទូទៅនៃប្រវត្តិកម្ពុជាទាំងមូល និងភូមិសាស្ត្ររបស់កម្ពុជា ។ សិស្សបានរៀនបន្ថែមពីការចាប់ផ្តើម និងការដួលរលំនៃរបបខ្មែរក្រហម, ការដាក់អាណានិគមរបស់អឺរ៉ុប និងការអន្តរាគមន៍របស់បរទេស, ជម្លោះជនជាតិដើមភាគតិច, សារសំខាន់របស់ទន្លេមេគង្គ និង បឹងទន្លេសាប និងឯករាជ្យភាពរបស់ប្រជាជនកម្ពុជា ។ លើសពីនេះទៀត កម្មវិធីសិក្សាបានបង្ហាញថា ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាទាំងមូល វាប្រសើរជាងការសិក្សាត្រឹមតែប្រវត្តិសាស្ត្រខ្មែរក្រហម (ប្រវត្តិសាស្ត្រនៃវិនាសកម្មដែលមានលក្ខណៈខុសពីគេ បើនិយាយចំពោះប្រជាជន និងប្រជាជាតិដ៏អស្ចារ្យមួយ) ។ ជារៀងរាល់ឆ្នាំ យើងមានភ្ញៀវពីសហគមន៍ខ្មែរមកទស្សនាថ្នាក់រៀន ដូច្នេះភ្ញៀវទាំងអស់ អាចចូលរួមជាផ្នែកមួយ ក្នុងការចែករំលែកនូវចំណេះដឹងអំពីរបាំប្រពៃណីខ្មែរ និង ម្ហូបខ្មែរ ហើយរួមទាំងការធ្វើសក្ខីកម្មពីបទពិសោធពីជីវិតរបស់គាត់រស់នៅក្នុងប្រទេសកម្ពុជា ។

ក្នុងពេលនោះដែរ ខេលី បានយល់ដឹងពីការឡើងកាន់អំណាច និងការអនុវត្តនយោបាយដ៏ឃោរឃៅនៃរបបខ្មែរក្រហម ។ សិស្សទាំងអស់ក៏បានយល់ដឹងយ៉ាងច្បាស់ពីប្រវត្តិសាស្ត្រ វប្បធម៌ និងភូមិសាស្ត្ររបស់ប្រទេសកម្ពុជា ។

ប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ បានបង្រៀនអំពីអត្តសញ្ញាណ អាណាចក្រ វប្បធម៌ សាសនា និងរដ្ឋាភិបាល ។ បរិបទប្រវត្តិសាស្ត្រខ្មែរក្រហម ក្នុងរយៈពេលសិក្សាស៊ីជម្រៅរបស់កម្ពុជា និងប្រជាជនបានអនុញ្ញាតិឲ្យសិស្សមានទំនាក់ទំនងជាមួយការចែករំលែកពីអតីតកាល ស្របពេលនឹងការសម្លឹងមើលទុកជាមុននូវនយោបាយ ដែលមានភាពស្មុគស្មាញ និងពិភពលោកដ៏ធំធេងក្នុងពេលទទួលសញ្ញាបត្រខាងមុខនេះ ។ **ម៉ៃរាម ម៉័រហ្គេនស្ទើន**

## ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ញ៉ន ស៊ី ស្នាក់នៅផ្ទះលេខ៨៧៦G សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រកាសស្វែងរកឈ្មោះ អៀវ ឡេងហាវ ភេទប្រុស កើតឆ្នាំ១៩៤៨ នៅភូមិក្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ពីមុន ឡេងហាវ គឺជាសាស្ត្រាចារ្យរូបវិទ្យា-គីមី នៅវិទ្យាល័យអង្គរ ទីរួមខេត្តសៀមរាប ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ឡេងហាវ និងភរិយាឈ្មោះ គួច សាយឡេង ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិកន្ទួត ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

នៅខែធ្នូ ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលបញ្ញវន្តនៅតាមភូមិឃុំ ក្នុងស្រុកភ្នំស្រុក ហើយបានបញ្ជូន ឡេងហាវ និងភរិយាទៅនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ ឡេងហាវ និងភរិយាបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ។

ប្រសិនបើបងប្អូនណាបានឮឬស្គាល់ឈ្មោះដូចខាងលើសូមផ្តល់ដំណឹងមកខ្ញុំបាទតាមរយៈអាសយដ្ឋានក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ទូរស័ព្ទលេខ ០១២ ៩៥៨ ៥៤៦ ឬ អ៊ីមែល nhansy04@yahoo.com ។ **សូមអរគុណ!**

# ការយល់ដឹងរបស់ខ្ញុំ តាមរយៈបទពិសោធ និងរឿងរ៉ាវ របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម


ជុំ ម៉ី អតីតអ្នកទោសនៅមន្ទីរស-២១ ឬគុកទួលស្លែង

អ្នកដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម បានទទួលរងនូវជីវភាពឈឺចាប់ ក៏ដូចជាការលងបន្លាចពីអតីតកាលដ៏សែនជូរចត់នៃរបបព្រៃផ្សៃនេះ ដែលមានរយៈពេលប្រមាណជាង ៣០ឆ្នាំមកហើយ ។ មនុស្សមួយចំនួនពុំចង់រំឭកឡើងវិញពីបទពិសោធឈឺចាប់នេះទេ អ្នកទាំងនោះក៏ពុំមានភាពក្លាហានទៅកាន់ទីតាំងនៃភាពសោកសង្រេងរបស់ខ្លួនដែរ ។ ប៉ុន្តែ ចំពោះ ជុំ ម៉ី គឺមិនដូច្នោះទេ ។ ក្នុងនាមជាជំនួយការនៃនិស្សិតមួយរូបក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា នាងខ្ញុំមានឱកាសក្នុងការសម្ភាសជាមួយអ្នករស់រាននៃមន្ទីរស-២១ ម្នាក់ក្នុងចំណោមអ្នករស់រានពីររូប ។ លោកតែងតែមកកាន់ទីតាំងដែលជាមន្ទីរឃុំឃាំង និងជាទីកន្លែងដែលលោកទទួលរងទារុណ្ឌកម្មក្នុងអំឡុងពេលជាប់ឃុំឃាំង ។ នៅក្នុងបទសម្ភាសនេះ ជុំ ម៉ី បានលើកឡើងនូវប្រយោគមួយដែលស្រដៀងទៅនឹងអ្វីដែលបានលើកឡើងក្នុងសៀវភៅរបស់គាត់ថា «ខ្ញុំមកកាន់ទីនេះរៀងរាល់ថ្ងៃ ដើម្បីប្រាប់ពីការពិតរបស់គុកទួលស្លែង ទៅកាន់ពិភពលោក ដូចនេះ ឧក្រិដ្ឋកម្មនឹងមិនកើតឡើងជាថ្មីនៅផ្នែកណាមួយនៃពិភពលោកនេះទៀតឡើយ» ។ ជួបដោយផ្ទាល់ និងសង្កេតឃើញពីទឹកមុខរបស់លោក បានឲ្យខ្ញុំកាន់តែចង់ដឹងពីប្រវត្តិរឿងរ៉ាវរបស់គាត់ ។ ឥទ្ធិពលនៃការស្តាប់នូវសម្តីរបស់គាត់ដោយផ្ទាល់ មានភាពជ្រាលជ្រៅជាងអំនាននូវពាក្យដែលគាត់បានសរសេរនៅក្នុងសៀវភៅរបស់គាត់ទៅទៀត ។

បើទោះជាស្ថិតក្នុងវ័យ៨០ឆ្នាំក៏ពិតមែន ជុំ ម៉ី នៅតែបន្តទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជារៀងរាល់ថ្ងៃ ដើម្បីចែករំលែកនូវបទពិសោធអតីតកាលសោកសៅរបស់គាត់ដល់អ្នកទស្សនា ។ គាត់បានលើកឡើងថា «ខ្ញុំយំរាល់យប់ និងរាល់ដង នៅពេលលើកឡើងពីរបបខ្មែរក្រហម ។ ការលើកឡើងនេះ បានរំឭកខ្ញុំពីប្រពន្ធ និងកូនរបស់ខ្ញុំ» ។ ចំពោះ ជុំ ម៉ី ការរំឭកពីរបបខ្មែរក្រហម គឺប្រៀបបានទៅនឹងការកាត់សាច់របស់គាត់យ៉ាងដូច្នោះដែរ ។ ទោះបីជាយ៉ាងនេះក្តី ដើម្បីអប់រំដល់មនុស្សទូទៅ គាត់បានសម្រេចចិត្តប្រឈមមុខនឹងការឈឺចាប់នេះរៀងរាល់ថ្ងៃ ។ សេចក្តីមោះមុតរបស់គាត់ បានបង្រៀនយើងឲ្យជម្នះនូវរាល់ឧបសគ្គដែលយើងជួបប្រទះក្នុងជីវិត បើទោះជាវាមានការឈឺចាប់ក៏ដោយ យើងមិនគួរមានការភ័យខ្លាច និងរួញរាឡើយ ។ យើងគប្បីធ្វើជាម្ចាស់លើបទពិសោធទាំងអស់នេះ និងយកឈ្នះលើវា ។ យើងនឹងទទួលបាននូវជ័យជម្នះប្រសិនបើយើងមានការប្តេជ្ញា ។ អាកប្បកិរិយារបស់ ជុំ ម៉ី សបញ្ជាក់ថា យើងពុំអាចធ្វើការផ្លាស់ប្តូរនូវអតីតកាលរបស់យើងបានទេ ក៏ប៉ុន្តែ គាត់បានបង្ហាញខ្ញុំពីវិធីសាស្ត្រក្នុងការក្លាយខ្លួនជាបុគ្គលមួយរូបដែលមានភាពរឹងប៉ឹង ទាំងផ្នែកស្មារតី និងកម្លាំងកាយ ។ គាត់ជាបុគ្គលមួយរូបដែលរឹងប៉ឹង ដែលមិនអនុញ្ញាតឲ្យអតីតកាលគ្រប់គ្រងលើខ្លួន ។ ខ្ញុំយល់ថា អតីតកាលរបស់គាត់ពុំបានលងបន្លាចគាត់នោះទេ ផ្ទុយទៅវិញគឺធ្វើឲ្យគាត់កាន់តែរឹងមាំថែមទៀត ។ លើសពីនេះទៅទៀត គាត់បានធ្វើការតទល់ជាមួយ ឌុច និងការស្វែងរកនូវយុត្តិធម៌ ជាជាងការភ័យខ្លាចនូវប្រធានគុកស-២១ រូបនេះ ។

ជុំ ម៉ី បានប្រើអតីតកាលរបស់ខ្លួន ក្នុងការជួយសង្គ្រោះនូវ

ជនរងគ្រោះដទៃទៀត ក៏ដូចជាជួយដល់ជនងាយរងគ្រោះដទៃទៀត ។ តាមរយៈការលក់នូវសៀវភៅរបស់ខ្លួន គាត់អាចទទួលបានកម្រៃសម្រាប់ទ្រទ្រង់ជីវភាពរបស់ខ្លួនសមរម្យ ។ យ៉ាងណាមិញ គាត់ពុំប្រើប្រាស់ចំណូលនោះដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួននោះទេ ។ គាត់បានបង្កើតនូវអង្គការមួយដែលមានឈ្មោះថា "សមាគមជនរងគ្រោះនៃរបបខ្មែរក្រហម ។" លើសពីនេះ គាត់បានផ្តល់ជាថវិកាដើម្បីជួយដល់អ្នកដែលរស់រាន និងកុមារកំព្រា ។ គាត់បានមានប្រសាសន៍ថា "យើងជាខ្មែរ យើងត្រូវតែជួយគ្នាទៅវិញទៅមក" ។ ភាពអង់អាច និងភាពសប្បុរសរបស់គាត់ បានបង្ហាញប្រាប់ខ្ញុំថា យើងគួរធ្វើអ្វីដែលយើងអាចធ្វើបានជួយដល់អ្នកដទៃ ។

ចំពោះទស្សនៈរបស់ខ្លួន ជុំ ម៉ី បានផ្តល់តម្លៃលើជីវិតជាខ្លាំង ។ ក្នុងអំឡុងរបបខ្មែរក្រហម គាត់បានទទួលរងនូវការធ្វើទុក្ខបុកម្នេញជាច្រើន ដូចជា ការឆក់ខ្សែភ្លើង ការដកក្រចក និងការវាយដំយ៉ាងព្រៃផ្សៃ ។ មនុស្សគ្រប់គ្នា មិនសុទ្ធតែអាចទ្រាំទ្រនូវទារុណកម្មនេះបាននោះទេ ។ មនុស្សមួយចំនួន នឹងធ្វើអត្តឃាតដើម្បីបញ្ចប់នូវភាពសោកសង្រេងនេះ ។ ចំណែក ម៉ី គឺមិនដូច្នោះទេ ។ គាត់បានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីឲ្យបានរស់រានមានជីវិត និងប្រាប់នូវរឿងរ៉ាវដែលគាត់បានឆ្លងកាត់ដល់អ្នកដទៃ ។ ទង្វើទាំងនេះ បានផ្តល់សារសំខាន់ដល់រូបខ្ញុំ គឺ យើងមិនគួរបញ្ចប់ជីវិតរបស់ខ្លួនដោយងាយទេ ហើយបញ្ហាលំបាកដែលយើងជួបប្រទះគង់តែនឹងកន្លងផុត ។

បើទោះជាមានការឈឺចាប់ក្នុងការចងចាំនូវអតីតកាលដ៏ជូរចត់ ជុំ ម៉ី នៅតែបន្តឆ្ពោះទៅមុខយ៉ាងអង់អាច ។ ទោះបីជាគាត់មានភាពពិបាកក្នុងការបញ្ឈរលើមួយចំហៀងខ្លួនរបស់គាត់ក្តី គាត់នៅតែបន្ត និយាយរឿងរ៉ាវប្រាប់ដល់ក្រុមទេសចរ នៅឯសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ពីព្រលឹមទល់ព្រលប់រៀងរាល់ថ្ងៃ ដោយពុំខ្វាចហត់នឿយ ។ បន្ទាប់ពីកិច្ចសម្ភាសនិងគំរូល្អពីគាត់ ខ្ញុំត្រូវបានលើកទឹកចិត្តបន្ថែមក្នុងការខិតខំប្រឹងប្រែងដើម្បីរៀនសូត្របន្ថែមពីរបបខ្មែរក្រហម ។ ខ្ញុំដឹងថា វាជាដំណើរដ៏វែងឆ្ងាយមួយ ប៉ុន្តែ ជុំ ម៉ី ផ្ទាល់ក៏បានធ្វើដំណើរ ដ៏វែងឆ្ងាយដែរ ក្នុងការជួយដល់ប្រជាជនកម្ពុជា ។ ដោយមានគាត់ជាគំរូ ខ្ញុំមានក្តីសង្ឃឹមពោរពេញដោយការប្តេជ្ញាចិត្ត និង ជំហរដ៏រឹងមាំ ។ **សុភ័ក្រ្ត ភាណា**

# ដំណឹងស្វែងរកឪពុក

ខ្ញុំបាទឈ្មោះ ព្រា ភារុន កើតឆ្នាំ១៩៦០ មានស្រុកកំណើតនៅភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ សព្វថ្ងៃរស់នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ខ្ញុំបាទមានបងប្អូន៥នាក់ (ស្រី២នាក់ ប្រុស៣នាក់) និងមានម្តាយឈ្មោះ នួន គឹមហៀង សូមប្រកាសរកឪពុក ឈ្មោះ ព្រា ហង្សរី កើតឆ្នាំជូត ។ មុនរបបខ្មែរក្រហម ឪពុកខ្ញុំធ្វើជាពិធីការសាលាក្រុងសៀមរាប ផ្នែករៀបចំបុណ្យជាតិ ។ ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ខេត្តសៀមរាប ក៏ដូចជាភូមិស្រុកដែលគ្រួសារខ្ញុំរស់នៅគឺភូមិទ្រាំង ។ ខ្មែរក្រហមបានស៊ើបដឹងថា ឪពុកខ្ញុំជាអតីតអ្នករដ្ឋការ ធ្វើការនៅសាលាខេត្ត ។ នៅយប់មួយចន្លោះពីថ្ងៃ១៧ ដល់ ១៩ មេសា ឆ្នាំ១៩៧៥ ខ្ញុំចាំមិនច្បាស់ ខ្មែរក្រហមបានមកហៅឪពុកខ្ញុំពីផ្ទះទាំងយប់ ដោយមិនប្រាប់ថាទៅណាទេ ។ ចាប់តាំងពីថ្ងៃ នោះមកឪពុកខ្ញុំក៏បាត់ដំណឹងរហូត ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង និងស្គាល់ពីឪពុកខ្ញុំឈ្មោះ ព្រា ហង្សរី នេះ សូមទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទខ្ញុំបាទផ្ទាល់លេខៈ ០១៦ ៥១៨ ៧៨៧ ។

***សូមអរគុណ!***

# លិខិតថ្លែងអំណរគុណ

ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨

ជូនចំពោះ កញ្ញា នូ លេខា!

ខ្ញុំបាទ បានទទួលរួចហើយនូវសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់លោកប៉ុកញ្ញា ពីលោក ហេង មុន្នីចិន្តា ។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការផ្តល់សេចក្តីទុកចិត្តមកលើមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈការបរិច្ចាគសៀវភៅកំណត់ហេតុជាប្រវត្តិសាស្ត្រនេះ ។ សៀវភៅកំណត់ហេតុនេះចូលរួមចំណែកយ៉ាងសំខាន់ដល់បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបម្រើដល់សាធារណជនគ្រប់រូប ។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតឡើងដោយកម្មវិធីស្រាវជ្រាវអំពើប្រល័យពូជសាសន៍របស់សកលវិទ្យាល័យយ៉េល នៅក្នុងឆ្នាំ១៩៩៥ ហើយក្លាយជាវិទ្យាស្ថានស្រាវជ្រាវកម្ពុជាឯករាជ្យ នៅខែមករា ឆ្នាំ១៩៩៧ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញ និងមិនមែនរដ្ឋាភិបាល ដែលត្រូវបានទទួលស្គាល់ជាស្ថាប័នឯករាជ្យនៅក្នុងប្រទេសកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងសំខាន់ពីរយ៉ាងគឺ ការចងចាំ និង យុត្តិធម៌ ដែលជាមូលដ្ឋានគ្រឹះដើម្បីបង្កើតឲ្យមាននីតិរដ្ឋ និងការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា ។

បច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងស្ថិតក្នុងដំណើរការសាងសង់វិទ្យាស្ថានអចិន្ត្រៃយ៍ ដែលរចនាឡើងដោយស្ថាបត្យករ ហ្សាហា ហាឌីត ។ដូច្នេះ កំណត់ហេតុនេះនឹងនៅតែមានជីវិតជារៀងរហូត ហើយជាប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា និងពិភពលោកដើម្បីស្វែងយល់បន្ថែមទៀតអំពីអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។

សូមមេត្តាទទួលនូវសេចក្តីគោរពរាប់អានអំពីខ្ញុំបាទ ។

ឆាំង យុ

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ *truthkokthay@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 176, 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.